**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ECONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

**សារណាបញ្ចប់ការសិក្សា**

# បទដ្ឋានគតិយុត្តកម្ពុជាលើអំពើជួញដូរមនុស្ស

ស្រាវជ្រាវនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះលោក **ស្លេះ ”រ៉ស៊ីទីន**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សុត័ណ្ឌា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# អារម្ភកថា

ការតាក់តែងជាសៀវភៅនេះឡើងគឺបានឆ្លងកាត់នូវដំណាក់កាល ជាច្រើនទើបទទួលបានការសម្រេចជាសមិទ្ធផល។ វាមិនមែនជាភាពងាយស្រួលសម្រាប់ខ្ញុំបាទជានិស្សិតដែលចាប់ផ្តើមហាត់រៀនតាក់តែងជាកម្រងឯកសារ ដែលមានទ្រង់ទ្រាយធំ និងមានការប្រឈមទៅនឹងការលំបាក ដោយសារកម្រិតនៃសមត្ថភាព។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយខ្ញុំបានតាំងចិត្តរួចជាស្រេចនៅក្នុងការសម្រេនូវប្រធានបទមួយនេះ។

ទោះបីជាទម្រង់ និងខ្លឹមសារមានលក្ខណៈខ្វះខាត ឬមិនត្រឹមត្រូវមួយចំនួនក៏ដោយតែសម្រាប់ជាប្រយោជន៍ដល់សង្គម ជាពិសេសស្ត្រី និងកុមារដែលត្រូវបានគេជួញដូរក្នុងគោលដៅកេងប្រវញ្ចន៍ និងរំលោភបំពាននានា។ ប្រជាពលរដ្ឋមួយចំនួនមិនបានយល់ដឹងពីការប្រឈមទាំងនោះទេ ពីព្រោះពួកគេមានលទ្ធភាពទទួលបានពត៌មានតិចតួច និងជាពិសេសមិនមានចំណេះដឹងជ្រៅជ្រះ។ សៀវភៅមួយនេះអាចជាគន្លឹះសម្រាប់ប្រជាជនទូទៅដើម្បីធ្វើការសិក្សាបាន និងជាប្រយោជន៍សម្រាប់ការស្រាវជ្រាវរបស់និសិត្សជំនាន់ក្រោយៗផងដែរ។

ខ្ញុំបាទពិតជាមានសេចក្តីសោមនស្សជាអនេក ក្នុងការទទួលការរិះគន់ដើម្បីស្ថាបនា និងទទួលនូវការកែតម្រូវនានាពីសំណាក់សាធារណៈជន។

ជាចុងក្រោយខ្ញុំបាទសូម គោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីសំណាក់ជនរួមជាតិ ពុក-ម៉ែ បង-ប្អូន មាមីង។ ហើយសូមជូនពរឲ្យមានសុខភាពល្អទទួលទានមានបានគ្រប់ក្រុមគ្រួសារ និងសូមជនពរឲ្យប្រជាជនទូទៅជួបតែសេចក្តីសុខចម្រើនសុភមង្គលក្នុងក្រុមគ្រួសារ ជាពិសេសចៀសឲ្យផុតពីការក្លាយទៅជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ជាពិសេសចុងក្រោយនោះសូមធ្វើការលើកទឹកចិត្ត និងថ្លែងអំណរគុណចំពោះរាល់ប្រតិបត្តិការរបស់សប្បុរសជន រាជរដ្ឋាភិបាល និងអង្គការនានា ដែលបានខិតខំប្រឹងប្រែងបង្ការ ការពារ និងជួយជ្រោមជ្រែងដល់ជនរងគ្រោះនៃអំពើសជួញដូរមនុស្ស។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ស្លេះ រ៉ស៊ីទីន ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៧ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ផ្នែកនីតិសាស្ត្រ។ ខ្ញុំបាទបានធ្វើការស្រាវជ្រាវទៅលើប្រធានបទ"**បទដ្ឋានគតិយុត្តកម្ពុជាលើអំពើជួញដូរមនុស្ស**" បានបញ្ចប់ដំណើរការនៃការស្រាវជ្រាវ និងចេញជាឯកសារស្តាពរមួយដែលចងក្រងជាសៀវភៅនេះឡើង។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- ព្រះបាទនរោត្តម **សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនចៅ និងជាតិមាតុភូមិ។
- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដឹកនាំ នាវាកម្ពុជាលើផ្លូវនយោបាយមួយប្រកបដោយសុច្ឆរិត រក្សាបាននូវស្ថេរភាព សន្តិភាព និងការអភិវឌ្ឍ។
- សាស្ត្រាចារ្យលោក **ហោ សុវ័ណ្ណា** ដែលបានណែនាំខ្ញុំបាទនូវការតាក់តែងជាអត្ថបទសារណានេះឡើងប្រកបដោយជោគជ័យ ព្រមទាំងផ្តល់ជាបទពិសោធន៍ និងដំបូន្មានល្អសំរាប់ជាមូលដ្ឋានក្នុងការសរសេរជាសៀវភៅនេះ។
- គណៈកម្មការសាលា និងលោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀនទាំងចំណេះដឹង និងសីលធម៌មកកាន់ខ្ញុំបាទ។
- ជាពិសេសសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅក្រៃលែងដល់ អ្នកមានគុណទាំងពីរ ដែលបានបីបាច់ចិញ្ចឹមប្រៀនប្រដៅសព្វបែបយ៉ាង ដល់រូបកូនឲ្យក្លាយជាមនុស្សល្អម្នាក់សម្រាប់បម្រើក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។

ជាទីបញ្ចប់ សូមប្រសិទ្ធពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងពីរទទួលបានជោគជ័យគ្រប់ភារកិច្ច និង សុខភាពរឹងមាំទទួលទានបានគ្រប់ៗគ្នា ព្រមទាំងសូមបួងសួងបរមីនៃវត្ថុស័ក្តសិទ្ធក្នុងលោកសូមជួយថែរក្សារ លោកមានគុណទាំងពីរ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ឲ្យមានសុខភាពល្អ។ សូមពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពុលៈ និង បដិភាណៈ កុំបីឃ្លាងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា** ........ ៣

**ផ្នែកទី១ សញ្ញាណទូទៅនៃការជួញដូរមនុស្ស** ........ ៣

កថាខណ្ឌទី១ និយមន័យ ........ ៣

ក. និយមន័យជាសកល ........ ៣

ខ. និយមន័យជាតិ ........ ៤

កថាខណ្ឌទី២ ការកំណត់អត្តសញ្ញាណជនពាក់ព័ន្ធ ........ ៥

ក. អត្តសញ្ញាណជនល្មើស ........ ៥

ខ. អត្តសញ្ញាណជនរងគ្រោះ ........ ៦

**ផ្នែកទី២ គោលបំណងនៃការជួញដូរមនុស្ស** ........ ៧

កថាខណ្ឌទី១ គោលបំណង រំលោភបំពានផ្លូវភេទ ........ ៧

ក. ឈ្លានពានខាងផ្លូវភេទ ........ ៧

ខ. ផលិតរូបអាសអាភាស ........ ៧

គ. កេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដ៏ទៃ ........ ៨

កថាខណ្ឌទី២ គោលបំណងនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ........ ១០

ក. ពលកម្មដោយបង្ខំ ........ ១០

ខ. ការបញ្ជាំខ្លួនដោះបំណុល ........ ១១

គ. ពលកម្មកុមារ ........................................................................................................ ១៣

ឃ. រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈជនរងគ្រោះ.................................. ១៤

**ផ្នែកទី៣ ចំណាត់ការរបស់អ្នកជួញដូរទៅលើជនរងគ្រោះ** ......................... ១៧

កថាខណ្ឌទី១ កត្តាឈានចូលអន្ទាក់ជនល្មើស ............................................. ១៧

ក. កត្តាជម្រុញជនរងគ្រោះ.................................................................. ១៨

ខ. កត្តាទាញជនរងគ្រោះ ................................................................... ១៨

កថាខណ្ឌទី២ វិធីនៃការរក្សាទុកជនរងគ្រោះដោយជនល្មើស........................ ១៩

ក ការកាត់ផ្ដាច់នូវទំនាក់ទំនង............................................................... ១៩

ខ. ការប្រើប្រាស់អំពើហិង្សា និងការគម្រាមកំហែង ............................. ២០

គ. ការប្រើប្រាស់គ្រឿងញៀន ................................................................ ២០

ឃ. ការបង្កើនបំណុល និងការធ្វើឲ្យអាម៉ាស់ដល់ក្រុមគ្រួសារ .............. ២០

**ផ្នែកទី៤ ផលប៉ះពាល់ និងជួយសង្គ្រោះជនរងគ្រោះ** ................................ ២១

កថាខណ្ឌទី១ ផលប៉ះពាល់ទៅលើជនរងគ្រោះ ........................................ ២១

ក. សុខភាព.................................................................................................. ២១

ខ. បាត់បងធនធានមនុស្ស ...................................................................... ២១

គ. សិទ្ធិរបស់ជនរងគ្រោះ ....................................................................... ២២

ឃ. ប៉ះពាល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរ .................................................. ២២

កថាខណ្ឌទី២ ការជួយសង្គ្រោះលើជនរងគ្រោះ........................................... ២២

ក. ទិដ្ឋភាពនៃការជួយសង្គ្រោះ ............................................................... ២២

ខ. ការជួយសង្គ្រោះដោយស្ថាប័នជាតិ ........................................ ២៤

គ. ការជួយសង្គ្រោះដោយអង្គការក្រៅរដ្ឋាភិបាល ........................................ ២៦

**ជំពូកទី២ ចំណាត់ប្រឆាំងទៅនឹងការជួញដូរមនុស្សដោយបទដ្ឋានគតិយុត្ត**...២៧

**ផ្នែកទី១ បទដ្ឋានគតិយុត្តអន្តរជាតិ** ........................................ ២៧

កថាខណ្ឌទី១ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ........................................ ២៧

ក. សញ្ញាណនៃ ICCPR ........................................ ២៧

ខ. បញ្ញត្តិអំពីការបំពានសិទ្ធិមនុស្ស ........................................ ២៧

កថាខណ្ឌទី២ អង្គការពលកម្មអន្តជាតិ និងពិធីសារនៃអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ........................................ ២៩

ក. សញ្ញាណនៃអង្គការពលកម្មអន្តរជាតិ និងពិធីសារ ........................................ ២៩

ខ. បទប្បញ្ញាត្តិអំពីការងារ ........................................ ២៩

កថាខណ្ឌទី៣ អនុសញ្ញាស្តីពីទាសភាព ........................................ ៣១

ក. សញ្ញាណនៃអនុសញ្ញាស្តីពីទាសភាព ........................................ ៣១

ខ. បទបញ្ញាត្តិអំពីទាសភាព ........................................ ៣១

កថាខណ្ឌទី៤ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍ទៅលើពេស្យាចារជនដ៏ទៃ (ហៅកាត់ CSTPEPO) ........................................ ៣២

ក. សញ្ញាណនៃ CSTPEPO ........................................ ៣២

ខ. បទប្បញ្ញាត្តិអំពី CSTPEPO ........................................ ៣២

កថាខណ្ឌទី៥ ពិធីសារប៉ាឡឺម៉ូ ........ ៣៣
ក. សញ្ញាណនៃពិធីសារប៉ាឡឺម៉ូ ........ ៣៣
ខ. បទបញ្ញត្តិអំពីការជួញដូរមនុស្ស ........ ៣៤
**ផ្នែកទី២ បទដ្ឋានគតិយុត្តជាតិ** ........ ៣៦
កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ........ ៣៦
កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជា ........ ៣៧
ក. សញ្ញាណនៃក្រមព្រហ្មទណ្ឌ ........ ៣៧
ខ. បញ្ញត្តិជុំវិញសកម្មភាពដួញដូរមនុស្ស ........ ៣៧
កថាខណ្ឌទី៣ ច្បាប់ស្តីពីការងារ ........ ៤០
ក. សញ្ញាណនៃច្បាប់ស្តីពីការងារ ........ ៤០
ខ. បញ្ញត្តិអំពីការកេងប្រវ័ញ្ចន៍ពលកម្ម ........ ៤១
កថាខណ្ឌទី៤ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ(ហៅកាត់LSHTSE) ........ ៤២
ក. សញ្ញាណនៃ LSHTSE ........ ៤២
ខ. បញ្ញត្តិជុំវិញការរំលោភសិទ្ធិមនុស្ស ........ ៤២
គ. គោលការណ៍នៃការបកស្រាយច្បាប់ ........ ៥០
**សេចក្តីសន្និដ្ឋាន** ........ ៥២
**អនុសាសន៍** ........ ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាជារដ្ឋអធិបតេយ្យមួយ ដែលមានភាពលេចធ្លោលើឆាកអន្តរជាតិក្នុងគ្រប់វិស័យ។ ម្លោះហើយធ្វើឲ្យកម្ពុជាអាចឈានជើងចូលទៅក្នុងសហគមន៍អន្តរជាតិក្រោមរូបភាពទំនាក់ទំនងជាសាកលភាវូបនីយកម្ម។ ដោយសារតែសាកលភាវូបនីយកម្មនាំឲ្យកម្ពុជាទទួលបាននូវភាពវិជ្ជមានជាច្រើនដែលលេចឡើងជាសមទ្ធផល ហើយក្នុងនោះទៀតសោត ក៏នាំឲ្យមានផលអវិជ្ជមានផងដែរ ដែលមានការលំបាកគ្រប់គ្រងនូវសក្តានុពល នៅក្នុងទីផ្សារ និងសង្គម ធ្វើឲ្យមានលំហូរអំពើខុសច្បាប់ជាច្រើន ដែលក្នុងនោះក៏មានការជួញដូរមនុស្សផងដែរ។ ម្យ៉ាងទៀតដោយសារតែកម្ពុជាបានឆ្លងកាត់នូវរបត់នយោបាយ និងសង្គ្រាមជាច្រើនជំនាន់ទាំងសង្គ្រាមស៊ីវិល និងការជ្រៀតជ្រែកពីបរទេស ធ្វើឲ្យប្រទេសឯកាមួយនេះទទួលរងនូវការខូចខាតហេដ្ឋា រចនាសម្ព័ន្ធ បាត់បង់ធនធានមនុស្ស និងធ្វើឲ្យប្រជាជនជួបប្រទះទៅនឹងការលំបាកភាពក្រីក្រ ទុរភិក្សជាដើម។ កត្តាទាំងនេះហើយដែលនាំឲ្យប្រជាជនកម្ពុជា ជាច្រើនបានផុងខ្លួនជាមួយជនដែលកេងប្រវ័ញ្ចន៍ តាមរយៈមធ្យោបាយបោកប្រាស់ សន្យាផ្តល់នូវលក្ខខណ្ឌជីវភាពរស់នៅល្អដល់ពួកគេ។ ក៏ប៉ុន្តែវាគ្រាន់តែជាការភូតភរកុហកទៅកាន់ប្រជាជនក្រីក្រ មានការយល់ដឹងតិចតួច ដែលងាយនឹងទៅតាមជនទុច្ចរិតទាំងនោះដើម្បីយកទៅជួញដូរក្នុងគោលដៅប្រើប្រាស់គ្រប់រូបភាព។

នៅក្នុងសារណានេះខ្ញុំនឹងលើកយកមកបកស្រាតក្រោមប្រធានបទ "បទដ្ឋានគតិយុត្តកម្ពុជាលើអំពើជួញដូរមនុស្ស"។ បទដ្ឋានគតិយុត្តគឺជា ច្បាប់ និងបទបញ្ញាផ្សេងៗដែលបង្កើតឡើងដោយរដ្ឋ ដែលមានលក្ខណៈចាប់បង្ខំ តម្រូវឲ្យអនុវត្ត ទោះបីចេញពីប្រភពណាក៏ដោយ។ អំពើជួញដូរមនុស្សគឺជា អំពើដែលយកមនុស្សជាកម្មវត្ថុសំរាប់លក់ដូរដូចទំនិញ បំលាស់ទីពីទីកន្លែងមួយ ទៅទីកន្លែងមួយផ្សេងទៀតពីមនុស្សម្នាក់ទៅ មនុស្សផ្សេងទៀតដើម្បីទទួលផលចំណេញ។ បើតាម និយមន័យបាឆ្លុះបញ្ចាំងឲ្យឃើញថាជាការចាប់បង្ខំដាក់ទោស ឬបង្ក្រាបនូវសកម្មភាពជួញដូរ មនុស្សដោយច្បាប់កម្ពុជា។

អំពើជួញដូរមនុស្សមានលក្ខណៈធំធេង សាយភាយ និងមានជនរងគ្រោះមកពីប្រភពផ្សេងៗពីគ្នាទូទាំងពិភពលោក។ តាមរបាយការណ៍របស់អង្គការសន្ទសន៍ទាសភាពពិភពលោកបានកំណត់ថាមនុស្សដែលលង់ខ្លួនចូលក្នុងទាសភាពសម័យទំនើបមានចំនួន ២៩.៨លាននាក់ក្នុងសកលលោក។ របាយការណ៍ដដែលបានបង្ហាញថា ប្រទេសចំនួន១៦២ប្រទេសដែលមានលំដាប់ថ្នាក់ប្រជាជនធ្លាក់ខ្លួនចូលទៅក្នុងទាសភាពសម័យទំនើបនេះ។ នៅក្នុងនោះប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី៣៨ ក្នុងចំណោមប្រទេសទាំងអស់នោះ។ ដូចនេះដើម្បីបង្ក្រាប និងផ្តន្ទាទោសទៅលើឧក្រិដ្ឋជននៃអំពើជួញដូរមនុស្ស ព្រះរាជាណាចក្រកម្ពុជាបានបង្កើតជាបទដ្ឋានគតិយុត្តជាច្រើនដែលនឹងត្រូវរៀបរាប់

ក្នុង៖ **ជំពូក១ ទិដ្ឋភាពនៃការជួញដូរមនុស្សនៅកម្ពុជា** និង **ជំពូក២ ចំណាត់ការប្រឆាំងទៅនឹងការជួញដូរមនុស្សដោយបទដ្ឋានគតិយុត្ត។**

# ជំពូកទី១ ទិដ្ឋភាពនៃការជួញដូរមនុស្សនៅកម្ពុជា

## ផ្នែកទី១ សញ្ញាណទូទៅនៃការជួញដូរមនុស្ស

អំពើជួញដូរមនុស្សត្រូវបានគេផ្តល់និយមន័យ ២ គឺនិយមន័យតាមច្បាប់អន្តរជាតិ និងតាមច្បាប់ជាតិ។

### កថាខណ្ឌទី១ និយមន័យ

#### ក. និយមន័យជាសកល

នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនឆ្នាំ ២០០០ មិនបានផ្តល់និយមន័យនៃអំពើជួញដូរមនុស្សនោះទេ រីឯនៅក្នុងអនុសញ្ញាអង្គកាសសហប្រជាជាតិស្តីអំពីការបង្ក្រាបអំពីជួញដូរមនុស្សក៏មិនបានឲ្យនិយមន័យដែរ គ្រាន់តែបញ្ញត្តិអំពីអានុភាពអនុវត្តន៍របស់រដ្ឋដែលបាន ផ្តល់សច្ចាប័នតែប៉ុន្នោះ។ ក៏ប៉ុន្តែនៅក្នុង ពិធីសារស្តីពីការពារ បង្ក្រាប និងដាក់ទណ្ឌកម្មទៅលើការជួញដូរមនុស្សជាពិសេសស្រ្តី និងកុមារដែលបានបង្កើតឡើង ក្នុងគោលបំណងបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលមានឈ្មោះថាពិធីសារប៉ាឡឺម៉ូបានផ្តល់និយមន័យអំពីជួញដូរមនុស្ស នៅក្នុងមាត្រា ៣៖

ការជួញដូរមនុស្សគឺជាការជ្រើសរើសការដឹក ជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬជាការទទួលរក្សាមនុស្សដោយប្រើប្រាស់មធ្យោបាយគម្រាម កំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ឬតាមរយៈមធ្យោបាយនៃការនាំចេញ ផ្ទុយពីឆន្ទៈ ការបោកប្រាស់ ការរក្សាទុក ការរំលោភលើអំណាច ឬតួនាទី ទៅលើជនងាយរងគ្រោះក្នុងគោលបំណងកេងប្រវ័ញ្ច។[1] មធ្យោបាយនៃការជួញដូរមនុស្សតាមរយៈផ្តល់ ឬក៏ទទួលប្រាក់ ឬផលប្រយោជន៍ផ្សេងទៀតពីអ្នកដ៏ទៃដើម្បីធ្វើការគ្រប់គ្រងលើ មនុស្ស ក្នុងគោល បំណង កេង ប្រវ័ញ្ច។

នៅក្នុងមាត្រានេះ កថាខណ្ឌដែលបានបញ្ជាក់អំពីការកេងប្រវ័ញ្ចថាជា សកម្មភាពទាំងឡាយណារួមមាន៖ ការកេងប្រវ័ញ្ច លើព្យោចារ្យជនដ៏ទៃ ឬក៏ទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការងារឬ សេវាដោយបង្ខំ ទាសភាពឬ ក៏ការអនុវត្តន៍ ស្រដៀងគ្នានឹងទាសភាព សេវភាព ឬក៏ការដកហូតសេរីរាង្គ។

[1] មាត្រា៣ កថាខណ្ឌ គ នៃ ពិធីសារប៉ាឡឺម៉ូ។

ដោយឡែក ប្រសិនបើមានការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬការទទួលនូវអនីតិជន ដែលមានគោលបំណងកេងប្រវ័ញ្ចន៍ នឹងត្រូវពិចារណាថាជាការជួញដូរមនុស្សទោះបីជាមិនបានប្រើប្រាស់នូវមធ្យោបាយខាងលើក៏ដោយ។ ត្រូវចាត់ទុកថាអនីតិជនគឺជាមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។

## ខ. និយមន័យជាតិ

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនបានផ្តល់និយមន័យចំៗពីការជួញដូរមនុស្សនោះទេ ក៏ប៉ុន្តែនៅក្នុងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានផ្តល់និយមន័យ នៃអំពើលក់-ដូរមនុស្ស។ ទោះជាយ៉ាងណាក៏ដោយនិយមន័យ អំពើលក់ ដូរមនុស្សគឺមានលក្ខណៈដូចគ្នាទៅនឹងច្បាប់អន្តរជាតិនៃអំពើជួញដូរមនុស្ស បើមើលទៅតាមលក្ខខណ្ឌ គោលបំណង និងការបកស្រាយពាក្យគន្លឹះមួយចំនួន។

នៅក្នុងមាត្រា១៣ នៃច្បាប់ស្តីពីការបង្រ្កាបអំពីជួញដូរមនុស្ស និងអំពីធ្វើអាជីវកម្មផ្លូវភេទចែងថា៖ អំពើលក់ដូរមនុស្សមានន័យថា ប្រគល់ឲ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដំទៃ ឬទទួលដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដំទៃដោយផ្តោះប្តូរទៅ នឹងរបស់មានតម្លៃអ្វីមួយដោយរាប់ចូលទាំងសេវា និងមនុស្សផង។

បទល្មើសនេះមានធាតុផ្សំពីរ ដែលត្រូវបំពេញទើបអាចចោទប្រកាន់បានរួមមាន៖ ប្រគល់ដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ ឬទទួលដោយខុសច្បាប់លើជនណាម្នាក់ និងដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ។

- ការប្រគល់ដោយខុសច្បាប់លើការគ្រប់គ្រងជនណាម្នាក់ ទៅកាន់ជនណាម្នាក់ផ្សេងទៀតមានន័យថា អ្នកលក់ដែលបានគ្រប់គ្រងជនរងគ្រោះ ធ្វើការលក់ទៅឲ្យអ្នកទិញដោយមានតម្លៃតប។ ចំណែកឯការប្រគល់ឲ្យគឺខុសច្បាប់ នៅពេលដែលធ្វើឡើងដោយមធ្យោបាយខុសច្បាប់។ ឧទាហរណ៍: តាមមធ្យោបាយប្រើប្រាស់កម្លាំង បង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោមដោយមានគោលដៅខុសច្បាប់។

- ការទទួលដោយខុសច្បាប់ គឺមានន័យថាអ្នកទិញ ទទួលយកជនរងគ្រោះដោយការជួញដូរពីអ្នកលក់។ លុះត្រាតែមានគោលដៅ និងមធ្យោបាយខុសច្បាប់ ទើបចាត់ទុកវាជាការទទួលដោយខុសច្បាប់។

 សកម្មភាពនៃការជួញដូរមានការផ្តោះប្តូរទៅនឹង របស់មានតម្លៃ។ អ្នកលក់ធ្វើការប្រគល់នូវជនរងគ្រោះឲ្យអ្នកទិញដើម្បីធ្វើការគ្រប់គ្រងដោយទទួលបាននូវ របស់មានតម្លៃ ដូចជា លាភការជាប្រាក់ ឬ ជារបស់ ប្រាក់ វត្ថុមានតម្លៃ ទ្រព្យសម្បត្តិ ( ដែលរួមមាន សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ ឬជួល ប្រភេទណាមួយនៃចលន ឬអចលនទ្រព្យ ) សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬដោយប្រយោល ឬថ្លៃឈ្នួល ពត៌មានមានតម្លៃ ឬការគ្រប់គ្រងលើមនុស្សផ្សេងទៀត។ សរុបមកការលក់ដូរមនុស្ស និងការជួញដូរមនុស្សទោះបីជា ច្បាប់ជាតិមិនបានផ្តល់និយមន័យឲ្យដូចគ្នានិងច្បាប់អន្តរជាតិពិតមែន ក៏ប៉ុន្តែលក្ខណៈវិនិច្ឆយរបស់វាស្រដៀងគ្នាបើមើលទៅលើ គោលបំណង និងមធ្យោបាយ។

## កថាខណ្ឌទី២ ការកំណត់អត្តសញ្ញាណជនពាក់ព័ន្ធ

### ក. អត្តសញ្ញាណជនល្មើស

នៅក្នុងអំពើជួញដូរមនុស្ស មានជនល្មើសពីរប្រភេទដែលមើលឃើញថាមានការពាក់ព័ន្ធទៅនឹងការនាំយកជនរងគ្រោះដោយខុសច្បាប់ដើម្បីទទួលបាននូវផលប្រយោជន៍។ ក្នុងនោះមានជនចម្លែក និងមនុស្សដែលជនរងគ្រោះស្គាល់ច្បាស់លាស់។

ការទទួលគ្រប់គ្រងជនរងគ្រោះដោយមនុស្សចមន្លែកគឺមានតិចតួច ដោយសារតែជនរងគ្រោះមិនមាននូវទំនុកចិត្តទៅតាមជនទាំងនោះ។ ក៏ប៉ុន្តែវានៅតែកើតមានដដែលដោយសារតែជនទាំងនោះប្រើប្រាស់គ្រប់មធ្យោបាយដើម្បីឲ្យជនរងគ្រោះលង់ខ្លួនទៅតាម ដែលអាចប្រើប្រាស់នូវការគម្រាមកំហែង ការលួងលោម បោកបញ្ឆោត ប្រើប្រាស់កម្លាំង ។ល។ ឧទាហរណ៍: មានករណីមួយជនល្មើសប្រដាប់អាវុធ ៥នាក់បានចាប់បង្ខំក្មេងស្រីឈ្មោះ ណារី អាយុ១៣ឆ្នាំ រំលោភសេពសន្ថវៈធ្វើឲ្យនាងមានភាពអាម៉ាស់ និងត្រូវបានគេលក់ពីផ្ទះមួយទៅផ្ទះមួយ រហូតដល់ផ្ទះគ្រួសារមួយបានលក់នាងទៅឲ្យមេបននៅភ្នំពេញ។[2] តាមរយៈការស្ទង់មតិរបស់អង្គការទស្សនៈពិភពលោក ទៅលើជនរងគ្រោះដែលត្រូវបានជួញដូរផ្លូវភេទទៅកាន់ប្រទេសថៃមានតែ២៥%តែ ប៉ុណ្ណោះដែលបានរាយការណ៍ថាបានទៅតាមជនដែលមិនស្គាល់មុខ។[3]

ភាគច្រើននៃជនរងគ្រោះ ដោយសារតែអំពើជួញដូរមនុស្សបានលង់ខ្លួនទៅតាមជនដែលគេធ្លាប់ស្គាល់ច្រើនជាង អាចជាសមាជិកគ្រួសារ ឬក៏អ្នកដែលនៅក្នុងសហគមន៍ជាមួយគ្នា។ មានករណីជាក់ស្តែងបានកើតឡើងទៅលើក្រុមគ្រួសារមួយនៅស្វាយប៉ាក។ ដោយម្តាយទីទាល់ក្រមិន

[2] របាយការណ៍ជួញដូរមនុស្សកម្ពុជារបស់អង្គការទស្សនៈពិភពលោក ទំព័រទី២។

[3]របាយការណ៍របស់អង្គការទស្សនៈពិភពលោកចូលមើលថ្ងៃទី15 មិថុនា 2017,តំណភ្ជាប់https://www.worldvision.com.au/docs/default-source/publications/human-rights-and-trafficking/trafficking-report-cambodia.pdf?sfvrsn=4

មានជម្រើស បានលក់កូនស្រីរបស់ខ្លួនអាយុ ១២ឆ្នាំទៅកាន់ផ្ទះបនមួយក្នុងតម្លៃ ៥០០$។[4] ដំបូងឡើយម្តាយបានជំពាក់លុយពីបុរសម្នាក់ចំនួន ២០០$ ដែលមានអត្រាកាប្រាក់ខ្ពស់បំផុតទោះបីជាដោះដូរកូនស្រីរបស់ខ្លួនក្នុងតម្លៃ ៥០០$ ពិតមែនក៏នៅតែជាប់ការប្រាក់រាប់ពាន់ដុល្លាលើនោះបន្ថែមទៀត។ ដូចនេះម្តាយក៏សម្រេចចិត្តប្រគល់កូនស្រីឲ្យធ្វើការជាស្រីពេស្យាចារពីផ្ទះមួយ ទៅផ្ទះមួយដើម្បីទទួលបានប្រាក់សងបំណុល។

សូមបញ្ជាក់ថា យោងតាមរបាយការណ៍របស់អង្គការទស្សនៈពិភោពលោក ជនរងគ្រោះត្រូវបានជួញដូរដោយមនុស្សក្នុងក្រុមគ្រួសារ ឬសហគមន៍ទៅកាន់បរទេសមានចំនួន ពីរភាគបីនៃជនរងគ្រោះ។[5]

### ខ. អត្តសញ្ញាណជនរងគ្រោះ

ការជួញមនុស្សគឺជាបាតុភូតដែលមានលក្ខណៈស្មុកស្មាញ បុរស ស្ត្រី និងក្មេងៗត្រូវបានគេធ្វើការជួញដូរពីប្រភពផ្សេងៗទៅកាន់ទីកន្លែងដែលមានបរិយាកាសខុសប្លែកពីស្រុក ឬទីកន្លែងដែលខ្លួនធ្លាប់រស់នៅ។ ម្លោះហើយ ទើបធ្វើឲ្យមានការលំបាកនៅក្នុងការកំណត់សម្គាល់ថាមនុស្សប្រភេទណាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

ទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះដោយអំពើជួញដូរមនុស្សអាចត្រូវបានគេស្គាល់តាមរយៈការងាររបស់មន្ត្រីនគរបាល មន្ត្រីអន្តោប្រវេសន៍ អ្នកត្រួតពិនិត្យការងារ អ្នកត្រួតពិនិត្យសុខភាពសុវត្ថិភាព សេវាសង្គម អ្នកថែទាំសុខភាព ឬ ភ្នាក់ងាររដ្ឋផ្សេងៗទៀត។ លើសពីនេះទៅទៀតយើងក៏អាចកំណត់សំគាល់នៃជនរងគ្រោះតាមរយៈ ការងាររបស់អង្គការក្រៅរដ្ឋាភិបាលផ្នែកអន្តោប្រវេសន៍ពេស្យាចារ ឬអង្គការធ្វើការងារទៅលើសិទ្ធិការងារជាដើម។

ក៏ប៉ុន្តែប្រសិនបើជនរងគ្រោះមិនទាន់បានទៅដល់អង្គការ ស្ថាប័នដែលបានរៀបរាប់ខាងលើនេះទេ តើយើងអាចសម្គាល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានតាមរបៀបណា? ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចត្រូវបានគេរកឃើញនៅទីកន្លែងដែលមានការពាក់ព័ន្ធជាមួយនឹងការកេងប្រវ័ញ្ច ដូចជានៅតាមគ្រឹះស្ថានពេស្យាចារ សណ្ឋាគារ ផ្ទះសំណាក់ កសិដ្ឋាន រង្គសាលភោជនីយដ្ឋាន រោងចក្រ ក្លឹប ភ្នាក់ងារជាអ្នកកំដរតាមខារ៉ាអូខេ ការដ្ឋានជីករ៉ែ និងទីកន្លែងម៉ាស្សា

[4] សារពត៌មាន CNN ចូលមើលថ្ងៃទី 01 មិថុនា 2017, តំណភ្ជាប់ http://edition.cnn.com/interactive/2013/12/word/cambodia-child-sex-trade/

[5] របាយការណ៍របស់អង្គការទស្សនៈពិភពលោក របាយការណ៍របស់អង្គការទស្សនៈពិភពលោក ចូលមើលថ្ងៃទី15 មិថុនា 2017, តំណភ្ជាប់ https://www.worldvision.com.au/docs/default-source/publications/human-rights-and-trafficking/trafficking-report-cambodia.pdf?sfvrsn=4

ជាដើម។[6] វិធីដែលល្អដើម្បីស្គាល់អត្តសញ្ញាណជនរងគ្រោះមួយទៀតនោះតាមរយៈ ការសាកសួរពីអ្នកជិតខាងដែលរស់នៅក្នុងសហគមន៍ជាមួយជនរងគ្រោះ ឬអ្នកដែលធ្វើការជាមួយនៅកន្លែងដែលសង្ស័យថាមានការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ច។ ការកំណត់អត្តសញ្ញាណជនរងគ្រោះគឺមានសារៈសំខាន់នៅត្រង់ការផ្តល់ជំនួយដល់ពួកគាត់ទៅលើកន្លែងស្នាក់នៅ ឧបករណ៍ប្រើប្រាស់ ការប្រឹក្សា ជំនួយផ្នែកច្បាប់ ជំនួយសុខភាព ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ជាពិសេសគឺបញ្ចៀសពួកគាត់ពីស្ថានភាពនៃការកេងប្រវ័ញ្ច។

## ផ្នែកទី២ គោលបំណងនៃការជួញដូរមនុស្ស

### កថាខណ្ឌទី១ គោលបំណង រំលោភបំពានផ្លូវភេទ

#### ក. ឈ្លានពានខាងផ្លូវភេទ

ការឈ្លានពានខាងផ្លូវភេទ គឺជាទម្រង់នៃបទល្មើសដែលមានការកើតឡើងជាញឹកញាប់នៅក្នុងសង្គមខ្មែរ ជាពិសេសកើតឡើងទៅលើ ប្រជាជនដែលទីទាល់ក្រ មានការលំបាកនៅតាមទីជនបទ។ ការឈ្លានពានខាងផ្លូវភេទមានន័យថា ជនល្មើសបានប្រព្រឹត្តអំពើជួញដូរដោយមានគោលដៅប្រព្រឹត្ត បទល្មើសផ្លូវភេទ ប្រឆាំងនឹងជនរងគ្រោះដូចជា អំពើរំលោភសេពសន្ថវៈ ឬ អំពើបំពានផ្លូវភេទផ្សេងទៀតដូចជា បទប្រទូសកេរខ្មាស ឬអំពើអាសប្រឆាំងនឹងអនីតិជនជាដើម។[7] ការធ្លាក់ចូលទៅក្នុងបទល្មើសនេះគឺដោយសារតែភាគច្រើនកើតចេញពីការគិតខុសរបស់ ឪពុក-ម្តាយដែលឃើញតែផលប្រយោជន៍ជាលុយកាក់តែមួយមុខ សុខចិត្តប្រគល់ខ្លួនប្រាណរបស់កូនឲ្យទៅជនល្មើស។ ជាក់ស្តែងដូចជាករណីក្មេងស្រីមួយរូបអាយុ១៣ ឆ្នាំត្រូវបានម្តាយរបស់ខ្លួនផ្តោះប្តូរទៅឲ្យបុរសជនជាតិចិនមួយរូបក្នុងតម្លៃ៨០០$។ ក្មេងស្រីរូបនេះបានស្នាក់នៅជាមួយបុរសជនជាតិចិនចំនួន៣ថ្ងៃក្រោយមកនាងក៏ត្រលប់មកវិញ តែបែជាម្តាយរបស់នាងបាន បង្ខំឲ្យធ្វើជាស្ត្រីពេស្យាចារទៅវិញ។ ដោយនាងបានរៀបរាប់ថាក្រោយពីបានបុរសចិនរូបនោះ រំលោភលើផ្លូវភេទខ្លួនមក នាងពិតជាពិបាកខ្លាំងណាស់ ពីព្រោះនាងមានការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត និង បាក់ស្បាតយ៉ាងខ្លាំង។[8]

#### ខ. ផលិតរូបអាសអាភាស

---

[6] សៀវភៅ Human Trafficking is modern day form of slavery, ទំព័រ 33 ដោយអង្គការអន្តោប្រវេសន៍អន្តជាតិ។

[7] កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សននិងអំពើអាជីវកម្មផ្លូវភេទបោះពុម្ពលើកទី២ (ភ្នំពេញ៖ ឆ្នាំ២០១៣), ទំព័រទី ៦៧។

[8] Time Hume,Lisa Cohen and Mira Sorvino, “The women who sold their daughter into sex slavery”CNN(ចូលទស្សនាថ្ងៃទី០២.មិថុនា.២០១៧)។

បទល្មើសផលិតរូបអាសអាភាស មិនត្រូវបានបញ្ចេញជាករណីជាក់ស្តែងតាមទីសាធារណៈនោះទេពីព្រោះវាប៉ះពាល់ដល់សិទ្ធិ និងកិត្តិយសដល់ជនរងគ្រោះយ៉ាងខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ តាមការស្រាវជ្រាវក៏អាចដឹង អំពីប្រតិបត្តិការ របស់ជនល្មើសនៅក្នុងការជ្រើសរើសជនរងគ្រោះ។ ភាគច្រើនជនល្មើសធ្វើការជ្រើសរើសនូវនារីក្មេងៗតាមរយៈការប្រើប្រាស់ គ្រប់មធ្យោបាយខុសច្បាប់ដូចជាបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោម។ ភាគច្រើននៃជនរងគ្រោះ ត្រូវបានគេនាំដោយប្រាប់ថាយកទៅទស្សនៈកិច្ចតែគោលបំណងយកទៅថត។[9]

បទសល្មើសនៃការផលិតរូបអាសអាភាស ជាការផលិតឡើងឲ្យមានជារូបថតគំនូរ អត្ថបទ ខ្សែវីដេអូ និងខ្សែភាពយន្តក្នុងទំរង់ជារូបរៀង ឬអេឡិចត្រូនិចណាមួយដែលធ្វើការពិពណ៌នាអំពីកេរភេទ។ ក៏ប៉ុន្តែការពិពណ៌អំពីកេរភេទតាមរយៈជារូបថតគំនូរ អត្ថបទ ខ្សែវីដេអូ និងខ្សែភាពយន្តទាំងអស់ដែលមានលក្ខណៈទូទៅក៏មិនអាចចាត់ទុកថាការផលិតរូបអាសអាភាសដែរ។ ឧទាហរណ៍: ករណីមានអង្គការមួយចេញផ្សាយជាសាធារណៈ ក្នុងគោលបំណង អប់រំទៅកាន់ប្រជាជនទូទៅអំពីសុខភាពការឆ្លងមេរោគ ឬក្នុងគោលបំណងណែនាំឲ្យប្រើប្រាស់ស្រោមអនាម័យជាដើម។ ត្រូវសន្មតថាមានបទល្មើសលុះត្រាតែ ការផលិតឡើងមានចេតនាធ្វើឲ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។[10] កេរភេទជាទូទៅត្រូវកំណត់ជាលិង្គ ឬរន្ធយោនី ក៏ប៉ុន្តែដើម្បីពង្រីកការការពារដល់ជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស (LSHTSE) ត្រូវបានគេយល់ថាកេរភេទ រួមមានលិង្គ រន្ធយោនី និងរន្ធគូទ។ ដូចនេះការផលិតរូបអាសអាភាសជាការផលិតឡើងឲ្យមានរូបថត គំនូរ អត្ថបទ ខ្សែវីដេរអូ និងខ្សែភាពយន្ត ដែលធ្វើការពិពណ៌នាអំពីផ្លូវភេទ និងមានចេតនាធ្វើឲ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។

### គ. កេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដ៏ទៃ

ការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដ៏ទៃ ឬសញ្ចារកម្មគឺជាអំពើដែលទទួល ឬរំពឹងនឹងទទួលអត្ថប្រយោជន៍ ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដ៏ទៃ ឬអ្នកដែលមានចេតនាធ្វើឲ្យរីកចម្រើនដល់សកម្មភាពអាជីវកម្មពេស្យាចារ។[11] ជនល្មើសទទួលអត្ថប្រយោជន៍អំពីពេស្យាចារច្រើនរូបភាពតាម

---

[9] ស្រាវជ្រាវចេញពីអង្គការលីកាដូ។

[10] កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបោះពុម្ពលើកទី២,២០១៣, ទំព័រ149 ។

[11] កំណាត់កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២,២០១៣,ទំព័រទី១១១។

រយៈការបើកជាផ្ទះបន កន្លែងម៉ាស្សា ខារ៉ាអូខេ។ បើតាមសំដីរបស់មន្ត្រីក្នុងអង្គការលីកាដូមានប្រសាសន៍ថា៖

> ពីមុនឆ្នាំ២០០៨ ដែលមិនទាន់មានច្បាប់ពិសេសស្តីអំពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការបើកន្លែងពេស្យាចារ ឬផ្ទះបនមានលក្ខណៈស្តែងៗតែម្តង។ ក៏ប៉ុន្តែក្រោយពីពេលបង្កើតច្បាប់នេះមកអំពើសញ្ចារកម្មនេះនៅតែកើតមាន ក៏ប៉ុន្តែមិនមានលក្ខណៈស្តែងដូចពីមុនទេ ពួកមេបនធ្វើសកម្មភាពលួចលាក់នៅតាមកន្លែងមួយចំនួនដូចជាកោសជប់ ម៉ាស្សា ឬខារ៉ាអូខេជាដើម។

ផលប្រយោជន៍ដែលជនល្មើសទទួលពីអំពើសញ្ចារកម្មមានច្រើនដូចជាប្រាក់ ឬវត្ថុមានតម្លៃអ្វីមួយ អាចជាលាបការ ជាប្រាក់ ឬគ្រឿងអលង្ការ សំលៀកបំពាក់ ទ្រព្យសម្បត្តិដែលមានរូបរាងជា ផ្ទះ ដី អាគា ឬទ្រព្យសម្បត្តិដែលគ្មានរូបរាង ឧទាហរណ៍ សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ សិទ្ធិលក់ ឬសិទ្ធិជួលប្រភេទណាមួយនៃចលនទ្រព្យ ឬអចនទ្រព្យ។ល។[12]

ចំណែកឯជនរងគ្រោះវិញ ដែលបំរើជាស្ត្រីពេស្យាចារ ដើម្បីឲ្យសញ្ចារិក ឬសញ្ចារិកាទទួលបាននូវផលប្រយោជន៍ គឺជាស្ត្រីដែលបានលក់ព្រហ្មចារីដោយជនល្មើសក្រោយមកទៀតបានផ្ទេរទៅផ្ទះបន។ ជនរងគ្រោះមួយចំនួនទៀតចូលបម្រើក្នុងផ្ទះបនដោយសារតែបំណុល និង អំពើហិង្សាក្នុងគ្រួសារ។ ឧទាហរណ៍: ករណីជាក់ស្តែងមួយបានកើតឡើងដោយម្តាយបានលក់កូនស្រីរបស់ខ្លួនទៅឲ្យផ្ទះបន។ សំណួរត្រូវបានសួរទៅម្តាយថា ហេតុអ្វីទើបអ្នកមីងព្រមលក់កូនទៅឲ្យផ្ទះបន? អ្នកមីងនោះឆ្លើយថា៖

> នាងជាកូនស្រីរបស់ខ្ញុំ ខ្ញុំបានផ្ទុកនាង ក្នុងពោះអស់រយៈពេល៩ខែ ខ្ញុំទ្រាំលំបាកដើម្បីផ្តល់កំណើតឲ្យនាង។ ខ្ញុំនឹងធ្វើអ្វីដែលខ្ញុំពេញចិត្តដោយសារនាងនិងមែនជារបស់អ្នកនោះទេ។ ខ្ញុំមានប្តីដែលតែងតែធ្វើបាបខ្ញុំ គ្រប់ពេលដែលមិនមានលុយ វាគិតតែផឹក វាយកូន វាយប្រពន្ធ និងចាប់រំលោភខ្ញុំជាដើម។ ដោយសារតែខ្ញុំមានកូននៅផ្ទះបន ទើបខ្ញុំមានលុយកាក់បន្តិចបន្តួចសម្រាប់ចាយវាយ និងសងបំណុលគេ។ [13]

មានមូលហេតុជាច្រើនទៀត ដែលស្ត្រីសម្រេចចិត្តធ្វើពេស្យាចារចូលខ្លួនបម្រើឲ្យសញ្ចារិក ឬសញ្ចារិកាដូចជា ជួបប្រទះភាពក្រីក្រ គ្រោះទុរភិក្ស ខូចចិត្តរឿងស្នេហា មិនមានការងារធ្វើជាដើម។

---

[12] កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២,២០១៣, ទំព័រទី៦៧។

[13] Amanda Monson, what is Behind Human Trafficking in Cambodia? (illicit Trade, 2009), ទំព័រទី ១៥។

## កថាខណ្ឌទី២ គោលបំណងនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត

ការជួញដូរមនុស្សក្រៅពីគោលបំណងនៃការរំលោភបំពានផ្លូវភេទ ជនរងគ្រោះកម្ពុជាក៏ត្រូវបានធ្វើការជួញដូរដើម្បីកេងប្រវ័ញ្ចន៍ពលកម្មដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចជាទាសករ ដែលត្រូវបានគេស្គាល់ថាជាទាសភាពសម័យទំនើប។ បុរស ស្ត្រីក្មេងៗកម្ពុជាត្រូវបានធ្វើការជួញដូរស្ថិតនៅក្នុងទំរង់ជាទាសករ ក្រោមរូបភាពជាកាងារដោយបង្ខំ ការដោះបំណុល និងការរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆ្ន:ជាដើម។ ប្រជាជនចំនួន ១.៦៥%នៃប្រជាជនសរុបដែលស្មើនឹងចំនួន ២៥៦,៨០០នាក់ កំពុងតែស្ថិតនៅក្នុងទាសភាពសម័យទំនើបនាពេលបច្ចុប្បន្ន។[14]

### ក. ពលកម្មដោយបង្ខំ

និយមន័យនៃពលកម្មដោយបង្ខំ ត្រូវបានគេផ្តល់នៅក្នុង កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទថាជារាល់ការងារ ឬសេវាកម្មដែលតម្រូវពីជនណាម្នាក់ ដោយការគម្រាមកំហែង ថាដាក់ទណ្ឌកម្មណាមួយ ហើយដោយជននោះមិនបានស្ម័គ្រចិត្តធ្វើដោយខ្លួនឯងទេ។ ការដែលជនរងគ្រោះព្រមទទួលការងារដោយបង្ខំនោះធ្វើ គឺមិនមែនកើតចេញពីឆន្ទ:របស់ពួកគេឡើយ បើសិនជាពួកគេដឹងថាវាជាការងារដែលមានការរំលោភសិទ្ធិនោះក៏គេមិនស្ម័គ្រចិត្តធ្វើដែរ ប៉ុន្តែដោយសារតែមានការគម្រាមកំហែងណាមួយធ្វើឲ្យពួកគេធ្វើដោយមិនសុទ្ធចិត្ត។ ករណីលពកម្មដោយបង្ខំនេះបានកើតឡើងហើយបន្តកើតឡើងចំពោះប្រជាជនរបស់យើង ចំនែកឯជនរងគ្រោះនៃការងារដោយបង្ខំនេះភាគច្រើនត្រូវបានគេឲ្យបម្រើជាកម្មករទូកនេសាទរោងចក្រកាត់ដេរ ឬជាអ្នកបំរើនៅក្នុងផ្ទះជាដើម។

ចំពោះកម្មករកម្ពុជាដែលត្រូវបានជួញដូរឲ្យធ្វើអ្នកនេសាទ ត្រូវបានបញ្ជូនទៅកាន់ប្រទេសជាច្រើនដូចជា ប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសឥណ្ឌូនេស៊ី។ ការទៅធ្វើការនៅលើទូកនេសាទកម្មករមិនមានកិច្ចសន្យាទទួលស្គាល់អ្វីនោះទេ ពួកគេតែងតែធ្វើឡើងដោយការព្រមព្រៀងផ្ទាល់មាត់។ ការមិនបានកំណត់កិច្ចសន្យាបែបនេះ វាកាន់តែធ្វើឲ្យកម្មករទាំងនោះរងគ្រោះដោយការជិះជាន់របស់ម្ចាស់ទូក លើសពីនេះទៅទៀតនោះ គឺម្ចាស់ទូកនេសាទដាក់ជាកាតព្វកិច្ចឲ្យនៅលើទូករហូតក្នុងសមុទ្រដែលមិនឃើញត្រើយចាប់ពី ១៨, ២៤ ឬ៣០ខែឯណោះ។[15] ការលំបាករបស់កម្មករទូកនេសាទមួយផ្នែកទៀតនោះមាន៖ ពួកគាត់ត្រូវបានបង្ខំឲ្យធ្វើការជារៀងរាល់ថ្ងៃចាប់ពី ១៨ទៅ

---

[14] The Global Slavery Index, Haw many people are in modern slavery in Cambodia, ចូលមើលថ្ងៃទី ០៥/០៦/២០១៧,http://www.globalslaveryindex.org/country/combodia/។

[15] International Organization for Migration (IOM), Trafficking of Fishermen in Thailand(2011), ទំព័រទី២០។

២០ម៉ោង មិនមានពេលសម្រាកគ្រប់គ្រាន់។ លើសពីនេះទៀតការញុំា អាហារ និងសំរានរបស់ពួកគេ តែពេលណាដែលសំណាញ់បានទម្លាក់ចូលក្នុងទឹកវិញ និងធ្វើការបែងចែកត្រីទៅតាមប្រភេទៗរបស់វារួច។ សម្រាប់ថ្ងៃខ្លះវិញមិនបានដេកប៉ុន្មានទេ ដោយសារតែនេសាទបានត្រីច្រើនហើយត្រូវរៀបចំដាក់កន្លែងដែលត្រឹមត្រូវទៅតាមប្រភេទៗរបស់វា។[16] មានប្រជាជនកម្ពុជាច្រើនដែលកំពុងធ្លាក់ខ្លួនចាញ់បោកពីការងារទាំងនេះ បើតាមរបាយការណ៍របស់អង្គការ ILO ចុះផ្សាយក្នុងឆ្នាំ ២០១៣ គឺមានចំនួន ៩% នៃអ្នកនេសាទកម្ពុជាដែលជាកម្មវត្ថុសម្រាប់ការងារដោយបង្ខំ។[17]

ចំណែកឯការងារជាកម្មករកាត់ដេរវិញ ពួកគាត់ក៏ប្រឈមទៅនឹងការងារទៅដោយបង្ខំគ្រប់រូបភាព។ ដោយសារតែតម្រូវការរបស់រោងចក្រនូវសម្លៀកបំពាក់ដើម្បីនាំចេញគឺធ្វើឲ្យនិយោជកមួយចំនួនបង្ខំកម្មករឲ្យធ្វើការបន្ថែមម៉ោង បើពួកគាត់មិនព្រមទេនិយោជកនិងយកជាហេតុផលដើម្បី បណ្តេញចេញ ឬកាត់ប្រាក់ខែ ឬបំលែងការងារទទួលប្រាក់ខែទៅជាការងារដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណនៃផលិតផលទៅវិញ។ កម្មកររោងចក្រកាត់ដេរមានចំនួនច្រើនណាស់ប្រហែលជា ៦០០,០០០ទៅ ៧០០,០០០ ជិត ៥ភាគរយនៃប្រជាជនសរុប ហើយភាគច្រើននៃពួកគេមកពីទីជនបទដែលអាចងាយរងគ្រោះពីការរំលោភបំពានដោយសារតែកត្តាចំណេះដឹង។[18]

នៅក្នុងសង្គមបច្ចុប្បន្នការបម្រើការងារនៅក្នុងផ្ទះមានលក្ខណៈជាទ្រង់ទ្រាយធំ ប៉ុន្តែយើងមិនដែលដឹងពីភាពលំបាករបស់ពួកគេយ៉ាងម៉េចនោះទេ ភាគច្រើនពួកគេរងគ្រោះតាមរយៈការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ឬអំពើហិង្សាផ្លូវភេទជាដើម។ នៅប្រទេសអ្នកមានមួយចំនួនគឺ ត្រូវការមនុស្សបម្រើក្នុងផ្ទះដែលមានតម្លៃថោកដូចជានៅអាស៊ីកណ្តាល ប្រទេសម៉ាឡេស៊ី សិង្ហបុរីជាដើម ដែលជាហេតុដែលធ្វើឲ្យប្រទេសទាំងនោះក្លាយទៅជាគោលដៅរបស់អ្នកជួញដូរ។ ក្រៅពីនាំយកទៅក្រៅបរទេស តម្រូវការរបស់អ្នកមានមួយចំនួននៅក្នុងស្រុកក៏មានផងដែរ ដូចជានៅភ្នំពេញជាដើម។ របាយការណ៍នៃការស្ទង់មតិរបស់អង្គការ Walk Free បានបង្ហាញថាប្រជាជន ដែលត្រូវបានបង្ខំឲ្យធ្វើការងារមានប្រហែល ២០១,០០០នាក់ក្នុងនោះ ៥% ត្រូវបានកេងប្រវ័ញ្ចន៍ឲ្យធ្វើនៅក្នុងផ្ទះ។ ការងាររបស់ពួកគាត់ដូចជា ជាអ្នកបម្រើ ជាអ្នកមើលថៃក្មេងៗ ឬរបរផ្សេងៗជាច្រើនទៀត។

### ខ. ការបញ្ចាំខ្លួនដោះបំណុល

[16] International Organization for Migration (IOM), Trafficking of Fishermen in Thailand(2011), ទំព័រទី២៧ និង២៨។

[17] ILO,Employment practice and working condition in Thailand fishing sector, (2013) ចូលមើលថ្ងៃទី 05/06/2017: http//www.ILo.org/dyn/migpractice/does/184/Fishing.pdf

[18] The Global Slavery Index, Haw many people are in modern slavery in Cambodia, ចូលមើលថ្ងៃទី ០៥/០៦/២០១៧,http://www.globalslaveryindex.org/country/combodia/។

នៅក្នុងកំណត់ពន្យល់មាត្រានីមួយៗ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានផ្តល់និយមន័យនៃការបញ្ចាំខ្លួនដោះបំណុលថា "ជាប្រព័ន្ធមួយដែលជនណាម្នាក់បញ្ចាំខ្លួនបម្រើគេ ឬស្ថិតក្រោមការគ្រប់គ្រងរបស់ជនណាម្នាក់ទៀត ដែលជនរងគ្រោះមិនអាចសងបំណុលពិតដែលខ្លួនបានជំពាក់"។ មានន័យថាជារូបភាពដែលជនល្មើសបានកេងប្រវ័ញ្ចន៍ ទៅលើជនរងគ្រោះដោយខុសច្បាប់ ដើម្បីឲ្យបំណុលរបស់ជនរងគ្រោះកាន់តែកើនឡើងៗ មិនអាចមានលទ្ធភាពសងគ្រប់ តាមរយៈការតម្លើងការប្រាក់ ឬតាមរយៈការគំរាមកំហែងណាមួយក្នុងគោលបំណងរក្សាគ្រប់គ្រងជនរងគ្រោះ ធ្វើការនៅកន្លែងខ្លួនបានជារៀងរហូត។

កត្តាដែលឲ្យជនរងគ្រោះជំពាក់ម្ចាស់បំណុលកាន់តែច្រើនឡើងៗ ពីព្រោះតំបូងឡើយពួកគេជួបប្រទះទៅនឹងបញ្ហាដូចជា ឈឺថ្កាត់ គ្មានលទ្ធភាពទិញគ្រាប់ពូជដើម្បីធ្វើស្រែ ឬសត្វពាហនៈជាដើម។ រូបភាពខ្លះទៀតពួកគាត់ភាគច្រើន បានផ្តើមខ្ចីប្រាក់ពីធានាគា ឬអ្នកផ្តល់ប្រាក់កម្ចីផ្សេងទៀតនៅតាមមូលដ្ឋាន។ នៅពេលគាត់មិនមានលទ្ធភាពសងប្រាក់នោះវិញ ពួកគាត់ត្រូវផ្ទេរបំណុលរបស់ពួកគាត់ទៅឲ្យជនល្មើសដើម្បី សងជូនហើយសន្យាថានឹងធ្វើអ្វីមួយតបទៅវិញ។

ជាក់ស្តែងតាមរយៈរបាយការណ៍របស់អង្គការលីកាដូ LICADHO លើសិប្បកម្ម ឡឥដ្ឋបានបង្ហាញនូវករណីបញ្ចាំខ្លួនដោះបំណុលនេះ។ ដំបូងឡើយពួកគាត់ធ្លាក់ខ្លួនជំពាក់ម្ចាស់សិប្បកម្មដោយសារតែពួកគាត់ត្រូវទូទាត់ចំពោះថ្លៃចំណាយលើការព្យាបាល ដែលបណ្តាលមកពីការមានផ្ទៃពោះ ឬឈឺថ្កាត់នៅក្នុងគ្រួសារ។ ពួកគាត់មួយចំនួនទៀត បានខ្ចីប្រាក់យកទៅទិញគ្រាប់ពូជ ឬសត្វពាហនៈ ហើយគ្មានលទ្ធភាពសងវិញដោយសារតែទទួលលទ្ធផលមិនល្អ។ នៅពេលដែលមិនមានលទ្ធភាពសងក៏ទៅធ្វើការដើម្បីកាត់បំណុល ការងាររបស់ពួកគាត់មិនត្រូវបានគិតជាប្រាក់ខែនោះទេ តែគេគិតទៅតាមចំនួននៃផលិទ្ធផល ដែលជាធម្មតាក្នុងមួយថ្ងៃទទួលបានពី២.៥$ ទៅ១០$ តែប៉ុណ្ណោះ។ នៅរដូវវស្សាពួកគាត់ទទួលបានតិចតួចបំផុត ដោយសារតែមិនមានកំដៅថ្ងៃហាលឥដ្ឋឲ្យបានស្ងួតទាន់ពេលវេលា ដែលជាហេតុនាំឲ្យចំនួននៃផលិតផលកាន់តែធ្លាក់ចុះ និងកម្រៃទទួលបានតិចតួច។ កត្តាបែបនេះហើយធ្វើឲ្យគាត់ជំពាក់ម្ចាស់បំណុលសិប្បកម្មបន្ថែមទៀតក្នុងការទ្រទ្រង់ជីវភាព ដែលធ្វើឲ្យបំណុលរបស់ពួកគាត់មានការកើនឡើងៗ កាន់តែច្រើន។ ឧទាហរណ៍៖ ស្ត្រីម្នាក់បានលើកឡើងថា ម្ចាស់សិប្បកម្មរបស់គាត់បានទិញអង្ករទម្ងន់ ១០គីឡូក្រាមហើយលក់ទៅឲ្យពួកគាត់ក្នុងតម្លៃដុំ ប៉ុន្តែថ្លៃទិញអង្ករនេះត្រូវបានបូកបញ្ចូលបន្ថែមទៅក្នុងចំនួនប្រាក់ដែលពួកគាត់បាន

ជំពាក់ម្ចាស់សិប្បកម្មនោះ។[19] ពេលវេលាច្រើនខែ ច្រើនឆ្នាំ បំណុលកាន់តែច្រើន ហើយលទ្ធភាពនៃការសងបំណុលមានកាន់តែតិចទៅៗ។ ដូចនេះធ្វើឲ្យពួកគេមិនអាចចេញពីទីកន្លែងនោះបានដោយងាយនោះទេ រាល់ពេលដែលចង់ចេញម្ចាស់សិប្បកម្មព្រមានថានឹងប៉ូលីសឲ្យចាប់ដាក់គុក បើមិនសងប្រាក់ទាំងនោះ។ បើសិនជាមិនមានអន្តរាគមន៍ទេ ពួកគេនឹងប្រឈមបញ្ហានេះជារៀងរហូត។

**គ. ពលកម្មកុមារ**

ពលកម្មកុមារជាពលកម្មធ្វើឡើងដោយអនីតិជន និងត្រូវបានហាមឃាត់ដោយច្បាប់។ នៅក្នុងច្បាប់ការងារឆ្នាំ១៩៩៧ កថាខណ្ឌទី ១,២និងទី៤មានចែងថាៈ

១ អាយុអប្បបរមាអាចចូលធ្វើការ ជាកម្មករនិយោជិកត្រូវបានកំណត់ត្រឹមដប់ប្រាំឆ្នាំ។

២ អាយុអប្បបរមារបស់កម្មករនិយោកជិត ត្រូវបានកំណត់ដល់ដប់ប្រាំបីឆ្នាំ ចំពោះមុខរបរ ឬ ការងារគ្រប់ប្រភេទដែលអាចនិងធ្វើឲ្យខូចសុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សពេញជំទង់ ដោយតែលក្ខខណ្ឌឬប្រភេទរបស់មុខរបរ និងការងារទាំងនោះបង្កឡើង។

៣ ដោយមិនគិតដល់បទបញ្ញត្តិទាំងឡាយនៃកថាខណ្ឌទី ៩ខាងលើក្មេងដែលមានអាយុពីដប់ពីរដល់ដប់ប្រាំឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលៗក្នុងលក្ខខណ្ឌដូចតទៅៈ

ក. ការងារទាំងនោះមិនបណ្តាលឲ្យខូចសុខភាព ឬការអភិវឌ្ឍនៃចិត្តនិងកាយរបស់កុមារ។

ខ. ការងារទាំងនោះមិនបណ្តាលឲ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់, ការចូលរួមក្នុងកម្មវិធីតំរង់ទិស ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្មេងៗកម្ពុជាជាច្រើនត្រូវបានជួញដូរ ក្នុងគោលបំណងដើម្បីធ្វើការងារដោយផ្ទុយពីបញ្ញត្តិខាងលើ។ ក្មេងៗខ្លះត្រូវបានបញ្ជូនទៅ ឲ្យសុំទាននៅទីក្រុងក្នុងស្រុក រីឯខ្លះទៀតត្រូវបានបញ្ជូនទៅប្រទេសជិតខាងដូចជា ថៃ វៀតណាមជាដើម។ ជាពិសេសនៅប្រទេសថៃមានក្មេងៗកម្ពុជា៨0% ក្នុងចំណោមក្មេងៗដែលកំពុងសុំទាននៅទីនោះ។[20] ដោយឡែកនៅប្រទេសវៀតណាមក្មេងៗកម្ពុជាត្រូវបានគេរកឃើញថា គេបង្ខំឲ្យសុំទាន ឬលក់ផ្កាជាដើម។ មានករណីជាក់ស្តែងជនរងគ្រោះម្នាក់ត្រូវបានសំភាសដោយបានប្រាប់ថា "គាត់ត្រូវបានគេជួញដូរទៅប្រទេសវៀតណាម និងត្រូវបាន

[19] LICADHO, «ការអភិវឌ្ឍន៍លើទាសភាព"ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឡដុតនៅកម្ពុជា», (ភ្នំពេញៈ២០១៦), ៥។

[20] The Global Slavery Index, Haw many people are in modern slavery in Cambodia, ចូលមើលថ្ងៃទី ០៥/០៦/២០១៧,http://www.globalslaveryindex.org/country/combodia/។

បង្ខំឲ្យសុំទាន និងលក់ផ្កាអស់រយៈពេល៦ខែ។ ជនល្មើសមានភាពលោភលន់ចង់បានលុយចូលច្រើន ម្លោះហើយទើបបង្ខំនាង និងមិនឲ្យបាយហូបគ្រប់គ្រាន់ដើម្បីឲ្យគេឃើញ និងអាណិត។ ជារៀងរាល់ថ្ងៃនាងត្រូវបានបង្ខំឲ្យសុំទានចាប់ពីម៉ោង៥ ព្រឹក រហូតដល់ពេលយប់។[21]

ដោយឡែកកុមារនៅក្នុងស្រុកមួយចំនួនដែលមានអាយុក្រោម១៥ឆ្នាំ កំពុងធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋជាកន្លែងដែលត្រូវប្រើប្រាស់ពលកម្មធ្ងន់ៗ ជាហេតុនាំឲ្យពួកគេជួបនូវការលំបាក និងប៉ះពាល់ដល់សុខភាព ក៏ដូចជាភាពលូតលាស់របស់ក្មេង។ ការងារដែលក្មេងៗទាំងនោះធ្វើនៅក្នុងឡឥដ្ឋមាន ការប្រើពូថៅ និងប៉ែលដើម្បីជីកឥដ្ឋពីពំនូកដី ការលើកដីឥដ្ឋដាក់ចូលក្នុងម៉ាស៊ីនផលិតឥដ្ឋ តូចធំ ដឹកឥដ្ឋនឹងរទេះឈើតូច ឬត្រាក់ទ័រ ហាលឥដ្ឋក្រោមកម្តៅថ្ងៃ ដឹកឥដ្ឋដែលហាលរួចយកទៅដាក់ក្នុងឡឥដ្ឋ ពុសអុសសម្រាប់ដុតក្នុងឡ បិតមាត់ឡជាមួយនឹងដីឥដ្ឋ និងជញ្ជូនឥដ្ឋចេញពីឡទៅដាក់ក្នុងរថយន្តជាដើម។ មានកុមារម្នាក់បានលើកឡើងថា គាត់ក្រោកពីគេងនៅម៉ោង៣ព្រឹកជារៀងរាល់ថ្ងៃដើម្បីជីកដី ការធ្វើបែបនេះគាត់នឹងអាចបញ្ចប់ ការងារដែលត្រូវប្រើកម្លាំងកាយខ្លាំងមុនពេលថ្ងៃក្តៅខ្លាំង។[22] លើសពីនេះទៅទៀតមិនត្រឹមតែពួកគាត់ប្រឈមទៅនឹងការងារធ្ងន់ធ្ងរលើសកម្លាំងនោះទេ ក្មេងៗទាំងនោះក៏ប្រឈមទៅនឹងគ្រោះថ្នាក់ ប៉ះពាល់ដល់រាងកាយផងដែរ ដោយសារតែកន្លែងសិប្បកម្មឡឥដ្ឋប្រើប្រាស់ទៅដោយម៉ាស៊ីន និងឧបករណ៍ធនធ្ងន់។ អង្គការលីកាដូបានរកឃើញថា មានករណី៣ ដែលកុមារដាច់ដៃដោយម៉ាស៊ីនផលិតឥដ្ឋ។ មួយករណីក្នុងចំណោមនោះ ក្មេងប្រុសអាយុ៩ឆ្នាំដែលកំពុងធ្វើការដាក់ដីចូលក្នុងម៉ាស៊ីន ហើយបានជួបគ្រោះថ្នាក់ដល់ពិការ។[23]

បើសិនជាមិនមានចំណាត់ការ អន្តរគមន៍ពីស្ថាប័នពាក់ព័ន្ធទេនោះពួកគេនឹងប្រឈមបញ្ហាទាំងនេះជាដរាប។

### ឃ. រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈជនរងគ្រោះ

ការជួញដូរ ដែលមានគោលដៅនាំយកជនរងគ្រោះដើម្បីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ មានន័យថាជាអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយអវត្តមាននូវការស្ម័គ្រចិត្តពីជនរងគ្រោះ ឬខ្លួនមិន

---

[21] Neth Naro, Humen Traficking in Cambodia: Reintegration of Cambodia illegal migrants from Vietnam and Thailand (Singapor,2009), 18 ។

[22] LICADHO,ការអភិវឌ្ឍន៍លើទាសភាព" ការមញ្ជាខ្លួនដោយបំណុល និងពលកម្មនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" (ភ្នំពេញ ២០១៦),ទំព័រទី៩។

[23] LICADHO,ការអភិវឌ្ឍន៍លើទាសភាព" ការមញ្ជាខ្លួនដោយបំណុល និងពលកម្មនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" (ភ្នំពេញ ២០១៦),ទំព័រទី១៥។

មានមនោសញ្ចេតនាជាមួយនឹងគូស្រករបស់ខ្លួន។ សកម្មភាពនេះកើតឡើងតាមរយៈរូបភាពជាការសន្យាថានាំយកដើម្បីផ្តល់ការងារល្អៗមានប្រាក់ខែច្រើន តែបែជាបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនមិនស្រលាញ់ ពេលទៅដល់គោលដៅ ឬជនល្មើសសន្យាថានាំយកទៅរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តែបែជារៀបអាពាហ៍ពិពាហ៍ជាមួយនឹងមនុស្សដែលពិការផ្នែកស្មារតី ឬរាងកាយជាដើម។ ទិសដៅនៃការជួញដូរដើម្បីបង្ខំរៀបអាពាហ៍ពិពាហ៍ភាគច្រើនត្រូវបាននាំយកទៅប្រទេសចិន ពីព្រោះប្រទេសនេះប្រកាន់យកនូវគោលការណ៍កូនតែមួយ ដែលធ្វើឲ្យជួបប្រទះនូវកង្វះមនុស្សស្រីដើម្បីបន្តពូជពង្ស។ បើយោងតាម The Chinese Academy of Social Sciences បានគណនានូវអត្រាផលធៀបរវៀងបុរសនិងស្ត្រី មានគម្លាតខុសៗគ្នា ដែលស្ត្រី មានជិត១០០នាក់ខណៈពេលដែលបុរសមាន១២៥នាក់ ដែលបានកើតនៅចន្លោះពីឆ្នាំ ២០០០ ដល់ឆ្នាំ២០០៤ និងជាប្រទេសដែលមានភាពមិនស្មើគ្នានៃភេទ ដែលខ្ពស់ជាងគេបំផុតក្នុងចំណោមប្រទេសផ្សេងទៀតក្នុងពិភពលោក។ ការសិក្សានេះបានបន្តទៀតថាចំនួនមនុស្សប្រុសដែលនឹងគ្រប់អាយុរៀបអាពាហ៍ពិពាហ៍និងមានចំនួនលើសលុបពី ៣០ទៅ ៤០លាននាក់មុនឆ្នាំ២០២០ នៅប្រទេសនេះ។[24] ដូចច្នេះហើយតម្រូវការស្ត្រីដែលនិងត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវបានជួញដូរពីប្រទេសក្រីក្រមួយចំនួនដូចជា កម្ពុជា មីយ៉ានម៉ា ឬ វៀតណាមជាដើម។

ការធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះកម្ពុជាពីការជួញដូរក្នុងគោលដៅរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈមកកាន់កម្ពុជាវិញក្នុងឆ្នាំ២០១៣ មានចំនួនស្ត្រី២១នាក់ ក្នុងឆ្នាំ២០១៤ ស្ត្រីមានចំនួន៥៨នាក់ និងឆ្នាំ២០១៥ មានចំនួនស្ត្រី៨៥នាក់។[25] ជនរងគ្រោះទាំងនោះភាគច្រើនមកពីខេត្ត កំពង់ចាម កំពង់ធំ និងខេត្តកណ្តាល។[26]

ប្រតិបត្តិការរបស់អ្នកជួញដូរមានពីដំណាក់កាល ក្នុងនោះដំណាក់នៅក្នុងប្រទេសសកម្ពុជា និងនៅប្រទេសចិន។

អ្នកជួញដូរនៅកម្ពុជា ស្លៀកពាក់បែបអ្នកមាន ហ៊ឺហា បំពាក់ទៅដោយខ្សែកខ្សែដៃ ដើម្បីចុះទៅតាមភូមិក្រីក្រ ឬ ទៅបញ្ចុះបញ្ចូលកម្មការនីនៅតាមរោងចក្រជាដើម។ ស្ត្រីរងគ្រោះភាគច្រើន ឮដំណឹង

[24] United Nations Action For Cooperation against Trafficking in Persons, HUMAN TRAFFICKING VULNERABILITIES IN ASIA, a study on forced marriage between Cambodia and China ( បាងកក៖ ២០១៦),១។

[25] United Nations Action For Cooperation against Trafficking in Persons, HUMAN TRAFFICKING VULNERABILITIES IN ASIA, a study on forced marriage between Cambodia and China ( បាងកក៖ ២០១៦),២។

[26] The Global Slavery Index, How many people are in modern slavery in Cambodia , ចូលមើលថ្ងៃទី ០៥/០៦/២០១៧ http://www.globalslaveryindex.org/country/Cambodia/ ។

ថារៀបការជាមួយជនជាតិចិន ហើយបានទៅរស់នៅប្រទេស និងឆាប់មានបានជាងរកស៊ីនៅកម្ពុជា ដែលដំណឹងនេះឮតៗគ្នា ពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ ឬធ្លាប់ស្គាល់មេខ្យល់ដែលធ្លាប់នាំមនុស្ស ទៅចិនរាប់មិនអស់ ហើយមិនបញ្ហាអ្វីកើតឡើងនោះទេ។ មេខ្យល់ទាំងនោះបានផ្តល់ពត៌មានទាក់ទាញចិត្តទៅដល់ស្ត្រីរងគ្រោះទាំងនោះ ដោយពន្យល់ពីស្ត្រីជាច្រើន ដែលត្រលប់មកវិញមានទាំងគ្រឿងអលង្កា មានលុយសាងសង់ផ្ទះនៅស្រុក និងទ្រព្យសម្បត្តិផ្សេងៗទៀត។ មេខ្យល់ខ្លះទៀតក៏បានបង្ហាញរូបថតបុរស ដែលនឹងអាចរៀបការជាមួយជាច្រើនដែលជាហេតុធ្វើឲ្យកាន់តែមានភាពទាក់ទាញ។ ក្រោយពីបានព្រមព្រៀងគ្នា មេខ្យល់ផ្តល់នូវប្រាក់មួយចំនួនទៅដល់ស្ត្រីរងគ្រោះទាំងនោះ ក្នុងគោលបំណងជ្រើសរើសនាំយកចេញ ក៏ប៉ុន្តែពួកគេប្រាប់ទៅកាន់ស្ត្រីរងគ្រោះថាជាប្រាក់បណ្តាការ ឬជាប្រាក់ខែបើកឲ្យមុន ឬជាប្រាក់សម្រាប់ត្រៀមរៀបចំមុនពេលចាកចេញទៅប្រទេសចិន។ ដូចជាករណីដែលនារីរងគ្រោះម្នាក់ បានលើកឡើងថា៖

> បុរសម្នាក់មិនបានឲ្យខ្ញុំទៅចំណាយលើលិខិតឆ្លងដែន និងសំបុត្រយន្តហោះនោះទេ តែថែមទាំងគាត់ឲ្យប្រាក់ខ្ញុំចំនួន ១,០០០$ សម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំនឹងត្រូវកាត់ប្រាក់ទាំងនោះវិញពីប្រាក់ខែរបស់ខ្ញុំពេលទៅបំពេញការងារនៅប្រទេសចិន។ បើសិនជាខ្ញុំផ្លាស់ប្តូរចិត្ត ខ្ញុំនឹងមានកាតព្វកិច្ចត្រូវសងវិញចំនួន ២,៥០០$។[27]

ជាការពិតណាស់ស្ត្រីរងគ្រោះទាំងអស់ មិនដំណើរការ ធ្វើលិខិតឆ្លងដែន ឬទិញសំបុត្រយន្តហោះដោយខ្លួនឯងនោះទេ។ ពួកគេគឺទទួលនូវឯកសារទាំងនោះនៅថ្ងៃដែលចេញដំណើរ។ ពេលទៅដល់អាកាសយានដ្ឋាន ពួកគេបែរជាជួបជាមួយនឹងមនុស្សមិនស្គាល់មុខទៅវិញ ដែលនាំផ្លូវពួកគេដើម្បីចូលពិនិត្យឡើងយន្តហោះ ហើយបានប្រាប់ពួកគេថា បើសិនជាមានអ្នកសួរ ត្រូវឆ្លើយថាទៅទស្សនកិច្ចនៅទីនោះ។ នៅពេលដែលទៅដល់ប្រទេសចិនពួកគេត្រូវបាន បញ្ជូនដោយជនមិនស្គាល់មុខទៅកាន់ទីជនបទ ដាច់ស្រយាលដោយមធ្យោបាយផ្សេង។ ភាគច្រើនដែលជនរងគ្រោះត្រូវបានគេបង្ខំឲ្យទៅរៀបអាពាហ៍ពិពាហ៍ ឬបើមិនដូច្នេះទេនឹងត្រូវសងប្រាក់ដែលបានចំណាយទាំងអស់មកវិញ ឬជនល្មើសបានដកហូតឯកសារស្របច្បាប់ទាំងអស់ហើយ គម្រាមថានឹងប្តឹងទៅនគរបាលឲ្យចាប់ខ្លួនការស្នាក់នៅដោយខុសច្បាប់។ ដោយសារតែមិនមានជម្រើសស្ត្រីទាំងអស់នោះក៏បង្ខំខ្លួនរៀបអាពាហ៍ពិពាហ៍។ បុរសដែលនិងត្រូវរៀបអាពាហ៍ពិពាហ៍ភាគច្រើនមិនសូវមានលក្ខណៈគ្រប់គ្រាន់

---

[27] United Nations Action For Cooperation against Trafficking in Persons, HUMAN TRAFFICKING VULNERABILITIES IN ASIA, a study on forced marriage between Cambodia and China ( បាងកក៖ ២០១៦),១០ ។

ខ្លះពិការផ្នែករៀងកាយ ខ្លះពិការផ្នែកបញ្ញាស្មារតីជាដើម។ ខ្ញុំសូមលើកយកករណីសិក្សាដែលជនរងគ្រោះ បានប្រឈមទៅនឹងការលំបាកដែលត្រូវបានជួញដូរក្នុងគោលដៅយកទៅរៀបអាពាហ៍ពិពាហ៍នៅប្រទេសចិនះ

> នៅអាកាសយានដ្ឋានកម្ពុជា ខ្ញុំបានជួបនារីក្មេងៗ៩នាក់ ដែលនឹងចាកចេញទៅជាមួយខ្ញុំ ពួកយើងទទួលបានលិខិតឆ្លងដែន និងសំបុត្រយន្តហោះរៀងខ្លួននៅទីនោះតែម្តង។ បន្ទាប់ពីពួកយើងបានត្រួតពិនិត្យឡើង ( check in) រួចពួកយើងត្រូវបាននាំដោយបុរសផ្សេងទៀតដែលខ្ញុំមិនស្គាល់មុខទៅកាន់កន្លែងត្រួតពិនិត្យលិខិតឆ្លងដែន និងនាំចេញ។ ពួកយើងបានចូលចតនៅប៉េកាំង ហើយត្រូវបាននាំយកចេញទៅដោយបុរសម្នាក់ទៅកាន់ខេត្តមួយចំនួន។ យើងត្រូវបានដាក់ក្នុងផ្ទះសំណាក់មួយអស់រយៈ២ ទៅ ៣យប់ ក្រោយមកត្រូវបានគេបំបែកទៅជាក្រុមតូចៗ ធ្វើដំណើរទៅទិសដៅផ្សេងៗគ្នា។ ពីរ បីម៉ោងក្រោយមកឡានបានឈប់ ហើយបុរសមិនស្គាល់មុខ ៣នាក់ផ្សេងទៀតកំពុងរងចាំនៅចិញ្ចើមផ្លូវ។ ហើយខ្ញុំក៏បានធ្វើដំណើរបន្តទៅជាមួយជនមិនស្គាល់មុខទាំងនោះដោយឡានរបស់ពួកវា ខ្ញុំសួរពួកគេដោយភាសាខ្មែរថា តើនាំខ្ញុំទៅណា ហើយខ្ញុំនិងធ្វើការងារអ្វី ? ប៉ុន្តែ មិនមានចម្លើយត្រូវបានឆ្លើយនោះទេ ព្រោះពួកគេជាជនជាតិចិន។ [28]

## ផ្នែកទី៣ ចំណាត់ការរបស់អ្នកជួញដូរទៅលើជនរងគ្រោះ

### កថាខណ្ឌទី១ កត្តាឈានចូលអន្ទាក់ជនល្មើស

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលធ្លាក់ខ្លួនចូលក្នុងកណ្តាប់ដៃរបស់អ្នកជួញដូរដោយសារកត្តាពីរយ៉ាង គឺ កត្តាដែលជម្រុញ និង កត្តាទាញជនរងគ្រោះ។ កត្តាជម្រុញជាកត្តាដែលនាំឲ្យជនរងគ្រោះចាកចេញពីទីលំនៅរបស់គេទៅកាន់ទីកន្លែងផ្សេងៗ ពីគ្នាដើម្បីស្វែងរកលក្ខខណ្ឌជីវភាពរស់នៅដែលប្រសើរ។ កត្តាជម្រុញទាំងនោះមានដូចជា ភាពគ្មានការងារធ្វើ ខ្វះសន្តិសុខសុវត្ថិភាព ការដាំដុះមិនអំណោយផល គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ភាពក្រីក្រ និងសង្គ្រាមជាដើម។ កាលណាជនរងគ្រោះជួបប្រទះ និងបញ្ហាទាំងនេះធ្វើឲ្យអ្នកជួញដូរមានគំនិតដើម្បីបង្កើតជាភាពទាក់ទាញដល់ជនរងគ្រោះ។ អ្វីដែលជាភាពទាក់ទាញដល់ពួកគេគឺ ជនល្មើសសន្យា នឹងផ្តល់លក្ខខណ្ឌជីវភាពប្រសើរដល់ពួកគេដែលហៅថាជាកត្តាទាញ ក្នុងនោះរួមមាន ការងារដែលមានសក្តានុពល បរិយាកាសដែលមានសុវត្ថិភាព ការដាំដុះដែលមានជីវជាត ការផ្តល់អាហារគ្រប់គ្រាន់ ការរួចផុតពីគ្រោះថ្នាក់ធម្មជាតិ ផ្តល់នូវប្រាក់កាសទ្រព្យសម្បត្តិមានតម្លៃ និងសន្តិភាពគ្មានសង្គ្រាមជាដើម។

[28] United Nations Action For Cooperation against Trafficking in Persons, HUMAN TRAFFICKING VULNERABILITIES PN ASIA, a study on fored marriage between Cambodia and China ( បាងកក៖ ២០១៦),១២។

**ក កត្តាជម្រុញជនរងគ្រោះ**

កត្តាជម្រុញដែលចម្បងគឺ ភាពក្រីក្រ ដែលជាកត្តាសំខាន់ដែលធ្វើឲ្យ ស្រ្តីនិងក្មេងៗ ជាច្រើនងាយទទួលរងគ្រោះដោយអំពើជួញដូរមនុស្ស។ បើយោងតាមសម្តីរបស់លោក Vijghen និង Jironimous (2007) បានថ្លែងប្រហាក់ប្រហែលគ្នាថា «ដោយសារការអប់រំ បំណុលគ្រួសារ ការដាំដោះមិនអំណោយផល គ្មានដីធ្វើកសិកម្មគ្រប់គ្រាន់ បានជម្រុញឲ្យប្រជាជនទៅកាន់ទីក្រុង ឬទៅប្រទេសផ្សេងៗទៀត ដែលបុរសធ្វើជាកម្មករសំណង់ រីឯនារីវិញធ្វើការបម្រើសេវា ឬធ្វើជាពេស្យាចារជាដើម។

សម្រាប់ក្រុមគ្រួសារខ្លះដើម្បីចង់មានចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ ក៏សម្រេចចិត្តទៅខ្ចីលុយពីឈ្មួញ ក្នុងអត្រាការប្រាក់ខ្ពស់។ ប៉ុន្តែចំនូលពីការដាំដុះ របស់គេមិនអាចយកទៅសងបំណុលបានទេ ដែលជាហេតុចុងក្រោយពួកគេត្រូវបង្ខំឲ្យលក់ អចលនវត្ថុរបស់គេ។ ជីវភាពរបស់ជនរងគ្រោះមុនត្រូវបានជួញដូរៈ ៨% ជីវភាពមធ្យម, ៤០% ទីទាល់ក្រ និង៥២% ស្ថិតក្នុងជីវភាពក្រីក្រ។[29]

ករណីសិក្សាៈ ខ្ញុំមានអាយុ១៥ឆ្នាំ មកពីគ្រួសារក្រីក្រមួយក្នុងភូមិ Chan Theaខ្ញុំមានបងប្អូនស្រី ៤នាក់ និងប្រុស៣នាក់ ម្តាយរបស់ខ្ញុំជាអ្នកលក់ត្រី ឪពុករបស់ខ្ញុំជាកសិករ។ នៅក្នុងភូមិរបស់ខ្ញុំពិតជាលំបាកខ្លាំងណាស់ក្នុងការប្រកបរបររកស៊ី ពីព្រោះដីរាំងស្ងួតនៅខែក្តៅ ហើយទឹកជំនន់នៅខែធ្លាក់ភ្លៀង។ ដោយសារតែគ្រួសារខ្ញុំទីទាល់ក្រ ឪពុកម្តាយរបស់ខ្ញុំក៏បានសម្រេចចិត្តជួញដូរខ្ញុំទៅឲ្យឈ្មួញ ក្នុងគោលបំណងជាថ្នូរសម្រាប់បានលុយជាប្រចាំខែ។ រឿងនេះបានកើតឡើងតាំងពីខ្ញុំរៀនថ្នាក់ទី៥។ ខ្ញុំពេញចិត្តការសិក្សារ និងសង្ឃឹមថានឹងមានឱកាសគ្រប់គ្រាន់ទៅសាលាជាមួយមិត្តរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាច។ ខ្ញុំត្រូវបាននាំយកចេញឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងធ្វើការជាអ្នកលក់ផ្កា និងសុំទាននៅប្រទេសវៀតណាម។[30]

**ខ. កត្តាទាញជនរងគ្រោះ**

ដោយសារតែកត្តាក្រីក្រនេះហើយ ទើបនាំឲ្យជនរងគ្រោះខិតខំស្វែងរកការងារដែលមានចំណូលច្រើន។ នៅពេលដែលឮគេនិយាយថា មានទីកន្លែងដែលអាចប្រកបមុខរបរ មានប្រាក់ខែច្រើនក៏ទៅតាមគេដោយមិនមានការត្រិះរិះពិចារណានូវផលវិបាកនោះទេ។ នេះហើយគឺជាវិធីដែលជនល្មើសប្រើដើម្បីសម្រេចនូវគោលបំណងជួញដូរមនុស្ស។ ក្រៅពីភាពក្រីក្រក៏មានកត្តាទាញបន្ទាប់បន្សំផ្សេងៗ

---

[29] Neth Naro, Human Trafficking in Cambodia Reintegration of Cambodian illegal Migrom ts from Vietnam and Thailand (Singapore, 2009), 12 ។

[30] Neth Naro, Human Trafficking in Cambodia Reintegration of Cambodian illegal Migrom ts from Vietnam and Thailand (Singapore, 2009), 12 ។

ទៀតដូចជា កាងារដែលមានសក្ដានុពល បរិយាកាសដែលមានសុវត្ថភាព ដីមានជីជាតសម្រាប់ដាំដុះ ការផ្ដល់អាហារគ្រប់គ្រាន់ ការរួចផុតពីគ្រោះថ្នាក់ធម្មជាតិ ផ្ដល់នូវប្រាក់កាសទ្រព្យសម្បត្តិមានតម្លៃ និងសន្តិភាពគ្មានសង្គ្រាម។ល។

**កថាខណ្ឌទី២ វិធីនៃការរក្សាទុកជនរងគ្រោះដោយជនល្មើស**

ការរក្សាទុកជនរងគ្រោះគឺជាអ្វីដែលអ្នកជួញដូរត្រូវគិត ពីព្រោះបើសិនជាមានការដឹងឮដល់សមត្ថកិច្ច ច្បាស់ណាស់ពួកគេនិងត្រូវប្រឈមការផ្ដន្ទាទោស ហើយម៉្យាងទៀតគេក៏ត្រូវខាតបង់នូវដើមទន់ដែល ចំណាយទៅលើការវិនិយោគមួយនេះ។ ម្លោះហើយគេត្រូវរិះរកគ្រប់វិធីបែបយ៉ាងដើម្បីរក្សាជនរងគ្រោះក្នុងកណ្ដាប់ដៃរបស់ពួកគេ។ ដោយលែកជនរងគ្រោះក៏មិនស្វែងរកវិធីដើម្បីគេចចេញដែរ សំនួរចោទឡើងថាហេតុអ្វីទើបជនរងគ្រោះមិនព្យាយាមរកគេចពីការកេងប្រវ័ញ្ចន៍? មូលហេតុគឺដោយសារតែជនល្មើសប្រើនូវវិធីជាច្រើនដូចខាងក្រោម[31]៖

**ក ការកាត់ផ្ដាច់នូវទំនាក់ទំនង**

. **ការឃុំខ្លួន** ជនរងគ្រោះត្រូវបានចាក់សោរទុកនៅកន្លែងស្ងាត់ ជាពិសេសប្រព្រឹត្តទៅលើជនរងគ្រោះណាដែលទើបតែត្រូវបានកេងប្រវ័ញ្ចន៍ថ្មីៗ។

. **ការដកនូវឯកសារផ្លូវច្បាប់** ជនរងគ្រោះត្រូវបានគេដកនូវឯកសារកំណត់អត្តសញ្ញាណទាំងអស់ដែល ជាហេតុធ្វើឲ្យពួកគេលំបានកនឹងទទួលការជួយសង្គ្រោះនៅក្រៅប្រទេស។ នេះជាមូលហេតុដែលពួកគេមិនអាចស្វែងរកអ្នកជួយបាន ដោយសារតែខ្លាចប៉ូលីសអន្ដោប្រវេសន៍ចាប់ឃុំខ្លួននឹងដោះស្រាយតាមនីតិវិធីច្បាប់។

. **បញ្ចៀសពីមន្ត្រីមានសមត្ថកិច្ច** ជនល្មើសតែងតែប្រាប់ទៅកាន់ជនរងគ្រោះថា បើសិនទៅកាន់ប៉ូលីសដើម្បីរកជំនួយ ហើយនិងបញ្ជូនជនរងគ្រោះត្រឡប់ទៅប្រទេសវិញ នោះជនរងគ្រោះឬគ្រួសាររបស់ជនរងគ្រោះ នឹងត្រូវធ្វើទារុណកម្មដោយជនល្មើស។ ឬជនល្មើសប្រាប់ទៅកាន់ជនរងគ្រោះថាមន្ត្រីប៉ូលីសពាក់ព័ន្ធបានទទួលសំណូកពីពួកគេរួចហើយ ដូចនេះជនរងគ្រោះមិនមានផ្លូវនឹងអាចសង្គ្រោះបានទេ។

. **ភាសា និងសង្គម** ជនរងគ្រោះត្រូវបានគេរក្សាទុកនៅកន្លែងដោយឡែកពីមនុស្សទូទៅ ( ជនដែលមិនត្រូវបានជួញដូរ) ដែលមានភាសាដូចគ្នា នឹងមនុស្សដែលយល់ដឹងពីវប្បធម៌របស់ជនរងគ្រោះ។

[31] International Organization for Migration (IOM), Human Trafficking is a modern day form of slavery, 22-24 ។

. **ការបំលាស់ទី** ជនរងគ្រោះត្រូវបានគេធ្វើការបំលាស់ទីពី កន្លែងមួយទៅកាន់កន្លែងមួយទៀតក្នុងរយៈពេលពី ៣ទៅ៤ ខែ ពីព្រោះបញ្ចៀសពួកគេពីភាពសាំនៅក្នុងសង្គម ឬស្គាល់អាជ្ញាធរមានសមត្ថកិច្ចជាដើម។ ជាពិសេសគឺជនរងគ្រោះដោយការកេងប្រវ័ញ្ចន៍ផ្លូវភេទត្រូវបានគេបញ្ជូនជារឿយៗ ទៅកាន់ប្រទេសផ្សេងៗ ។

### ខ. ការប្រើប្រាស់អំពើហិង្សា និងការគម្រាមកំហែង

. **ការប្រើប្រាស់អំពើហិង្សា** វិធីនេះត្រូវបានប្រើប្រាស់នៅពេលដែលជនរងគ្រោះ រឹងទទឹងមិនស្តាប់សំដីរបស់ជនល្មើស។ នៅពេលដែលជនល្មើសពិបាកគ្រប់គ្រង ពួកគេតែងតែវាយតប់ ឲ្យប្រើប្រាស់គ្រឿងញៀន បង្អត់ទឹង បង្អត់អាហារ ឬចាប់រំលោភសេពសន្ថវៈជាដើម ដើម្បីឲ្យជនរងគ្រោះបាក់កម្លាំងមិនអាចមានសមត្ថភាពតបត ឬរត់គេចបាន។

. **ការគម្រាមកំហែង** ជាធម្មតាជនរងគ្រោះស្ថិតនៅក្នុងកណ្តាប់ដៃជនល្មើស រួចទៅហើយ ប៉ុន្តែប្រសិនបើជនរងគ្រោះចង់រត់គេច ឬ ប្តឹងទៅមន្ត្រីមានសមត្ថកិច្ច ពួកគេត្រូវបានគម្រាមថានឹងធ្វើបាប ឬ សម្លាប់ មនុស្សជាទីស្រលាញ់របស់ជនរងគ្រោះដូចជា កូន ឪពុកម្តាយ ក្រុមគ្រួសារជាដើម។ ពីព្រោះថាពត៌មានទាំងឡាយអំពីជីវប្រវត្តិ ឬអាស័យដ្ឋានរបស់អ្នកដែលជាទីស្រឡាញ់របស់ជនរងគ្រោះ ត្រូវបាលស្គាល់យ៉ាងច្បាស់នៅពេលជ្រើសរើស។

### គ. ការប្រើប្រាស់គ្រឿងញៀន

ការបង្ខំឲ្យជនរងគ្រោះប្រើប្រាសគ្រឿងញៀន វាជារឿងធម្មតាទៅហើយ ពីព្រោះដើម្បីគ្រប់គ្រងជនរងគ្រោះបាន និងងាយស្រួលបញ្ជា ជនល្មើសតែងតែបង្ខំឲ្យប្រើប្រាស់ថ្នាំញៀន។ ក្រោយពីជនរងគ្រោះសាំទៅនឹងភាពញៀនហើយ ជនល្មើសចាប់ផ្តើមធ្វើការចែកចាយកាន់តែទូលាយទៅៗ រហូតដល់ដំណាក់ការដែលពួកគេអាចគ្រប់គ្រង និងបញ្ជាបានតាមចិត្ត។

### ឃ. ការបង្កើនបំណុល និងការធ្វើឲ្យអាម៉ាស់ដល់ក្រុមគ្រួសារ

. **ការបង្កើនបំណុល** ជនរងគ្រោះនៃការជួញដូរត្រូវបានទាមទាឲ្យសងនូវតម្លៃដែលបានចំណាយលើការធ្វើដំណើរ កន្លែងស្នាក់នៅ ឬកន្លែងការងារជាដើម។ ជាធម្មតាតម្លៃដែលត្រូវបានទាមទារទាំងនោះលើសលុបពីសមត្ថភាពដែលអាចសងវិញ ហើយត្រូវបង្ខំឲ្យធ្វើការងារដើម្បីសងវិញ ។ ជាពិសេសនោះនៅពេលដែលជនរងគ្រោះត្រូវបានជួញដូរទៅកន្លែងផ្សេងទៀត ឬ ទៅកាន់មនុស្សដ៏ទៃទៀត អ្នកទទួលថ្មីបែជាប្រាប់ជនរងគ្រោះថា ត្រូវតែធ្វើការដើម្បីសងនូវតម្លៃដែលខ្លួនបានចំណាយលើការទិញមកនេះ។ តើវាលំបាកយ៉ាងណាទៅ? តើអាចមានថ្ងៃនឹង មានសេរីភាព

ដូចមនុស្សដ៏ទៃវិញ បានដោយរបៀបណា? ទុកលំបាករបស់ជនរងគ្រោះ នៃអំពើជួញដូរមនុស្សគ្រាន់តែធ្ងន់ទៅៗ ណាមួយពួកគាត់មិនមានចំណេះដឹង ណាមួយស្ថិតនៅក្រោមការគាបសង្កត់។

. **ការធ្វើឲ្យអាម៉ាស់ដល់ក្រុមគ្រួសារ** វិធីនេះភាគច្រើនធ្វើឡើងនៅពេលដែលជនរងគ្រោះមានការពាក់ព័ន្ធទៅនឹង ការកេងប្រវ័ញ្ចន៍ផ្លូវភេទ។ ជនរងគ្រោះដឹងថាក្រុមគ្រួសារនឹងទទួលភាពអាម៉ាស់ នៅពេលគេប្រាប់ទៅក្រុមគ្រួសារគាត់ថា ខ្លួនជាស្ត្រីពេស្យា ឬក៏គម្រាមហែកកេរ្តិ៍ដោយផ្តល់ ឬចាក់ផ្សាយនូវរូបភាព និងវិឌីអូ អាសអាភាសរបស់ខ្លួនទៅទី សាធារណៈ ឬទៅកាន់ក្រុមគ្រួសារ។ សម្រាប់ក្រុមគ្រួសារខ្លះនៅកម្ពុជា ឬវប្បធម៌ប្រពៃណីខ្លះ នឹងបដិសេធមិនទទួលស្គាល់ជនរងគ្រោះនៃការកេងប្រវ័ញ្ចន៍ផ្លូវភេទ ប្រសិនបើអាក្រាតទាំងឡាយរបស់គេត្រូវបានបញ្ចេញ។

## ផ្នែកទី៤ ផលប៉ះពាល់ និងជួយសង្គ្រោះជនរងគ្រោះ

### កថាខណ្ឌទី១ ផលប៉ះពាល់ទៅលើជនរងគ្រោះ

ពិតណាស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានប្រឈមនិងទុកលំបាកវេទនាមិនអាចពិពណ៌នាបាន ការរងទុកវេទនានេះហើយធ្វើឲ្យជនរងគ្រោះ ដែលមានបំណងត្រូវបានសង្គ្រោះពីកណ្តាប់ដៃជនល្មើសនោះ បានបន្សល់ទុកនូវផលលំបាកជាច្រើនដល់ខ្លួនប្រាណនិងផ្លូវចិត្តរបស់ពួកគេ។ ផលប៉ះពាល់ជាច្រើនបានកើតមានលើជនរងគ្រោះរួមមាន៖

#### ក. សុខភាព

ផលប៉ះពាល់ទៅលើសុខភាព ដែលចម្បងនោះគឺ ការផ្ទុកនូវជម្ងឺអេដស៍ពីព្រោះជនរងគ្រោះភាគច្រើនជាស្ត្រីនិង កុមារហើយត្រូវបានជួញដូរផ្លូវភេទ ពីកន្លែងមួយទៅកន្លែងមួយ។ នៅពេលដែលមានជនរងគ្រោះម្នាក់បានផ្ទុកមេរោគអេដស៍(AIDS) នេះរួចហើយប្រសិនបើទៅរួមភេទជាមួយជនដ៏ទៃ វានឹងបញ្ជូនមេរោគនេះបន្តៗរហូតដល់ប្រពន្ធ កូនរបស់អ្នកទទួលសេវាជាដើម។ ម្លោះហើយទើបឃើញថា ជម្ងឺអេដស៍ មិនត្រូវបានផ្ទុកត្រឹមតែទៅលើជនរងគ្រោះនៃអំពើជួញដូរនោះទេ សូម្បីតែមនុស្សទូទៅដែលមានដៃគូជាច្រើនទៀត។

ក្រៅពីជម្ងឺអេដស៍មានបញ្ហាសុខភាពប្រឈមជាច្រើនទៀតរួមមានការរងរបួស បញ្ហាបង្អាក់ការលូតលាស់ បញ្ហាខួរក្បាល ( រួមមានការបាក់ទឹកចិត្ត, ការភ័យខ្លាច, គេឬជំងឺ បាកស្បាតជាដើម), ពិការ ឬ បាក់ឆ្អឹងជាដើម។

#### ខ. បាត់បង់ធនធានមនុស្ស

ការបាត់បង់ធនធានមនុស្សពីអំពើជួញដូរមនុស្ស នៅត្រង់ថាក្រោយពីពួកគេទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពដូចដែលបានរៀបរាប់ខាងលើ ដូចនេះពួកគាត់មិនអាចធ្វើអ្វីបាននៅក្នុងសង្គម ក្រៅពីសំរាកទទួលការព្យាបាល។ មួយចំនួនច្រើននៃជនរងគ្រោះកាលនាត្រូវបានជួញដូរច្បាស់ណាស់នឹង ត្រូវធ្វើការចំណាកស្រុក ដែលជាហេតុបាត់បង់កម្លាំងពលកម្មក្នុងស្រុក។

### គ. សិទ្ធិរបស់ជនរងគ្រោះ

សិទ្ធិមនុស្សត្រូវបានបាត់បង់ នឹងរំលោភបំពានដោយសារតែសកម្មភាពឃោឃៅរបស់ជនល្មើសនៅពេលធ្វើការជួញដូរដូចជាការដាក់នៅទីកន្លែងងងឹត ឬចាក់សោជិតក្នុងឡានធនធំពេលដឹកជញ្ជូនពីទីកន្លែងមួយទៅកន្លែងមួយ។ លើសពីនេះទៅទៀតសម្រាប់កម្មករដែលត្រូវធ្វើកាងារដោយបង្ខំវិញតម្រូវឲ្យធ្វើនៅកសិកម្ម ដែលមានគ្រោះថ្នាក់ រោងចក្រកាត់ដេរ ឬក៏ជាកម្មករសំណង់។ សម្រាប់កម្មករខ្លះទៀតត្រូវបង្ខំឲ្យឈរនៅកន្លែងតួនាទីរបស់ខ្លួនពេញមួយថ្ងៃ ឬធ្វើការនៅកន្លែងមានពន្លឺតិច ឬកន្លែងដែលមានធូលីពិបាកដកដង្ហើមចេញចូល។ លើសពីនេះទៅទៀតពួកគេត្រូវបានបំបែកចេញពីក្រុមគ្រួសារ មិនបញ្ជូនទៅកាន់តំបន់ឆ្ងាយផ្សេងទៀត ជាពិសេសទៅកាន់ប្រទេសដែលមិនចេះនិយាយភាសាដូចខ្លួន ជាហេតុធ្វើឲ្យពួកគេ ឯកោយ៉ាងខ្លាំង។

### ឃ. ប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ

សម្រាប់សង្គមណាក៏ដោយ ជាពិសេសប្រពៃណីក្នុងសង្គមកម្ពុជាបានរក្សាតម្លៃស្ត្រីខ្ពង់ខ្ពស់។ ជនរងគ្រោះដែលត្រូវបានជួញដូរផ្លូវភេទ គឺមានការអាម៉ាស់មិនហ៊ានត្រលប់ចូលក្នុងសមគន៍របស់ខ្លួនវិញ ពីព្រោះខ្លាចប៉ះពាល់កិត្តិយស និងតម្លៃនៃសេចក្តីថ្លៃថ្នូរដល់ក្រុមគ្រួសាររបស់ខ្លួនជាដើម។ ចំណែកឯជនរងគ្រោះដោយពលកម្មដោយបង្ខំវិញមានការអាម៉ាសនៅពេលដែល ការងារពុំទទួលបានជោគជ័យជាពិសេស មិនមានប្រាក់ដើម្បីផ្ញើមកកាន់ក្រុមគ្រួសាររបស់គេ។

## កថាខណ្ឌទី២ ការជួយសង្គ្រោះលើជនរងគ្រោះ

### ក. និដ្ឋភាពនៃការជួយសង្គ្រោះ

ជនរងគ្រោះនៃអំពើជួញដូរមនុស្សពិតជាត្រូវការសប្បុរសជន ដើម្បីខ្វាយខ្វល់ពីការជួយសង្គ្រោះពួកគេ និងទទួលបាននូវជីវិតមួយថ្មីដែលល្អប្រសើរ មានសុភមង្គលដូចកាលពីមុនត្រូវបានជួញដូរ។ ពួកគេពិតជាចង់ត្រឡប់ទៅកាន់ដើមកំណើតរបស់គេ គ្មានការគាបសង្កត់ ជួបជុំគ្រួសារ និងមានសេរីភាព ដូចនេះការធ្វើមាតុភូមិនិវត្តន៍ គឺដើតួនាទីយ៉ាងសំខាន់នៅក្នុងការជួយសង្គ្រោះជនរងគ្រោះ។

ការធ្វើមាតុភូមិនិវត្តន៍ មានសារៈសំខាន់នៅក្នុងការបញ្ជូនជនរងគ្រោះឲ្យជួបជុំ នូវក្រុមគ្រួសាររបស់គេវិញ រស់នៅក្នុងសហគមន៍ដើម មានការងារធ្វើ មានការអប់រំជាដើម។ ការធានាបាននូវតំរូវការរបស់ជនរងគ្រោះក្រោយពីវិលត្រលប់មកវិញគឺជាបន្ទុករបស់ស្ថាប័នដែលពាក់ព័ន្ធ។ ដោយសារតែវាមិនគ្រប់គ្រាន់នោះទេសម្រាប់ពួកគាត់ត្រឹមតែមកជួបជុំក្រុមគ្រួសារ និងភូមិស្រុក លើសពីនេះទៅទៀតជនរងគ្រោះ ត្រូវបានទទួលនូវអ្វីដែលចាំបាច់ដូចខាងក្រោម[32]៖

- ការពារនូវភាពអាម៉ាស់ ឬការមាក់ងាយពីសាធារណៈជន ដោយផ្តល់ឱកាសឲ្យពួកគេបង្ហាញពីការខ្មាយខ្វល់ជាសាធារណៈ
- សម្រាប់កុមារៗ វិញគឺចាំបាច់ផ្តល់ការអប់រំដល់ពួកគេ
- ការផ្តល់ការងារឲ្យធ្វើ
- ការជួយផ្នែកផ្លូវច្បាប់ដើម្បីឲ្យជនរងគ្រោះទទួលបានយុត្តិធម៌ និងបង្ក្រាបការជួញដូរមនុស្ស
- ការផ្តល់នូវថ្នាំសង្កូវ និងការថែទាំសុខភាព
- សេវាសង្គមដើម្បីការពារជនរងគ្រោះពីការភ័យខ្លាចនូវស្នាមអតីតកាល
- ត្រូវមានសេវាកម្មជួយសង្គ្រោះផ្នែកផ្លូវចិត្ត នៅពេលនៅពេលដែលមានប្រតិបត្តិការអន្តរាគមន៍បឋមដើម្បីការពារនូវជនរងគ្រោះណាដែលត្រូវបានរំលោភបំពាន អារម្មណ៍តានតឹង បាក់ទឹកចិត្តជាដើម។

លើសពីនេះទៅទៀតប្រសិនបើជនរងគ្រោះត្រូវបានជួយសង្គ្រោះ យើងមិនត្រូវធ្វើឲ្យពួកគេឈឺចាប់បន្ថែមទៀតឡើយ។ នេះជាដំណាក់កាលដំបូងបំផុតដែលយើងត្រូវធ្វើក្រោយពីជួយសង្គ្រោះនោះគឺការមិនរំលោភបំពាន បន្ថែមទៅលើពួកនោះឡើយ ពីព្រោះក្នុងអំឡុងពេលដែលត្រូវបានជួញដូរពួកគេទទួលរងនូវការលំបាកធ្ងៃតធ្ងន់ណាស់ទៅហើយ។ ក្រៅពីការមិនរំលោភបំពាន អ្នកជួយសង្គ្រោះត្រូវធ្វើនូវរឿងមួយចំនួនទៀតដូចខាងក្រោម៖

**គោរព និងការពារសិទ្ធិមនុស្ស** បទល្មើសជួញដូរមនុស្សគឺជាបទល្មើសដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត។ រាល់ពេលនៃការជួយសង្គ្រោះ គឺត្រូវព្យាយាមផ្តល់សិទ្ធិពេញលេញសម្រាប់ពួកគេ។

**ការមិនរើសអើង** មិនត្រូវមានការរើសអើងចំពោះការផ្តល់ សេវាទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះទេ ទោះបីមានភេទខុសគ្នា អាយុ ពិការ ពណ៌សម្បុរ វណ្ណៈ សង្គម ពូជសាស

[32] The Asia Foundation

សាសនា ភាសា ជំនឿនយោបាយ ឬកាលៈទេសៈផ្សេងទៀត។ ការរើសអើងធ្វើឲ្យពួកគេមិនទទួលបាននូវភាពកក់ក្តៅគ្រប់គ្រាន់ និងធ្វើឲ្យពួកគេជួបប្រទះទៅនឹងបញ្ហាផ្លូវចិត្តផងដែរ។

**រក្សាការសម្ងាត់ និងសិទ្ធិឯកជនរបស់ជនរងគ្រោះ** គ្រប់ពត៌មានទាំងអស់ដែលទាក់ទងទៅនឹងការសម្ងាត់ ឬភាពឯកជនរបស់ជនរងគ្រោះត្រូវតែធ្វើការរក្សាជាសម្ងាត់ លើកលែងតែពត៌មានណាដែលមានការចាំបាច់បំផុតប៉ុណ្ណោះ។ បុគ្គលិកដែលធ្វើការពាក់ព័ន្ធជាមួយនឹងពត៌មានជនរងគ្រោះត្រូវដឹងថាពួកគេនឹងជួបការប្រថុយប្រថានទៅដល់ជីវិតរបស់ខ្លួន និងអ្នកដ៏ទៃ (ក្រុមគ្រួសា ជាដើម) ប្រសិនបើពត៌មានណាត្រូវបានផ្សព្វផ្សាយ។

**ការសម្រេចចិត្តដោយខ្លួនឯង និងការចូលរួម** ជនរងគ្រោះគួរតែត្រូវបានផ្តល់កម្លាំងចិត្តដើម្បីឲ្យស្គាល់ ពីខ្លួនឯងកាន់តែច្បាស់ និងមានការសម្រេចចិត្តដោយខ្លួនឯងប្រកបដោយភាពត្រឹមត្រូវ។ ត្រូវធានាថាពួកគេអាចចូលរួមបាននៅក្នុងកិច្ចការនានាក្នុងសង្គម។

**កុំធ្វើឲ្យពួកគេជួបការអាម៉ាស់ម្តងទៀត** មានន័យថាកុំចោទសួរនូវសំនួរណាដែលធ្វើឲ្យចាក់ទៅដល់សតិអារម្មណ៍របស់ពួកគេ ឬយករឿងដែលកើតឡើងចំពោះជនរងគ្រោះទៅនិយាយតៗគ្នាជាដើម។

### ខ. ការជួយសង្គ្រោះដោយស្ថាប័នជាតិ[33]

ស្ថាប័នជាតិ មានតួនាទីយ៉ាងសំខាន់នៅក្នុងការជួយសង្គ្រោះឲ្យរួចផុតពីវិបត្តិទាំងឡាយកើតចេញពីការជួញដូរមនុស្ស។ មានក្រសួងចំនួនពីរដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជនរងគ្រោះតាមរយៈការធ្វើសមាហរណកម្ម។ ក្រសួងទាំងនោះរួមមាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងក្រសួងកិច្ចការនារីផងដែរ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (តទៅនេះហៅកាត់ថា MoSAVYR) ដោយមានការគាំទ្រពីអង្គការអន្តោប្រវេសន៍អន្តរជាតិដើម្បីធ្វើការទៅលើការការពារ ក្នុងគោលដៅកំណត់អត្តសញ្ញាណជនរងគ្រោះ ជួយសង្គ្រោះ ធ្វើមាតុភូមិនិវត្តន៍ដែលមានសុវត្ថិភាព ធ្វើសមាហរណកម្ម និងផ្តល់កន្លែងនីតិសម្បទា ប្រកបទៅដោយជំនាញមានថ្នាំពេទ្យជំនួយ ជំនួយផ្នែកច្បាប់ ការអប់រំ និងការឈប់សម្រាកហ្វឹកហាត់ជាដើម។ លើសពីនេះទៅទៀតក្រសួងក៏បានរៀបចំឲ្យជនរងគ្រោះដែលវិលត្រលប់មកវិញមានការងារធ្វើ និងជួបជុំក្រុមគ្រួសាររបស់គេវិញ។ តើ

[33] Neth Naro, Human Trafficking in Cambodia: Reintegration of Cambodia illegal Migrants from Vietnam and Thailand (Sinagapore, 2009), 31-33។

ក្រសួងផ្អាកការជួយសង្គ្រោះជនរងគ្រោះនៅពេលណា? ជាការពិតក្រសួងបានខិតខំប្រឹងប្រែងលើកស្ទួយជនរងគ្រោះតាំងពីមុន និងក្រោយពេលដែលទទួលបានពួកគេ។ ក្រសួងបានកំណត់សម្គាល់ថាករណីជួយសង្គ្រោះមួយអាចនឹងត្រូវបានបញ្ឈប់លុះត្រាតែលក្ខខណ្ឌខាងក្រោមនេះត្រូវបានជួបៈ

១. ក្មេងៗ ឬក៏ជងរងគ្រោះ បន្តស្នាក់នៅកន្លែងធ្វើការរបស់មជ្ឈមណ្ឌលបញ្ជូនត្រលប់ជនរងគ្រោះបន្តស្នាក់នៅជាមួយគ្រួសារ សហគមន៍ម្តងទៀត និងទទួលបានការងារធ្វើដែលមានរយៈពេលលើសពីមួយឆ្នាំ។
២. ក្មេងៗ ឬជនរងគ្រោះនោះស្លាប់
៣. ក្រុមគ្រួសារនោះផ្លាស់ប្តូរទៅកាន់ទីកន្លែងណាផ្សេងទៀតដែលមិនអាចទៅជួបបាន
៤. ក្មេង ឬជនរងគ្រោះទាំងឡាយណាដែលរត់គេចពីជំរំ ក្រុមគ្រួសារ ឬសហគមន៍តែប៉ុណ្ណោះ។

នៅក្នុងឆ្នាំ ២០០៧, MOSAVYR បានធ្វើការជាមួយនឹងប្រទេសថៃ និងបានព្រមព្រៀងទៅលើកិច្ចការ ក៏សាងកន្លែងឆ្លងកាត់ ប៉ោយប៉ែត សំរាប់ទទួលជនរងគ្រោះ និងសម្រាប់ឲ្យជនរងគ្រោះស្នាក់នៅបណ្តោះអាសន្ន ដែលធ្វើដំណើរ និងបញ្ជូនពីប្រទេសថៃ។ លើសពីនេះទៅទៀត ក្រសួងក៏បានបង្កើតឲ្យមាននៅក្រុមការងារ ដើម្បីតាមដានជនរងគ្រោះដែលស្នាក់នៅក្នុងជម្រកស្តានីតិសម្បទាផងដែរ។ ក្រសួង និងនាយកដ្ឋានចំណុះតាមខេត្តជារៀយៗប្រព្រឹត្តកិច្ចប្រជុំរៀងរាល់ ពីរខែម្តងជាមួយនឹងភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងគោលបំណងពិភាក្សាអំពីដំណើរការនៃការតាមដាន និងការស្តានីតិសម្បទា។

ចំណែកឯក្រសួងកិច្ចការនារីវិញ (តទៅនេះហៅកាត់ថា MOWA) កំពុងតែធ្វើការនៅក្នុងការការពារជនរងគ្រោះ។ តាមរយៈសកម្មភាពរបស់ខ្លួន ក្រសួងនេះធ្វើការប្រតិបត្តិការឆ្លងកាត់ប្រទេសជាពិសេសតំបន់ណាដែលមានប្រភពនៃការកើតឡើង អំពើជួញដូរមនុស្សតែម្តង។ ប្រតិបត្តិការសកម្មភាពរបស់ក្រសួងមានដូចជា យុទ្ធនាការលើកកំពស់ការយល់ដឹងពីអំពើជួញដូរមនុស្ស និងចំណាកស្រុកដែលមានសុវត្ថិភាព ការអប់រំ ការបង្កើនសមត្ថភាពបង្កើតបណ្តាញការពារកុមារ ការលុបបំបាត់ភាពក្រីក្រ និងគម្រោងប្រតិកម្មមហន្តរាយ។ លើសពីនេះទៅទៀតដើម្បីពង្រឹងផ្នែកច្បាប់ និងពង្រឹងសេវាជួយសង្គ្រោះជនរងគ្រោះនៃអំពើជួញ ដូរមនុស្សនៅក្នុងតំបន់ MOWA ព្យាយាមបង្កើតច្បាប់ គោលនយោបាយ កិច្ចព្រមព្រៀងជាទ្វេ និងពហុភាគីជាមួយនឹងបណ្តាប្រទេសជាច្រើន។ តាមរយៈគម្រោងទាំងនេះ ក្រសួងទទួលជំនួយពី USAID និងក្រសួងការបរទេសប្រទេសហ្វាំងឡង់។

សកម្មភាពរបស់ក្រសួងតាមរយៈជំនួយពី អង្គការអន្តោប្រវេសន៍អន្តរជាតិ ក្រសួងបានបំពេញនូវកិច្ចការជាច្រើន ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស ជាពិសេសក្រសួងបាយជួយក្រុមគ្រួសារចំនួន ២៧១ គ្រួសារមកពី ១០ភូមិ ក្នុងខេត្តស្វាយរៀង ដែលជាខេត្តងាយទទួលរងគ្រោះអំពើ

ជួញដូរមនុស្ស។ នៅក្នុងខេត្តបន្ទាយមានជ័យ ក្រសួងបានផ្តល់ជំនួយចំនួន ១០ភូមិ មកពីស្រុកសីរីសោភ័ណ្ឌ និងស្រុកអូរជ្រៅផងដែរ។

### គ. ការជួយសង្គ្រោះដោយអង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលនាពេលបច្ចុប្បន្ន កំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយសង្គ្រោះជនរងគ្រោះក្នុងនាមរដ្ឋាភិបាល ធ្វើការគាំទ្រជនរងគ្រោះនៃអំពើជួញដូរមនុស្សទទួលបាននូវការហ្វឹកហាត់ជំនាញផ្សេងៗ ក៏ដូចជាផ្តល់នូវការងារផងដែរ។ ដូចជាអង្គការទស្សនៈពិភពលោក បានបង្កើតនូវគម្រោងជាច្រើន ក្នុងនោះមានដូចជា គម្រោង Children at High Risk Prevention Project (CHRPP) ដែលធ្វើការងារទៅលើការការពារក្មេងៗពីអំពើហិង្សា ការកេងប្រវ័ញ្ចន៍ និងការរំលោភបំពានផ្លូវភេទតាមរយៈការអប់រំក្នុងសង្គម។ ក្រៅពីនេះក៏មានសកម្មភាពហ្វឹកហាត់ក្មេងៗ ឲ្យមានការអភិវឌ្ឍន៍នូវភាពជាអ្នកដឹកនាំ និងឲ្យដឹងពីការការពារ អំពើជួញដូរមនុស្សសំរាប់កេងប្រវ័ញ្ចន៍ផ្លូវភេទ ឬកេងប្រវ័ញ្ចន៍ពលកម្មជាដើម។[34]

ក្រៅពីនេះមានអង្គការផ្សេងជាច្រើនទៀតដូចជា LICADHO, អង្គការសាសនាគ្រិស្តមានដូចជា Agape International Mission , Faith Alliance Against Slavery and Trafficking -ល- ។ ការងារសំខាន់ៗដែលNGOត្រូវធ្វើមាន៖

- NGO ត្រូវធ្វើការពង្រីកថវិការរបស់ខ្លួនដើម្បីឲ្យបំពេញតម្រូវការចាំបាច់ក្នុងកម្មវិធីវិលត្រលប់របស់ជរងគ្រោះ។ នៅពេលពួកគេត្រលប់មកកាន់មាតុប្រទេសរបស់គេវិញ គឺត្រូវការចាំបាច់នោះការងារដែលសមរម្យ ដូចនេះបើសិនមិនមានថវិការដើម្បីលើកទឹកចិត្ត និងបណ្តុះបណ្តាលទេ នោះគម្រោងនឹងមិនមានការជោគជ័យទេ។

- NGO ត្រូវយល់ច្បាស់ពីតម្រូវការ និងទេពកោសល្យរបស់ជនរងគ្រោះ ដើម្បីធានាឲ្យជនរងគ្រោះពេញចិត្តទៅនឹងការងារដែលត្រូវជំនាញរបស់គេ ហើយម្យ៉ាងវិញទៀតជនរងគ្រោះក៏អាចធ្វើការវិវត្តន៍ បានលឿននូវសមត្ថភាពរបស់គេជាក់លាក់ណាមួយ។ លើសពីនេះទៅទៀត NGO ក៏គួរតែលើកទឹកចិត្តឲ្យជនរងគ្រោះបង្ហាញពីទីកន្លែងធ្វើការណា ឬជំនាញណាដែលខ្លួនគេពេញចិត្តធ្វើ។

- NGO មិនត្រឹមតែផ្តល់ឲ្យជនរងគ្រោះនូវការហ្វឹកហាត់ជំនាញប៉ុន្នោះទេ លើសពីនេះទៅទៀតក៏ត្រូវផ្តល់នូវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗការគ្រប់គ្រងពាណិជ្ជកម្ម និងជំនួញផងដែរ។

[34] World Vision , Traffick report : Camdodia , 3។

# ជំពូកទី២ ចំណាត់ប្រឆាំងទៅនឹងការជួញដូរមនុស្សដោយបទដ្ឋានគតិយុត្ត

## ផ្នែកទី១ បទដ្ឋានគតិយុត្តអន្តរជាតិ

### កថាខណ្ឌទី១ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR)

ប្រជាពលរដ្ឋគ្រប់រូបមិនគិតលើវណ្ណៈ ពណ៌សម្បុ ភេទ អាយុ និន្នាការ ទាំងនៅទូទាំងពិភពលោកត្រូវបានធានានូវសិទ្ធិ និងសេចក្តីថ្លៃថ្នូរតាំងពីកំណើត។ ការមិនអាចរំលោភទៅលើសិទ្ធិមនុស្ស ការឈ្លានពានទៅលើរូបភាពរបស់មនុស្ស និងការបើកសិទ្ធិទូលាយសំរាប់មនុស្សក្នុងការទទួលបានសិទ្ធិ របស់ខ្លួនពីកំណើត និងសេចក្តីថ្លៃថ្នូរ ត្រូវបានទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាច្រើន ជាពិសេស គឺមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

#### ក. សញ្ញាណនៃ ICCPR

បើយោងតាមការយល់ឃើញរបស់រដ្ឋភាគីនៃកតិកាសញ្ញានេះ ក៏ដូចជាស្មារតីរបស់កតិកាសញ្ញានេះផ្ទាល់ ទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស សិទ្ធិស្មើភាពគ្នា និងដែលមិនអាចលក់ដូរ ផ្ទេរ ដកហូតបានរបស់សមាជិកគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាពយុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

កតិកាសញ្ញា ICCPR បានអនុម័ត និងបើកឲ្យចុះហត្ថលេខាឲ្យសច្ចាប័ន និងចូលជាសមាជិកតាមសេចក្តីសម្រេចលេខ ២២០០ A(XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៩៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងចូលជាធរមាននៅថ្ងៃទី ២៣ ខែមិនា ឆ្នាំ១៩៧៦។

#### ខ. បញ្ញត្តិអំពីការបំពានសិទ្ធិមនុស្ស

ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ យើងអាចយល់ច្បាស់ថា អំពើជួញដូរមនុស្សគឺជា ការរំលោភបំពានសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សយ៉ាងមហិមាដែលពិបាកគណនា។ ក្នុងមាត្រា៧ វក្យខណ្ឌទី១ បានចែងថា៖ គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬទណ្ឌកម្មដែលឃោឃៅអមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។

គោលបំណងនៃការជួញដូរមនុស្សមានច្រើនរូបភាព និងប្រើប្រាស់គ្រប់មធ្យោបាយដើម្បីទទួលគ្រប់គ្រង សំរាប់កេងប្រវ័ញ្ចន៍ទៅលើការងារដែលផ្ទុយពីឆន្ទៈជនរងគ្រោះជាដើម។ នៅក្នុងមាត្រា៨ កថាខណ្ឌ ១,២,៣ (ក) ចែងថា៖

១ គ្មានជនណាម្នាក់ជាប់ក្នុងទាសភាពឡើយ។ ទាសភាពនិង ទាសពាណិជ្ជកម្មតាមគ្រប់ទម្រង់ទាំងអស់ត្រូវហាមឃាត់។

២ គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ

៣ (ក) គ្មានជនណាម្នាក់តម្រូវឲ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ។

បើតាមមាត្រានេះ (មាត្រា៨) ឆ្លុះបញ្ចាំងឲ្យឃើញថា ការជួញដូរមនុស្សគឺមានការរំលោភបំពានទៅលើកតិកាសញ្ញានេះពេញទំហឹងតែម្តង។ មូលហេតុហេតុដែលហ៊ានសន្និដ្ឋានបែបនេះព្រោះការប្រើប្រាស់គ្រប់មធ្យោបាយដោយបង្ខិតបង្ខំ និងកេងប្រវ័ញ្ចន៍ឲ្យធ្វើការងារដោយបង្ខំគ្មានពេលសម្រាកចាត់ទុកជនរងគ្រោះជាទាសករ មិនផ្តល់ប្រាក់ឈ្នួល និងមិនមានការស្ម័គ្រចិត្តធ្វើការងារនោះពីកម្មករជាដើម។ ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានគេដកហូតសេរីភាពយ៉ាងខ្លាំង មិនមានសុន្តិសុខ ផ្ទាល់ខ្លួនមានការភ័យខ្លាចនូវទង្វើឃោរឃៅអមនុស្សធម៌។ នៅក្នុងមាត្រា៩ កថាខណ្ឌ១ និង២ នៃច្បាប់នេះបានចែងថា៖

១ ជនគ្រប់រូបមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

២ ជនណាដែលត្រូវចាប់ខ្លួន ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹងនៅពេលចាប់ខ្លួនអំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឲ្យដឹងភ្លាម អំពីការចោទប្រកាន់។

សកម្មភាពខ្លះដែលជនល្មើសប្រព្រឹត្តទៅលើជនរងគ្រោះ ដើម្បីឲ្យជនរងគ្រោះបន្តស្នាក់នៅជាមួយខ្លួន និងបន្តបំពេញតម្រូវការឲ្យខ្លួន ដោយជនល្មើសប្រើវិធីដាក់កាតព្វកិច្ចឲ្យជនរងគ្រោះសងបំណុលស្ថិតនៅក្នុងអត្រាការប្រាក់ខ្ពស់បំផុតដែលមិនអាចទទួលយកបាន។ ប្រសិនបើមិនព្រមបំពេញតម្រូវការឲ្យខ្លួនទេនោះ ជនល្មើសនឹងទារបំណុលពីជនរងគ្រោះ ហើយបើសិនជនរងគ្រោះមិនមានលទ្ធភាពសង ពួកគេនឹងគម្រាមថាចាប់ដាក់ពន្ធធានាគារជាដើម ជម្រើសចុងក្រោយមានតែបន្តបំពេញតួនាទីទៅតាមបញ្ជារបស់ជនល្មើស។ នៅក្នុងមាត្រ១១ នៃច្បាប់នេះបានចែងថា៖

គ្មានជនណាម្នាក់ត្រូវជាប់ពន្ធនាគារ ដោយសារតែខ្លួនពុំអាចបំពេញកាតព្វកិច្ចនៃកិច្ចសន្យានោះឡើយ។

ដូចនេះ មានន័យថា ទោះបីជាមិនបំពេញកាតព្វកិច្ចសងក៏មិនអាចត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែរ។

## កថាខណ្ឌទី២ អង្គការពលកម្មអន្តជាតិ និងពិធីសារនៃអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ

### ក. សញ្ញាណនៃអង្គការពលកម្មអន្តរជាតិ និងពិធីសារ

 **អង្គការពលកម្មអន្តរជាតិ** ហៅកាត់ថា (ILO) គឺជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលធ្វើការដោះស្រាយទៅនឹងបញ្ហាពលកម្ម បញ្ហាស្តង់ដារការងារពលកម្មអន្តរជាតិជាក់លាក់ណាមួយ ធ្វើការការពារសង្គម និងឱកាសការងារទូទៅ។ អង្គការមានសមាជិកចំនួន១៨៧រដ្ឋ ដែលមាន ១៨៦នៃ ១៩៣រដ្ឋ មកពីសមាជិកអង្គការសហប្រជាជាតិ បូកនិង Cook Islands[35] ផងដែរ។ អង្គការនេះមានសកម្មភាពផ្សព្វផ្សាយសន្តិភាពក្នុងចំណោមវណ្ណៈទាំងឡាយ ផ្តល់ការងារសមរម្យ និងយុត្តិធម៌ដល់កម្មករ និងផ្តល់ជាជំនួយផ្នែកបច្ចេកទេសទៅកាន់ប្រជាជាតិស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដ៏ទៃទៀត និងបានទទួលពានរង្វាន់ Nobel ក្នុងឆ្នាំ១៩៦៩។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការនេះមិនមានសិទ្ធិនៅក្នុងការដាក់ទណ្ឌកម្មទៅលើរដ្ឋាភិបាលនៃរដ្ឋសមាជិកនោះទេ តែអាចធ្វើការរិះគន់ជាលាយលក្ខអក្សរ។

 **ពិធីសារនៃអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ** វិញត្រូវបានអនុម័តតាមរយៈការបោះឆ្នោតដែលមានសម្លេងលើសលុប ក្នុងគោលបំណង ដើម្បីបំពេញបន្ថែមនូវអនុសញ្ញាស្តីពីពលកម្មដោយបង្ខំឆ្នាំ ១៩៣០ (លេខ២៩) និងដើម្បីបំពេញបន្ថែមនូវលិខិតគុបករណ៍អន្តរជាតិដែលនៅជាធរមានផ្សេងៗទៀត និងបានចែងជាក់លាក់អំពីការណែនាំផ្លូវក្នុងការប្រើប្រាស់វិធានដែលមានឥទ្ធិពលដើម្បីលុបបំបាត់រាល់ទម្រង់នៃពលកម្មដោយបង្ខំទាំងអស់។[36] បើយោងតាមប្រសាសន៍របស់អគ្គនាយក ILO លោក Guy Ryder បានលើកឡើងថា៖[37]

> ការអនុម័តនូវពិធីសារនេះគឺជា « ផ្លែផ្កានៃសេចក្តីសម្រេចជាក្រុមរបស់យើងដើម្បីបញ្ឈប់នូវភាពស្អប់ខ្ពើម ដែលជះឥទ្ធិពលដល់ការងារក្នុងពិភពលោករបស់យើង និងដើម្បីដោះលែងឲ្យមានសេរីភាពឡើងវិញនូវជនរងគ្រោះចំនួន២១ លាននាក់»។

### ខ. បទប្បញ្ញត្តិអំពីការខារ

[35] Cook Island ស្ថិតនៅសមុទ្របាស៊ីហ្វិកខាងត្បូងដែលមានទំនាក់ទំនងសេរីជាមួយប្រទេស New Zealand ដែលមាន ១៥កោះ និង ដីគោកចំនួន ២៤០ គីឡូម៉ែតការ៉េ។

[36] International Labour Organization, Special Action Programm e to Combat forced Labour,1 ។

[37] International Labour Organization, Special Action Programme to Combat forced Labour,1 ។

ការងារ គឺជាតម្រូវការរបស់មនុស្សគ្រប់ៗរូបដើម្បីទទួលបានចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រកបដោយឆន្ទៈយល់ព្រមធ្វើការងារនោះ។ ទោះបីជាមនុស្សត្រូវការនូវការផ្គត់ផ្គង់ការរស់នៅក៏ពិតមែន ក៏មិនមានន័យថាមនុស្សស្ម័គ្រចិត្តធ្វើការងារទាំងអស់បានទេ ចំពោះការងារខ្លះត្រូវបានគេបង្ខិតបង្ខំឲ្យធ្វើដោយប្រើប្រាស់កម្លាំងលើសពីសមត្ថភាព និងមិនមានការយល់ព្រមឡើយ។ រាល់ទម្រង់នៃពលកម្មដោយបង្ខំ ត្រូវបានហាមឃាត់ដោយអនុសញ្ញាអន្តរជាតិស្តីពីពលកម្មដោយបង្ខិតបង្ខំ។ ពាក្យថាពលកម្មដោយបង្ខំត្រូវបានឲ្យនិយមន័យនៅក្នុងមាត្រា២ កថាខណ្ឌ១ នៃអនុសញ្ញាអន្តរជាតិស្តីពីពលកម្មដោយបង្ខំថា៖

សំរាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថាពលកម្មដោយបង្ខំមានន័យថាជាការងារ ឬសេវាទាំងឡាយណាដែលបង្ខំមនុស្សណាម្នាក់ឲ្យធ្វើការ ក្រោមការគម្រាមកំហែង ការធ្វើទារុណកម្មណាមួយ ហើយដែលបុគ្គលនោះមិនបានផ្តល់នូវឆន្ទៈស្ម័គ្រចិត្តឡើយ។

ដូចនេះការងារប្រភេទណាក៏ដោយ ដែលធ្វើឡើងដោយបង្ខំ និងមិនមានការស្ម័គ្រចិត្តទេនោះត្រូវបានធ្វើការហាមឃាត់ លុបបំបាត់ បង្ក្រាបដោយអាជ្ញាធររបស់រដ្ឋ ដែលជាសមាជិកនៃអង្គការនេះ។ នៅក្នុងមាត្រា១ កថាខណ្ឌ ១ អនុសញ្ញានេះបានចែងថា៖

សមាជិកនីមួយៗរបស់អង្គការពលកម្មអន្តរជាតិដែលបានផ្តល់នូវ សច្ចាប័នទៅលើអនុសញ្ញានេះ ត្រូវធ្វើការធានានូវការបង្ក្រាបការប្រើប្រាស់ពលកម្មដោយបង្ខំគ្រប់ទម្រង់ទាំងអស់ក្នុងរយៈពេលដែលខ្លីដែលអាចធ្វើទៅបាន។

លើសពីនេះទៅទៀតពិធីសារនៃអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ បានកំណត់ថារដ្ឋទាំងឡាយមិនត្រឹមតែចាត់វិធានការបង្ក្រាបប៉ុណ្ណោះទេ និងថែមទាំងចាត់វិធានការប្រសិទ្ធិភាពដើម្បីការពារ និងផ្តល់ឲ្យជនរងគ្រោះនូវការស្តាឡើងវិញ ដូចជាសំណងដែលខូចខាតកន្លងទៅផងដែរ។

ជនរងគ្រោះត្រូវមានការគាំពារ ពីព្រោះជនរងគ្រោះមួយចំនួនត្រូវបានគេបង្ខំឲ្យធ្វើការងារមិនស្របច្បាប់ និងត្រូវបានផ្តន្ទាទោសជាដើម ហេតុនេះទើបពិធីសារនេះបានចែងក្នុងមាត្រា៣និង ៤ កថាខណ្ឌ២៖

វិធានការដែលមានប្រសិទ្ធិភាពត្រូវបានចាត់ឡើងសំរាប់ កំណត់អត្តសញ្ញាណការដោះលែង ការគាំពារ និងស្តានីតិសម្បទាឡើងវិញរបស់ជនរងគ្រោះ។

ការពារជនរងគ្រោះពីការដាក់ទណ្ឌកម្ម នូវសកម្មភាពខុសច្បាប់ដែលពួកគេត្រូវបានគេបង្ខំប្រព្រឹត្តិ។

ក្រៅពីនេះពិធីសារនៃអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ក៏បានចែងអំពីការបង្កាជនរងគ្រោះក្នុងមាត្រា ២ដែលមានខ្លឹមសារដូចតទៅ៖

- ធ្វើការអប់រំ និងផ្តល់ពត៌មានទៅកាន់ជនដែលត្រូវបានពិចារណាថាងាយរងគ្រោះទៅកាន់និយោជក និងផ្សព្វផ្សាយជាសាធារណៈ។
- ធ្វើការពង្រីកនូវការគ្រប់ដណ្តប់ និងការអនុវត្តច្បាប់ដែលពាក់ព័ន្ធទៅកាន់កម្មករទាំងអស់ និងទៅកាន់វិស័យៗជាច្រើនទៀត។
- ពង្រឹងនូវការត្រួតពិនិត្យផ្នែកពលកម្ម និងសេវាកម្មដើម្បីទទួលខុសត្រូវទៅលើការអនុវត្តន៍នូវច្បាប់ទាំងនេះ
- ការការពារពីការរំលោភបំពានទាំងឡាយ ក្នុងអំឡុងពេលដែលដំណើរការនៃការជ្រើសរើស
- ធ្វើការគាំទ្រនូវតម្រូវការផ្នែកច្បាប់ សំរាប់សុវត្ថិភាពចំណីអាហារ (due diligence) ដោយវិស័យរដ្ឋ និងឯកជន
- ធ្វើការដោះស្រាយនូវកត្តាទាំងឡាយ និងបញ្ហាចម្បងៗដែលធ្វើឲ្យមានការប្រថុយខ្ពស់នៅក្នុងពលកម្មដោយបង្ខំ។

## កថាខណ្ឌទី៣ អនុសញ្ញាស្តីពីទាសភាព

### ក. សញ្ញាណនៃអនុសញ្ញាស្តីពីទាសភាព

អនុសញ្ញាស្តីពីទាសភាពត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្ក្រាបនូវទាសភាព និងពាណិជ្ជកម្មលើទាសករ។ អនុសញ្ញានេះត្រូវបានចុះហត្ថលេខានៅទីក្រុងហ្សឺណែវ (Geneva) នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៦ ប៉ុន្តែត្រូវបានធ្វើវិសោធនកម្មដោយពិធីសារ និងចូលជាធរមាននៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៥៣ អនុលោមទៅតាមមាត្រា៣ នៃពិធីសារ (Protocol ) នេះ។

### ខ. បទបញ្ញត្តិអំពីទាសភាព

ដូចដែលបានសិក្សាពីជំពូកទី១ នូវការកេងប្រវ័ញ្ចន៍ទាសភាពលើអ្នកដ៏ទៃគឺកើតឡើងពាសពេញពិភពលោក ដែលជនរងគ្រោះត្រូវបានបំលាស់ទីពីតំបន់មួយទៅតំបន់មួយ និងត្រូវបានបម្រើប្រភេទមនុស្សដែលភាគច្រើនជាអ្នកមាន ឬនៅតាមកន្លែងសិប្បកម្ម ឧស្សាហកម្ម កសិកម្ម-ល-។ បើយោងតាម The Global Slavery Index មនុស្សចំនួន ៤៥.៨លាននាក់ដែលកំពុងស្ថិតនៅក្នុងទាសភាពនាពេលបច្ចុប្បន្ន។[38] បើងយោងតាមអនុសញ្ញាស្តីពីទាសភាពបានផ្តល់និយមន័យក្នុងមាត្រា១ថា៖

[38] ប្រភពពី៖ https://www.globalslaveryindex.org/ ចូលមើលថ្ងៃទី១៥/០៥/២០១៧។

សំរាប់គោលបំណងនៃអនុសញ្ញានេះ តាមនិយមន័យខាងក្រោមត្រូវបានព្រមព្រៀងថា៖

១ ទាសភាពគឺជាឋានៈ ឬលក្ខខណ្ឌរបស់ បុគ្គលម្នាក់ដែលមានលើអ្នកដទៃ តាមរយៈការប្រើប្រាស់អំណាចក្តោបក្តាប់ទៅលើសិទ្ធិរបស់អ្នកដទៃ

២ ពាណិជ្ជកម្មលើទាសកររួមមាន ទង្វើទាំងឡាយណាដែលមានការពាក់ព័ន្ធទៅនឹងការចាប់យក (capture) ការទទួលយក (acquisition) ឬក៏ការចាត់ចែង(disposal) ទៅលើមនុស្សម្នាក់ជាមួយនឹងគោលបំណងដើម្បីឲ្យបុគ្គលនោះ ស្ថិតនៅក្នុងទាសភាព សកម្មភាពទាំងឡាយណាដែលចាត់ចែងដោយលក់ ឬដោយផ្លាស់ប្តូរ នូវទាសករម្នាក់ដែលមានគំនិតចាប់ផ្តើមលក់ ឬក៏ធ្វើការផ្លាស់ប្តូរ ហើយជាទូទៅពាណិជ្ជកម្មលើទាសករនេះឃើញក្នុងរូបភាពនៃការធ្វើពាណិជ្ជកម្ម និងការដឹកជញ្ជូនទាសករ។

នេះគ្រាន់តែចង់បង្ហាញពីការខ្វាយខ្វល់របស់អន្តរជាតិទៅលើការរីករាលដាល នៃទាសភាពសម័យទំនើបនាពេលបច្ចុប្បន្ន ទោះបីជាយ៉ាងណាក៏ដោយ បើគិតមកត្រឹមពេលនេះ (ឆ្នាំ២០១៧) ប្រទេសកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឡើយ។

## កថាខណ្ឌទី៤ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីការបង្ក្រាបការជួញដូរមនុស្ស និង ការកេងប្រវ័ញ្ចន៍នៅលើពេស្យាចារជនដទៃ (ហៅកាត់ CSTPEPO)

### ក. សញ្ញាណនៃ CSTPEPO

អនុសញ្ញានេះត្រូវបានអនុម័តឡើងដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៤៩ និងចូលធរមាន ( came into effect ) នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥១។ រហូតមកដល់ខែធ្នូ ឆ្នាំ២០១៣ មានរដ្ឋចំនួន៨២ ដែលជាភាគីនៃអនុសញ្ញានេះ និងមានរដ្ឋចំនួន១៣ ផ្សេងទៀត បានចុះហត្ថលេខាលើអនុសញ្ញានេះតែមិនបានផ្តល់សច្ចាប័ននៅឡើយ។ ក្នុងនោះក៏មានកម្ពុជាចុះហត្ថលេខាផងដែរ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ តែមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ (គិតត្រឹមខែ មិថុនា ឆ្នាំ ២០១៧)។

### ខ. បទប្បញ្ញត្តិអំពី CSTPEPO

ការបង្កើតឲ្យមានអនុសញ្ញានេះឡើងដើម្បីធ្វើការបង្ក្រាបនូវអំពីអមនុស្សធម៌ ប៉ះពាល់ដល់កិត្តិយសសេក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេសបញ្ញត្តិឲ្យរដ្ឋដែលជាភាគីនៃអនុសញ្ញានេះចាត់វិធានការដាក់ទណ្ឌកម្មទៅកាន់បុគ្គលទាំងឡាយណាដែល រក្សាទុក លួងលោម ឬនាំយកចេញនូវបុគ្គលដទៃ

ក្នុងគោលបំណងដើម្បីធ្វើជា ពេស្យាចារទោះបីជនរងគ្រោះព្រមព្រៀងធ្វើក៏ដោយ។ ដូចដែលមាត្រា១ នៃអនុសញ្ញានេះបានចែងថា៖

> មាត្រា១ ភាគីទាំងឡាយនៃអនុសញ្ញានេះ យល់ព្រមដើម្បីដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែល៖
>
> ១ រក្សាទុក លួងលួម ឬនាំយកចេញ ក្នុងគោលបំណងដើម្បី ធ្វើជាពេស្យាចារ លើបុគ្គលដ៏ទៃទោះបីជាដោយព្រមព្រៀងពីបុគ្គលនោះក៏ដោយ
>
> ២ កេងប្រវ័ញ្ចន៍លើពេស្យាចារជនដ៏ទៃ ទោះបីជាមានការព្រមព្រៀងពីបុគ្គលនោះក៏ដោយ
>
> លើសពីនេះទៅទៀត រដ្ឋភាគីនៃអនុសញ្ញានេះព្រមព្រៀងដើម្បីផ្តន្ទាទោសលើបុគ្គលទាំងឡាយណាដែល៖
>
> ១ រក្សាទុក ឬគ្រប់គ្រង ឬក៏ដឹងថាទទួលនូវហិរញ្ញវត្ថុ ឬរួមចំណែកទទួលហិរញ្ញវត្ថុពីផ្ទះបន
>
> ២ អនុញ្ញាត ឬជួលអគារ ឬក៏កន្លែងផ្សេងទៀត ឬផ្នែកណាមួយក្នុងគោលបំណងដើម្បីឲ្យជនដ៏ទៃធ្វើជាពេស្យាចារ។

ទន្ទឹមនឹងនេះផងដែរ អនុសញ្ញានេះបានបញ្ញត្តិឲ្យមានភ្នាក់ងារពលកម្មដើម្បី ការពារជនរងគ្រោះពីការកេងប្រវ័ញ្ចន៍ផ្សេងៗ នៅពេលដែលពួកគេទាំងនោះត្រូវបានជ្រើសរើស ក្នុងរូបភាពពលកម្ម។ នៅក្នុងមាត្រា២ នៃអនុសញ្ញានេះ (CSTPEPO) បានបញ្ញត្តិថា៖

ភាគីនៃសន្ធិសញ្ញានេះ ប្រសិនបើពួកគេមិនទាន់បានចាត់វិធានការ ពួកគួរតែចាត់វិធានការចាំបាច់សំរាប់ត្រួតពិនិត្យ ភ្នាក់ងារពលកម្មដើម្បីការពារ បុគ្គលទាំងឡាយណាដែលស្វែងរកការងារជាពិសេសស្ត្រី និងកុមារពីការបង្ហាញឲ្យឃើញនូវគ្រោះថ្នាក់ពីពេស្យាកម្ម។

## កថាខណ្ឌទី៥ ពិធីសារប៉ាឡឺម៉ូ

### ក. សញ្ញាណនៃពិធីសារប៉ាឡឺម៉ូ

ពិធីសារប៉ាឡឺម៉ូត្រូវបានអនុម័តឡើងដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០០ និងបានចូលជាធរមាននៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣។ ពិធីសានេះត្រូវបានអនុម័តឲ្យមាន ៣ប្រភេទធំៗគឺ៖

- ពិធីសារស្តីពីការការពារ ការបង្ក្រាប និងការផ្តន្ទាទោស ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

- ពិធីសារស្តីពីការប្រយុទ្ធប្រឆាំងទៅនឹងការត់ពន្ធ ជនអន្តោប្រវេសន៍តាមផ្លូវគោក សមុទ្រ និង អាកាស។
- ពិធីសារស្តីពីការប្រយុទ្ធប្រឆាំងទៅនឹងកម្មន្តសាលខុសច្បាប់ និងការជួញដូរសំរាប់ (firearms), ផ្នែករបស់វា សមាសភាគណាមួយ ឬរំសេវ។

ក៏ប៉ុន្តែនៅក្នុងចំនុចខាងក្រោមខ្ញុំនឹង លើកយកមកពិភាក្សាតែអំពី ពិធីសារស្តីពីការការពារ ការបង្ក្រាប និងការផ្តន្ទាទោសជាពិសេសស្ត្រី និងកុមារតែប៉ុណ្ណោះ ពីព្រោះវាទាក់ទងចម្បងទៅនឹង ប្រធានបទនេះ។ ដោយឡែកពិធីសារប៉ាឡឺម៉ូនេះត្រូវបានចុះហត្ថលេខាដោយព្រះរាជាណាចក្រកម្ពុជា នៅខែធ្នូឆ្នាំ ២០០៣។

### ខ. បទបញ្ញត្តិអំពីការជួញដូរមនុស្ស

ពិធីសារស្តីពីការការពារការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារ និងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស។ មិនតែប៉ុណ្ណោះ ថែមទាំងបង្ការ និងជួយទៅដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាមួយនឹង ការយកចិត្តទុកដាក់ទៅដល់សិទ្ធិរបស់ពួកគេ និងគោលបំណងមួយទៀតនោះ គឺដើម្បីធ្វើការ ផ្សព្វផ្សាយនូវកិច្ចសហប្រតិបត្តិការ រវាងរដ្ឋភាគីទាំងឡាយដើម្បីឲ្យមានជំនួបនូវកម្មវត្ថុទាំងឡាយ។[39]

ដើម្បីស្របទៅនឹងកថាខណ្ឌខាងលើនៃការជួយ ការពារ និងការបង្ការ រដ្ឋទាំងឡាយជាភាគីនៃ ពិធីសារនេះត្រូវធ្វើការនូវរឿងមួយចំនួនដូចខាងក្រោម៖

**□ ការជួយ និងការពារជនរងគ្រោះ**[40]

រដ្ឋភាគីទាំងឡាយ ប្រសិនបើមានករណីជាក់លាក់ណាមួយ ត្រូវតែធ្វើការរក្សាជាសំងាត់ នូវ ភាពជាឯកជនរបស់ជនរងគ្រោះ និងអត្តសញ្ញាណរបស់ពួកគេ កុំឲ្យមានការដឹងឮជាសារធារណៈ ព្រោះវាអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ពួកគេ។ លើសពីនេះទៅទៀតរដ្ឋដែលជាភាគីនីមួយៗ គួរតែធានាបាននូវច្បាប់ជាតិ និងប្រព័ន្ធរដ្ឋបាលរបស់ខ្លួនដើម្បីជួយសម្រួលដល់ជនរងគ្រោះនៃអំពើ ជួញដូរមនុស្ស នូវករណីនីមួយៗតាមរយៈ ធ្វើការផ្តល់ពត៌មានដល់ពួកគេ អំពីពត៌មានទាំងឡាយ

[39] មាត្រា២ (statement of Purpose) នៃពិធីសារស្តីពីការការពារបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្សពិសេសស្ត្រី និង កុមារ។

[40] មាត្រា៦ ( Assistance to and protection of victims of Trafficking in Person ) នៃពិធីសារស្តីពីការការពារបង្ក្រាប នឹងការ ផ្តន្ទាទោសការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ។

ដែលទាក់ទងទៅនឹងប្រព័ន្ធតុលាការ និងនីតិវិធីដំណើរការរដ្ឋបាល។ ក្នុងនោះផងដែរ គួរតែជួយដល់ពួកគេក្នុងការផ្តល់ នូវមតិយោបល់ និងការខ្វាយខ្វល់របស់ជនរងគ្រោះ និងដំណាក់កាលនីតិវិធីតុលាការ រឿងព្រហ្មទណ្ឌ ដល់ពួកគេដើម្បីតបតប្រឆាំងទៅនឹងជនល្មើស។

បន្ថែមលើនេះទៅទៀត រដ្ឋភាគីទាំងឡាយគួរតែពិចារណាអំពីវិធានការសំរាប់អនុវត្តដើម្បីស្តារឡើងវិញនូវ វិបត្តិផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់ជនរងគ្រោះ។ វិធីនៃការចាត់វិធានការអនុវត្តនេះអាចធ្វើឡើងនូវករណីនីមួយៗ ឬមានការសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល ឬអង្គការពាក់ព័ន្ធនានា និងអង្គភាពរបស់សង្គមស៊ីវិលជាដើម។ ការស្តារឡើងវិញនូវវិបត្តិទាំងឡាយរបស់ជនរងគ្រោះរួមមានៈ

- ផ្តល់ផ្ទះស្នាក់នៅសមរម្យ
- ប្រឹក្សា និងផ្តល់ពត៌មានជាក់លាក់ទាក់ទងទៅនឹងសិទ្ធិស្របច្បាប់របស់ពួកគេ ដោយប្រើប្រាស់ភាសាណាដែលជនរងគ្រោះអាចយល់បាន
- ជំនួយផ្នែកថ្នាំពេទ្យ ផ្លូវចិត្ត និងឧបករណ៍ប្រើប្រាស់ផ្សេងទៀត
- ផ្តល់ឱកាសការងារ ការអប់រំ និងការហ្វឹកហាត់។

ទន្ទឹមនឹងនេះ រដ្ឋភាគីទាំងឡាយនៃពិធីសារនេះ គួរតែធានាថាប្រព័ន្ធផ្លូវច្បាប់ជាតិរបស់ខ្លួនមានវិធានការផ្តល់ឲ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សនូវសមត្ថភាព ក្នុងការទទួលបាននូវសំណងទាំងឡាយដែលកើតចេញពីព្យសនកម្មនៅពេលដែលខ្លួនត្រូវបានគេកេងប្រវ័ញ្ចន៍។

**□ ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃអំពើជួញដូរមនុស្ស[41]**

ការធ្វើមាតុភូមិនិវត្តន៍ផ្តល់អត្ថប្រយោជន៍ និងដើរតួនាទីយ៉ាងសំខាន់សម្រាប់ជនរងគ្រោះដើម្បីឲ្យពួកគេជួបជុំគ្រួសារ សាច់ញាតិ និងដើម្បីស្តានីតិសម្បទាឡើងវិញ ដូចនេះរដ្ឋដែលជាភាគីនៃពិធីសារនេះ និងដែលជារដ្ឋផ្តល់សញ្ជាតិឲ្យជនរងគ្រោះ ឬដែលជនរងគ្រោះមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ គួរតែទទួលយកជនរងគ្រោះ និងធ្វើឲ្យមានភាពងាយស្រួលដល់ពួកគេដើម្បីអាចមកដល់មាតុភូមិរបស់គេវិញ។ រដ្ឋដែលមានបន្ទុកទទួលជនរងគ្រោះ មិនត្រូវមានលេស ឬហេតុផលមិនសមរម្យណាមួយ ក្នុងការពន្យាការទទួលជនរងគ្រោះនោះទេ។ ដោយឡែកក្នុងករណីដែលមានរដ្ឋមួយធ្វើការស្នើសុំធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ទៅកាន់រដ្ឋមួយផ្សេងទៀត រដ្ឋដែលត្រូវបានស្នើសុំ

[41] មាត្រា៨ (Repatriation of victims of Trafficking in persons) ពិធីសារស្តីពីការការពារបង្ក្រាប នឹងការផ្តន្ទាទោសការជួញដូរមនុស្សពិសេសស្ត្រី និង កុមារ។

នោះ គួតែបញ្ជាក់ ឬធ្វើការត្រួតពិនិត្យដោយមិនត្រូវមានលេស ឬហេតុផលមិនសមរម្យណាមួយនោះទេ។

នៅក្នុងករណីដែលជនរងគ្រោះនៃអំពើជួញដូរមនុស្សត្រូវបានជនល្មើស ដកហូតនូវឯកសារចាំបាច់របស់ខ្លួននៅក្នុងរដ្ឋដែលជាទិសដៅនៃការជួញដូរ ឬជាឯកសារចាំបាច់របស់ខ្លួនបានបាត់បង់ពោលគឺមិនមានឯកសារសមស្រប (លិខិតឆ្លងដែន) ដែលអាចឲ្យពួកគេវិលត្រលប់មកប្រទេសដើមវិញដូច្នេះតាមការស្នើសុំរបស់រដ្ឋដែលទទួលជនរងគ្រោះ ឯកសារធ្វើដំណើរទាំងឡាយ ឬក៏លិខិតអនុញ្ញាតផ្សេងៗ ទៀតគួរធ្វើការសម្រួលដើម្បីអាចឲ្យជនរងគ្រោះមានលទ្ធភាពនឹងវិលត្រលប់មកប្រទេសរបស់ខ្លួនវិញ។

## ផ្នែកទី២ បទដ្ឋានគតិយុត្តជាតិ

បទដ្ឋានគតិយុត្តជាតិគឺជារនាំងដ៏សំខាន់ដែលអាចធ្វើការចែកខណ្ឌរវាងជនរងគ្រោះ និងជនល្មើសនៃអំពើជួញដូរមនុស្ស មានន័យថាប្រទេសកម្ពុជាមានច្បាប់ និងបទដ្ឋានជាច្រើនដែលអាចជាខែលការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ទោះជាយ៉ាងណាក៏ដោយដោយសារតែការស្រាវជ្រាវនៅមានកម្រិត ខ្ញុំនឹងលើកយកមកបង្ហាញ នូវឋានានុក្រមនៃបទដ្ឋានជាតិចាប់ពីច្បាប់ឡើងទៅក្នុងនោះរួមមាន៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នីតិការងារ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

### កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺច្បាប់កំពូលតែមួយគត់ដែលទទួលស្គាល់នូវសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា មិនអាចធ្វើការរំលោភបំពានបានឡើយ ពីព្រោះថាសិទ្ធិ គឺជាឧបករណ៍សម្រាប់មនុស្សប្រើប្រាស់ជាប្រចាំនៅក្នុងជីវភាពរស់នៅ ប្រសិនបើមានការរំលោភសិទ្ធិនោះ នឹងមានការរើបំរាស់កើតឡើងដូចក្នុងមាត្រា ៣១នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានចែងថា៖

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុញ្ញាទាំងឡាយទាក់ទងទៅនឹង សិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ

ស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដ៏ទៃឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។

អំពើជួញដូរមនុស្សមានការប៉ះពាល់ទៅដល់សិទ្ធិបុគ្គលយ៉ាងខ្លាំងក្លា ពីព្រោះរូបភាពនៃការជួញដូរមនុស្សប្រព្រឹត្តឡើងបំបិទសិទ្ធិសេរីភាព មិនឲ្យមានការដើរហើរបាន ទំនាក់ទំនងទៅកាន់គ្រួសារមានការរារាំង ធ្វើការបង្ខិតបង្ខំ គំរាមកំហែងប្រឆាំងនឹងឆន្ទៈរបស់ជនរងគ្រោះ និងការធ្វើទារុណកម្មគ្រប់រូបភាព។ ទន្ទឹមនឹងនេះផងដែរ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការហាមឃាត់ទៅលើអំពើជួញដូរមនុស្សជាពិសេសទៅលើស្ត្រី និងកុមារ ដែលជាអំពើធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ មាត្រា ៤៦ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញបានចែងថា៖

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។

## កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជា

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាកច្រកម្ពុជា បានចែងបទល្មើសមួយចំនួនដែលទាក់ទងទៅនឹងសកម្មភាព នៃការជួញដូរមនុស្ស។ ខ្ញុំនឹងលើកយកតែបញ្ញត្តិណាដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌមួយចំនួន ដើម្បីយកមកសំយោគទៅនឹងអ្វីដែលបានលើកជាទិដ្ឋភាពនៅក្នុងជំពូកមុន។

### ក. សញ្ញាណនៃក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ និងត្រួតពិនិត្យដោយព្រឹទ្ធសភានៅថ្ងៃទី១៧ ខែវិច្ឆកា ឆ្នាំ២០០៩។ ហើយត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ខ. បញ្ញត្តិជុំវិញសកម្មភាពជួញដូរមនុស្ស

ទោះបីជាមានបញ្ញាត្តិពិសេស អំពីការជួញដូរមនុស្ស (ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨) ក៏ដោយ ក៏ក្រមព្រទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដើរតួនាទីយ៉ាងសំខាន់ជុំវិញ បទល្មើសទាំងឡាយនៃការកេងប្រវ័ញ្ចន៍មនុស្ស។ ហេតុដូច្នេះមានបទល្មើសមួយចំនួនមានចែងដូចគ្នាទាំងក្នុងក្រមព្រហ្មទណ្ឌនិងក្នុងច្បាប់ពិសេស ក៏ប៉ុន្តែបញ្ញត្តិខ្លះមានចែងពីទោសខុសគ្នាក្នុងបទល្មើសតែមួយ តែទោះបីជាយ៉ាងណាក៏ដោយចំងល់ទាំងនេះនឹងត្រូវបានវែកញែកនៅក្នុងកថាខណ្ឌចុងក្រោយ។ ដោយឡែកក្រមព្រហ្មទណ្ឌបានចែងអំពីសកម្មភាពពាក់ព័ន្ធការជួញដូរមនុស្សដូចខាងក្រោម៖

យើងបានជ្រាបហើយថាជនរងគ្រោះនៃអំពើជួញដូរមនុស្សមានទាំងនីតិជន និងអនីតិជន ត្រូវបាននាំយកចេញក្នុងគោលដៅកេងប្រវ័ញ្ចន៍ផ្សេងៗដូចជា ពលកម្មផ្លូវភេទជាដើម។ នៅក្នុងក្រមព្រហ្មទណ្ឌមិនបានបញ្ញត្តិថាការដកយកជនរងគ្រោះនៅក្នុងគោលបំណងសំរាប់ជួញដូរ ឬកេងប្រវ័ញ្ចន៍នោះទេ ឲ្យតែជនល្មើសធ្វើការដកយកជនរងគ្រោះចេញដោយខុសច្បាប់គឺជាលក្ខណ្ឌគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ដាក់បន្ទុក។ នៅក្នុងមាត្រា៣២៧ (បទដកយកអនីតិជន) ចែងថា៖

អំពើដកយកអនីតិជនដោយផ្ទុយច្បាប់ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល។

បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំទៅ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៦.០០០.០០០(ប្រាំមួយលាន) រៀល ប្រសិនបើអនីតិជន ត្រូវបានរក្សាទុកនៅក្រៅដែនដីនៃ ព្រះរាជាណា-ចក្រកម្ពុជា។

ពាក្យថាផ្ទុយច្បាប់ពីបុគ្គលដែលថែរក្សាស្របច្បាប់គឺមានន័យថា ជនល្មើសដកយកអនីតិជនចេញដោយមិនមានសមត្ថកិច្ចស្របច្បាប់ ឬច្បាប់មិនបានអនុញ្ញាតឲ្យទទួលយកអនីតិជននោះពីអ្នកថែរក្សាស្របច្បាប់ដូចជា ឪពុកម្តាយ អាណាព្យាបាល ឬពីកន្លែងថែរក្សាកុមារកំព្រាជាដើម។

- ដើម្បីថែរក្សាជនរងគ្រោះកុំឲ្យមានការរត់គេច ឬលាក់បាំងពីមន្ត្រីមានសមត្ថកិច្ច នោះជនល្មើសមានវិធីឃុំឃាំងជនរងគ្រោះនៅកន្លែងងងឹត ស្ងាត់ ដែលជនរងគ្រោះមិនអាចរើបំរាស់បាន។

ការឃុំឃាំងជនរងគ្រោះត្រូវបានផ្តន្ទាទោសដូចដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ២៥៣ (បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់)

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំង បុគ្គលផ្សេងទៀតដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់បានអនុញ្ញាត ត្រូវផ្តន្ទាទោស៖

១ ដាក់ធន្ធនាគារពី ១(មួយ) ឆ្នាំទៅ៣(បី) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលតិចជាង ៤៨ (សែសិបប្រាំបី) ម៉ោង។

២ ដាក់ពន្ធនាគារពី៣ (បី) ឆ្នាំទៅ៥ (ប្រាំ)ឆ្នាំ បើការចាប់ឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលចាប់ពី ៤៨ (សែសិបប្រាំបី) ម៉ោង ដល់តិចជាង១ (មួយ) ខែ។

៣ ដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំទៅ១០ (ដប់)ឆ្នាំ បើការចាប់ឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលស្មើ ឬលើសពី ១(មួយ) ខែ។

 សញ្ចារកម្ម : ជាបទល្មើសធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សហួសហេតុ ដោយធ្វើការដឹកនាំឲ្យមានជនរងគ្រោះទៅបម្រើសេវាផ្លូវភេទទៅកាន់អតិថិជន ហើយរង់ចាំទទួលប្រាក់កម្រៃពីអតិថិជនតាមរយៈបើកជាទីកន្លែងកំសាន្តសប្បាយដូចជា ខារ៉ាអូខេ ក្លឹប រង្គសាល ឬកន្លែងម៉ាស្សាកោសជប់ជាដើម ហើយបង្កប់នូវសកម្មភាពសញ្ចារកម្ម។ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាណាចក្រកម្ពុជា បានផ្តល់នូវនិយមន័យ និងការផ្តន្ទាទោសយ៉ាងច្បាស់ដែលមានខ្លឹមសារនៅក្នុងមាត្រា ២៨៥ (បទសញ្ចារកម្ម)៖

សញ្ចារកម្ម គឺជាអំពើរ៖

១ ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់អ្នកដទៃ។

២ ជួយ ឬការពារអំពើពេស្យាចាររបស់អ្នកដទៃ ឬរៀបចំតាមគ្រប់មធ្យោបាយនូវសកម្មភាពពេស្យាចារ។

៣ ជ្រើសរើស ពង្រត់ ឬអូសទាញបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ។

៤ ធ្វើការគាបសង្កត់ លើបុគ្គលណាមួយដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។

៥ សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល។

អំពើអូសទាញផលប្រយោជន៍ពេស្យាចារ ពីជនដទៃបានភាគច្រើនមិនមែនកើតចេញពីការស្ម័គ្រចិត្តពីជនរងគ្រោះនោះទេ ភាគច្រើននៃពួកគេក្លាយខ្លួនជាពេស្យាចារ និងបម្រើការក្នុងគ្រឹះស្ថានពេស្យាចារតាមរយៈការបង្ខិតបង្ខំ និងឈានទៅដល់ការប្រើប្រាស់ទារុណកម្ម និងអំពើឃោឃៅផ្សេងៗទៀតទៅលើជនរងគ្រោះដើម្បីឲ្យពួកគេព្រមទទួលបម្រើសេវាកម្មផ្លូវភេទ។

នៅក្នុងក្រមព្រហ្មទណ្ឌការធ្វើទារុណកម្ម ឬអំពើឃោឃៅទៅលើជនរងគ្រោះ ក្នុងបទល្មើសសញ្ចារកម្ម គឺជាស្ថានទម្ងន់ទោស ត្រូវអនុវត្តន៍លើជនល្មើស ជាសញ្ចារិក សញ្ចារិកា ឬជាមេពេស្យាដែលជាធម្មតា នៅក្នុងមាត្រា២៨៥ ផ្តន្ទាទោសត្រឹមតែ ២ឆ្នាំទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀលដល់ ១០លានរៀលប៉ុន្នោះ។រីឯស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើឃោឃៅ ឫទារុណកម្មវិញ ត្រូវបានអនុវត្តន៍ធ្ងន់ធ្ងរ ដែលមានខ្លឹមសារ ក្នុងមាត្រា២៩០ (ស្ថានទម្ងន់ទោស ដោយសារការធ្វើទារុណកម្ម ឬអំពើឃោឃៅ)៖

សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់) ឆ្នាំទៅ ២០(ម្ភៃ)ឆ្នាំកាលបើសញ្ចារិក

សញ្ចារិកា ឬជនមេពេស្យា បានប្រើប្រាស់ទារុណកម្ម ឬអំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ។

ដោយឡែកប្រសិនបើជនរងគ្រោះជាអនីតិជន ក៏ជាស្ថានទម្ងន់ទោសនៃបទល្មើសសញ្ចារកម្មផងដែរ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំទៅដល់ ១៥(ដប់ប្រាំ) ឆ្នាំ។[42]

ជាធម្មតាដើម្បីដំណើរការសញ្ចារកម្មទៅបានលុះត្រាតែមានទីកន្លែង សម្រាប់សម្រួលទៅដល់អតិថិជនអាចទទួលបាននូវសេវានេះ។ ប្រសិនបើបុគ្គលណាដែលលក់កន្លែង ឬផ្តល់ជាទីកន្លែងទៅដល់បុគ្គលដ៏ទៃ ហើយដឹងច្បាស់ ទីកន្លែងនោះនឹងត្រូវប្រើប្រាស់ម្រាប់ ប្រព្រឹត្តសកម្មភាពពេស្យាចារ បុគ្គលនោះ នឹងត្រូវផ្តន្ទាទោសដូចដែលបានចែងនៅក្នុងមាត្រា២៩៣ នៃក្រមព្រហ្មទណ្ឌ (បទដាក់ឲ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ)៖

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល ចំពោះបុគ្គលដែលលក់ ឬដាក់ឲ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែងដែលមិនប្រើប្រាស់ដោយសាធារណៈជន ដោយដឹងច្បាស់ថាបុគ្គលនោះ នឹងប្រើប្រាស់ទីកន្លែងនោះសម្រាប់ធ្វើសកម្មភាពពេស្យាចារ។

ម៉្យាងទៀតទីកន្លែងសម្រាប់ប្រព្រឹត្តពេស្យាចារ តាមរយៈការបង្កើតជាគ្រឹះស្ថានស្របច្បាប់ ប៉ុន្តែធ្វើប្រត្តិការក្នុងគោលបំណងផ្សេងទៀត (ដែលជាអំពើពេស្យាចារមិនមែនជាគោលបំណងសំខាន់របស់គ្រឹះស្ថានទេ) ប៉ុន្តែជាទីកន្លែងដែលបង្កើតឲ្យមានអំពើពេស្យាចារនៅក្នុងបរិវេណនោះ។ គ្រឹះស្ថានទាំងនោះរួមមាន ក្លឹប ខារ៉ាអូខេ កន្លែងម៉ាស្សា ផ្ទះសំណាក់ បារ ឬសណ្ឋាគារ។[43] នៅក្នុងមាត្រា ២៩១ (បទដឹកនាំគ្រប់គ្រងគ្រឹស្ថានសម្រាប់ធ្វើពេស្យាចារ) នៃក្រមព្រហ្មទណ្ឌបានចែងថា៖

អំពើគ្រប់គ្រងធ្វើអាជីវកម្ម ដឹកនាំធ្វើឲ្យដំណើរការ ឬចេញប្រាក់ឲ្យ គ្រឹះស្ថានពេស្យាចារដោយផ្ទាល់ ឬតាមរយៈអន្តរការីត្រូវផ្តន្ទាទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល។

## កថាខណ្ឌទី៣ ច្បាប់ស្តីពីការខារ

### ក. សញ្ញាណនៃច្បាប់ស្តីពីការខារ

[42] មាត្រា២៨៩ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) នៅក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩។

[43] កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ទំព័រទី ១៣១។

ច្បាប់ស្តីពីការងារត្រូវបានសភាអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី៩ និងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ខែមិនា ឆ្នាំ ១៩៩៧។

## ខ. បញ្ញត្តិអំពីការគេចប្រវ័ញ្ចន៍ពលកម្ម

ច្បាប់ស្តីពីការងារត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកតំកើងសិទ្ធិ របស់កម្មករនិយោជិតពីការរំលោភបំពានដោយនិយោជក។ រាល់ទំរង់នៃការងារដោយបង្ខំត្រូវបានហាមឃាត់ ទោះបីជា កម្មករនិយោជិតព្រមធ្វើក៏ដោយ។ ពីព្រោះថាការងារដោយបង្ខំ គឺជនរងគ្រោះមិនបានប្រើសិទ្ធិសេរីភាព របស់ខ្លួនដើម្បីជ្រើសរើសនោះទេ ហើយម៉្យាងវិញទៀតប្រសិនបើមិនព្រមធ្វើការងារនោះ កម្មករនិយោជិតនិងត្រូវទទួលរងនូវទណ្ឌកម្ម គ្រប់បែបយ៉ាងពីជនល្មើស។

ដោយឡែកការងារសម្រាប់ក្មេងត្រូវមានការយកចិត្តទុកដាក់ឲ្យបានខ្ពស់បំផុត ពីព្រោះការងារខ្លះធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់ ធ្វើឲ្យខូចសុខភាព សន្តិសុខ ឬប៉ះពាល់ទៅដល់សីលធម៌របស់ក្មេងដូចជាការងារ នៅក្នុងសិប្បកម្មឡឥដ្ឋ កន្លែងជីករ៉ែ ឧស្សាហកម្មធ្វើដែក ឬនៅតាមគ្រឹះស្ថានដែលបង្កប់នូវពេស្យាចារជាដើម។ ក្មេងត្រូវបានកំណត់អាយុអាចធ្វើការបានចាប់ពី ១៥ឆ្នាំឡើងទៅ។ យោងតាមមាត្រា ១៧៧ កថាខណ្ឌទី ១ និងទី២បានចែងថាៈ

១ អាយុអប្បបរមាអាចចូលធ្វើការជាកម្មករ និយោជិត ត្រូវបានកំណត់ត្រឹម១៥ឆ្នាំ។

២ អាយុអប្បបរមា របស់កម្មករនិយោជិត ត្រូវកំណត់ដល់ ១៨ឆ្នាំចំពោះមុខរបរ ឬការងារគ្រប់ប្រភេទ ដែលធ្វើឲ្យខូចសុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សពេញជំទង់ដោយសារតែលក្ខខណ្ឌ ឬប្រភេទរបស់មុខរបរនិង ការងារទាំងនោះបង្កឡើង។ បែបផែននៃមុខរបរ ឬការងារដែលមានចែងក្នុងកថាខណ្ឌនេះ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ បន្ទាប់ពីពិគ្រោះយោបល់ជាមួយគណៈកម្មការប្រឹក្សាការងារ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក្មេងដែលមានអាយុចាប់ពី១២ឆ្នាំ ដល់១៥ឆ្នាំ ក៏អាចធ្វើការងារបានដែរលុះត្រាតែការងារនោះស្រាលៗ មិនបណ្តាលឲ្យខូចសុខភាព ឬការអភិវឌ្ឍន៍ នៃចិត្តនិងកាយរបស់កុមារហើយដែលជាការងារ មិនបណ្តាលឲ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ការ

ចូលរួមក្នុងកម្មវិធីតំរង់ទិស ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។[44]

រាល់សកម្មភាពដែលប្រព្រឹត្តផ្ទុយពីមាត្រា១៧៧ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ដូចបានចែងក្នុងមាត្រា ៣៦៨នៃច្បាប់ស្តីពីការងារ៖

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីសាមសិបមួយថ្ងៃ ទៅហុកសិបថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ចំពោះនិយោជកដែលមានប្រើប្រាស់ក្មេងអាយុតិចជាង១៨ឆ្នាំ។

## កថាខណ្ឌទី៤ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ( ហៅកាត់LSHTSE)

### ក. សញ្ញាណនៃ LSHTSE

ច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានរៀបចំឡើងដោយក្រសួងយុត្តិធម៌ ក្នុងឆ្នាំ ១៩៩៩ ដោយសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍ផ្នែកច្បាប់ប្រទេសជប៉ុន និងត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយអង្គការយូនីសេហ្វ។ គោលបំណងនៃការបង្កើតច្បាប់នេះឡើង គឺដើម្បីជំនួសច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សឆ្នាំ១៩៩៦ និងដើម្បីឲ្យស្របទៅតាមអនុញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធ និងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារដែលកម្ពុជាបានចុះហត្ថលេខាកាលពីខែមិថុនា ឆ្នាំ ២០០០។

ច្បាប់ត្រូវបានអនុម័ត នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០០៧ ដោយសភាជាតិ និងដោយព្រឹទ្ធសភានៅថ្ងៃទី ១៨ មករា ឆ្នាំ២០០៨ និងត្រូវបានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

សូមបញ្ជាក់ថា ច្បាប់ត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រខណៈពេលដែលក្រមព្រហ្មទណ្ឌមិនទាន់ចូលជាធរមាននៅឡើយ។

### ខ. បញ្ញត្តិជុំវិញការរំលោភសិទ្ធិមនុស្ស

ដោយសារតែច្បាប់នេះមានលក្ខណៈពិសេសច្រើនទាក់ទងទៅនិងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍ផ្សេងៗដូច្នេះ តម្រូវឲ្យលើកមកសរសេរ និងសិក្សាក៏ច្រើនផងដែរ ដែលក្នុងនោះរួមមាន៖

[44] មាត្រា១៧៧ កថខណ្ឌទី៤ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧។

### ខ.១. ការនាំយកចេញនូវជនរងគ្រោះ

ការនាំយកចេញនូវជនរងគ្រោះ គឺជាដំណាក់កាលដំបូងដែលធ្វើការបំលាស់ទីជងរងគ្រោះ និងអាចប្រព្រឹត្តនូវសកម្មភាពនៃការកេងប្រវ័ញ្ចន៍ផ្សេងៗទៀត។ ការនាំយកចេញនេះគឺចង់សំដៅទៅលើការនាំយកចេញដោយមិនស្របច្បាប់។ បើយោងទៅតាមមាត្រា៨ កថាខណ្ឌទី១នៃច្បាប់នេះ (LSHTSE) បានឲ្យនិយមន័យថា៖

ការនាំយកចេញដោយមិនស្របច្បាប់ នៅក្នុងច្បាប់នេះមាយន័យថា៖

១ ការធ្វើឲ្យមនុស្សម្នាក់ផ្លាស់ពីទីកន្លែង ដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដ៏ទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជន តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោម។

ទោះជាយ៉ាងណាក៏ដោយការលើកយកមាត្រាខាងលើ មកផ្ដល់និយមន័យក៏មិនទាន់មានការយល់ជាក់លាក់នោះទេ លុះត្រាតែមានការពន្យល់នូវសំណង់ប្រយោគ ឬពាក្យនីមួយៗ។ ឧទាហរណ៍ថា ការបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោមមានន័យដូចម្ដេច?

ដូចគ្នានេះផងដែរ ដើម្បីអាចចោទប្រកាន់ជនល្មើសទៅលើបទល្មើសនេះបានលុះត្រាតែមានធាតុផ្សំបីសំខាន់ៗគឺ ការនាំយកចេញ, ការត្រួតពិនិត្យ និងមធ្យោបាយ។

- ការនាំយកចេញមានន័យថាជាការផ្លាស់ទីពីទីកន្លែង ដែលគេកំពុងរស់នៅដូចជា ផ្ទះឬលំនៅឋានរបស់ជនរងគ្រោះ។ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៣៤ លំនៅឋានមានន័យថា កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលណាម្នាក់ៗ។ ទោះជាយ៉ាងណាក៏ដោយការនាំយកចេញត្រូវបានបកស្រាយម៉្យាងទៀតថាជនរងគ្រោះ ត្រូវបានហាមឃាត់រូបកាយពីការចូលទៅក្នុងលំនៅដ្ឋានរបស់គាត់។ ទោះបីជាជនរងគ្រោះត្រូវបាននាំយកចេញពីទីកន្លែងណាក៏ដោយ (កន្លែងធ្វើការ, ផ្សារ...) ក៏ត្រូវចាត់ទុកថាជាការនាំយកចេញដោយមិនស្របច្បាប់ដែរ ពីព្រោះជនរងគ្រោះមិនអាចចេញពីទីកន្លែងនោះមកកាន់លំនៅឋានរបស់គាត់វិញដូចធម្មតា។
- ការត្រួតពិនិត្យ មានន័យថាក្រោយពីជនល្មើសបាននាំយកចេញដោយមិនស្របច្បាប់រួចមកជនល្មើសនាំយកទៅទីកន្លែងដ៏ទៃដោយទុកនៅក្រោមការត្រួតពិនិត្យ របស់ខ្លួន ឬរបស់តតិយជនហើយដែលជនរងគ្រោះមិនអាចចេញមកវិញដោយស្ម័គ្រចិត្តពីទីកន្លែងដែលត្រូវបានត្រួតពិនិត្យដោយជនល្មើសនោះ។

- មធ្យោបាយដើម្បីអាចទាញយកជនរងគ្រោះបាន ជនល្មើសត្រូវប្រើប្រាស់នូវមធ្យោបាយទាំងនោះរួមមាន[45]៖
  - ការបង្ខិតបង្ខំ: មានន័យថាជាការបង្ខិតបង្ខំផ្លូវកាយ ឬផ្លូវចិត្តប្រឆាំងនឹងឆន្ទៈរបស់ជនរងគ្រោះ។ ការបង្ខំនេះមិនមែនមានន័យថាតម្រូវឲ្យជនល្មើសធ្វើការវាយដំ ច្រំធាក់ ឬធ្វើឲ្យជនរងគ្រោះមានរបួសនោះទេ គ្រាន់តែជនល្មើសធ្វើការរុញ ឬទាញជនរងគ្រោះដែលធ្វើឲ្យជនរងគ្រោះនោះព្រមទៅជាមួយផ្ទុយពីឆន្ទៈរបស់ខ្លួន គឺចាត់ទុកថាជាការបង្ខិតបង្ខំ។
  - ការគ្រាមកំហែង: មានន័យថាជាការគម្រាមកំហែងដោយផ្ទាល់ និងដោយប្រយោលដែលធ្វើឲ្យជនរងគ្រោះភ័យខ្លាចពីការធ្វើបាប រូបកាយ ឬផ្លូវចិត្ត ឬភ័យខ្លាចមានគ្រោះថ្នាក់ផ្សេងទៀតដល់ខ្លួន ឬដល់តតិយជន។ ដោយឡែកការគម្រាមប្រព្រឹត្តអំពើស្របច្បាប់ ប៉ុន្តែប្រើប្រាស់ការគម្រាមកំហែងនោះដើម្បីប្រព្រឹត្តបទល្មើសទៅវិញ ក៏ចាត់ទុកថាជាការគម្រាមកំហែងផងដែរ។ ឧទាហរណ៍ ជនល្មើសនិងគម្រាមកំហែងថានឹងរាយការណ៍អំពី ការធ្វើចំណាកស្រុកខុសច្បាប់ទៅមន្ត្រីមានសមត្ថកិច្ចប្រសិនបើជនរងគ្រោះមិនព្រមធ្វើការងារនៅក្នុងការដ្ឋានរ៉ែ។
  - ការបោកបញ្ឆោត: នេះក៏ជាមធ្យោបាយមួយផងដែរដែលសកម្មភាពរបស់ជនល្មើសប្រើពាក្យកុហក ផ្តល់ពត៌មានមិនពេញលេញ ឬរឿងមិនពិត ជាពាក្យសំដី ឬជាទង្វើដើម្បីឲ្យជនរងគ្រោះជឿធ្វើអ្វីមួយ។
  - ការបំពានដោយអំណាច: មានន័យថាជាស្ថានការណ៍មួយដែលមន្ត្រីសាធារណៈ (ដែលរួមមាន មន្ត្រីរាជការបុគ្គលដែលមានតួនាទីដោយការបោះឆ្នោតជ្រើសរើស ឬមន្ត្រីដែលត្រូវបានតែងតាំងផ្សេងទៀត) ប្រើប្រាសតួនាទីរបស់ខ្លួន ឬឆ្លៀត យកប្រយោជន៍ពីតួនាទីរបស់ខ្លួនដើម្បីប្រព្រឹត្តអំពើខុសច្បាប់។
  - ការលួងលោមសំដៅ ដល់ស្ថានការដែលជនល្មើស លួងលោម ជងរងគ្រោះដោយធ្វើការសន្យាក្លែងក្លាយ ឬដោយមិនបានផ្តល់ពត៌មានពេញលេញ ធ្វើឲ្យជនរងគ្រោះជឿនិងទៅតាមជនល្មើស។

ចំពោះការនាំយកចេញដោយមិនស្របច្បាប់ត្រូវបានផ្តន្ទាទោសអាស្រ័យទៅតាមបទល្មើសនីមួយៗមានន័យថាការនាំយកចេញដោយមិនស្របច្បាប់ទៅលើអនីតិជន ដោយមានគោលដៅ ឬសម្រាប់ឆ្លងដែនជាដើម។ ឧទាហរណ៍នៅក្នុងមាត្រា១០នៃ LSHTSE ចែងថា៖

[45] កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី ២,២០១៣.៣៦-៣៨។

ជនណាដែលនាំយកជនដ៏ទៃដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាព រៀបអាពាហ៍ពិពាហ៍ជនរងគ្រោះស្មុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់ ១៥ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំទៅ២០ ឆ្នាំ ក្នុងករណីដែលៈ

- ជនរងគ្រោះជាអនីតិជន
- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។
- អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង។

ពាក្យថាទម្រង់នៃការកេងប្រវ័ញ្ចន៍ទៀត នៅក្នុងមាត្រនេះ និងមាត្រា១២ មាត្រា១៥ មាត្រា១៧ និងមាត្រា១៩ នៃច្បាប់នេះរួមមានការកេងប្រវ័ញ្ចន៍លើពេស្យាកម្មជនដ៏ទៃ រូបភាព និងសម្ភារៈអាសអាភាសពាណិជ្ជកម្មផ្លូវភេទ សេវា ឬពលកម្មដោយបង្ខំទាសភាពឬ ការអនុវត្តន៍ ស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុលសេរភាពដោយមិនស្មគ្រចិត្តពលកម្មកុមារ ឬ ការដកហូតសេរីរាង្គ។

ការយល់ព្រមរបស់ជនរងគ្រោះគោលដៅដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះមិនទាក់ទងទៅ និងមធ្យោបាយណាមួយដែលមានដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៨នៃច្បាប់នេះដែលត្រូវបានប្រើនោះទេ។ ករណីនេះត្រូវយកទៅអនុវត្តន៍ផងដែរចំពោះបទល្មើសដែល មានចែងក្នុងមាត្រា១៥ មាត្រា១៧ និងមាត្រា១៩ នៃច្បាប់នេះ។

សូមបញ្ជាក់ថាការនាំយកចេញដោយមិនស្របច្បាប់ ទៅលើអនីតិជន និងការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែនគឺមានចែងនៅក្នុងមាត្រា៩ និង១១ នៃច្បាប់ LSHTSE។

### ខ.២. អំពើលក់ដូរមនុស្ស

អំពើលក់ដូរមនុស្សត្រូវបានផ្តល់និយមន័យក្នុងមាត្រា១៣ នៃ LSHTSE ថាៈ

អំពើលក់ដូរមនុស្សមានន័យថា ប្រគល់ឲ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដ៏ទៃ ឬដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដ៏ទៃដោយប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។

អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងអំពើលក់-ដូរមនុស្សដោយផ្ទាល់។

នៅក្នុងសកម្មភាពលក់-ដូរមនុស្ស មានការផ្តន្ទាទោសមិនថា អ្នកលក់ ឬអ្នកទិញត្រូវទទួលទោសដូចគ្នាចំពោះការប្រព្រឹត្តបទល្មើសនេះ។ បទល្មើសលក់-ដូរមនុស្សនេះទៀតសោត៍ គឺតម្រូវឲ្យមានធាតុផ្សំ២ ដូចជា៖ ការប្រគល់ឲ្យដោយខុសច្បាប់ (ការលក់) នូវការគ្រប់គ្រងទៅលើជនណាម្នាក់ ឬទទួលដោយខុសច្បាប់ (ការទិញ)លើជនណាម្នាក់ និងផ្តោះប្តូរទៅនឹងរបស់មានតម្លៃ។

ការប្រគល់ និងការទទួលជនណាម្នាក់ដោយខុសច្បាប់មានន័យថា គឺប្រព្រឹត្តឡើងតាមរយៈការប្រើប្រាស់មធ្យោបាយដែលខុសច្បាប់ ដូចជាប្រើប្រាស់កម្លាំងបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោមនៅពេលដែលធ្វើឡើងដោយមានគោលដៅខុសច្បាប់ ឬទៅលើអនីតិជន ឬទៅលើជនផ្សេងទៀតដែលមិនមានសមត្ថភាពខាងផ្លូវច្បាប់។

រីឯ ការផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ មានន័យថាអ្នកទិញផ្តោះប្តូរទៅនឹងការទទួលការគ្រប់គ្រងលើជនរងគ្រោះពីអ្នកលក់។ ពាក្យថាវត្ថុមានតម្លៃ រាប់បញ្ចូលជាអាទិ៍លាភការជាប្រាក់ ឬជារបស់ វត្ថុមានតម្លៃទ្រព្យសម្បត្តិ សេវាកម្ម ការបង់ប្រាក់ដោយផ្ទាល់ ឬដោយប្រយោល ឬថ្លៃឈ្នួល ពតិមានមានតម្លៃ ឬការគ្រប់គ្រងទៅលើមនុស្សផ្សេងទៀត។

អំពើលក់ដូរនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់ ៥ឆ្នាំ។ ចំណែកឯស្ថានទម្ងន់ទោសនៃអំពើជួញដូរមនុស្សវាអាស្រ័យទៅលើប្រភេទនៃបទល្មើស ដែលជនល្មើសបានប្រព្រឹត្ត គឺអាចលក់-ដូរដោយមានគោលដៅ ឬលក់ដូរសម្រាប់នាំឆ្លងដែន។ ចំពោះការលក់-ដូរសម្រាប់នាំឆ្លងដែនគឺមានចែងនៅក្នុងមាត្រា ១៦ កថាខណ្ឌទី១-២ (អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន) នៃ LSHTSE ថា៖

- ជនណាដែលលក់-ដូរជនដទៃ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥(ដប់ប្រាំ) ឆ្នាំ។
- ជនណាដែលលក់-ដូរជនដទៃ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅប្រគល់ ឬនាំជននោះ ទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី ១ ខាងលើ។

ដើម្បីអាចផ្តន្ទាទោសជនល្មើសយោងតាមមាត្រានេះ លុះត្រាតែជនល្មើសត្រូវបានបំពេញធាតុផ្សំ ២សំខាន់ៗនោះគឺ៖ អំពើលក់-ដូរមនុស្ស និងដោយមានគោលដៅនាំឆ្លងដែន។

ដូចបានពន្យល់ពីខាងលើមកហើយថា ធាតុផ្សំនៃ «អំពើលក់-ដូរមនុស្ស» គឺនៅត្រង់មានការប្រគល់ និងការទទួលជនណាម្នាក់ដោយខុសច្បាប់ ដោយធ្វើការផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ។ ចំណែកឯ «មានគោលដៅនាំឆ្លងដែន» មានន័យថាជនល្មើសត្រូវតែបានប្រព្រឹត្តអំពើលក់-ដូរ

មនុស្សដោយមានគោលដៅនាំជនរងគ្រោះឆ្លងព្រំដែនអន្តរជាតិ។ ចេតនានៃការនាំជនរងគ្រោះឆ្លងព្រំដែនអន្តរជាតិនេះគឺមិនតម្រូវឲ្យជនល្មើសឆ្លង ឬមានចេតនាឆ្លងព្រំដែនអន្តរជាតិដោយខ្លួនឯងនោះទេ ឬមិនចាំបាច់ថាជនរងគ្រោះត្រូវតែបានឆ្លងដែននោះដែរ វាជាការគ្រប់គ្រាន់ហើយដែលជនល្មើសមានចេតនា លក់-ដូរជនរងគ្រោះឆ្លងព្រំដែនអន្តរជាតិនោះ។ ការនាំឆ្លងដែននេះមានពីររូបភាពកើតឡើងនោះគឺ៖

- គោលដៅប្រគល់ ឬនាំយកជនរងគ្រោះទៅក្រៅព្រះរាជាណាចក្រកម្ពុជា មានចេតនាដែលនាំយក ឬគ្រោះជនរងគ្រោះពីប្រទេសកម្ពុជាទៅកាន់ប្រទេសក្រៅ
- ការនាំយកចេញជនរងគ្រោះ ដែលប្រព្រឹត្តនៅក្រៅប្រទេសកម្ពុជារួចប្រគល់ទៅកាន់ប្រទេសណាមួយផ្សេងទៀត។ មានន័យថាបទល្មើសនៃការនាំយកចេញកើតឡើងមិនមែនស្ថិតនៅក្នុងប្រទេសកម្ពុជាឡើយ តែមានជនល្មើស ឬជនរងគ្រោះមានសញ្ជាតិខ្មែរ។ តើរដ្ឋណាមានយុត្តាធិការទៅលើបទល្មើសនេះ? នៅក្នុងមាត្រា ២ និងមាត្រា៣ នៃLSHTSE ចែងថា៖

មាត្រា ២. ការអនុវត្តច្បាប់នេះនៅក្នុងដែនដី

ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងច្បាប់នេះ រួមបញ្ចូលទាំងនាវា ឬ អាកាសយានណាមួយដែលមានសិទ្ធិប្រើប្រាស់ទង់ជាតិកម្ពុជា។

បទល្មើសមួយត្រូវចាត់ទុកថា បានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើរួមផ្សំណាមួយនៃបទល្មើសនោះកើតឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣.- ការអនុវត្តច្បាប់នេះនៅក្រៅដែនដី

ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ។

ច្បាប់នេះអនុវត្តទៅលើបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើង នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយជនបរទេស ហើយជនរងគ្រោះគឺជាពលរដ្ឋខ្មែរនៅពេលដែលបទល្មើសកើតឡើង។

### ខ.៣. សញ្ញារកម្ម

ដើម្បីក្តោបនិយមន័យទាំងមូល សញ្ចារកម្មមានន័យថា ជនទាំងឡាយណាដែលទទួល ឬរំពឹងថានឹងទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់ជនដទៃ ឬអ្នកដែលមានចេតនាធ្វើឲ្យរីកចម្រើនដល់សម្មភាពអាជីវកម្មពេស្យាចារ។[46] បើយោងតាមមាត្រា ២៥ នៃLSHTSE ចែងថាៈ

មាត្រា ២៥. និយមន័យនៃសញ្ចារកម្ម

អំពើសញ្ចារកម្ម នៅក្នុងច្បាប់នេះ មានន័យថា:

១ ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២ ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ

៣ ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ

៤ ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ។

អំពើដូចខាងក្រោមនេះ ត្រូវចាត់ទុកថា ដូចគ្នាទៅនឹងសញ្ចារកម្ម:

១ អំពើធ្វើជាអន្តរការីរវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារជនដទៃ។

២ អំពើរបស់ជនណាដែលបានជួយសម្រួល ឬ បិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម។

៣ អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះ ដោយការធ្វើពេស្យាចារ។

កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរបស់ក្រសួងយុត្តិធមិ បានធ្វើការកំណត់ពន្យល់នូវកថាខណ្ឌនីមួយៗទាក់ទងទៅនឹងនិយមន័យទាំងនេះថាៈ

- ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពី ពីអំពើពេស្យាចាររបស់ជនដ៏ទៃៈ ផលប្រយោជន៍ហិរញ្ញវត្ថុ មានន័យថា ជាវត្ថុមានតម្លៃអ្វីមួយដែកអ្នកប្រព្រឹត្តទាញយកផលប្រយោជន៍ពីវត្ថុនោះ។ វត្ថុមានតម្លៃអាចមានដូចជា ប្រាក់ គ្រឿងអលង្ការ សំលៀកបំពាក់ ឬអចលនវត្ថុដូចជា ផ្ទះ ដី អគារ ឬជាទ្រព្យសម្បត្តិដែលគ្មានរូបរាងដូចជា សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់ ជួល លក់ ប្រភេទអចលន

[46] កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២,២០១៣, ១១១។

ទ្រព្យ ឬចលនទ្រព្យ សេវាកម្ម ការបងប្រាក់ ឬថ្លៃឈ្នួល ពតិមានមានតម្លៃ ឬការគ្រប់គ្រងលើមនុស្ស។

រីឯការទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុពី ពីអំពើពេស្យាចាររបស់ជនដ៏ទៃមានន័យថា អ្នកប្រព្រឹត្តទទួលយកអត្ថប្រយោជន៍ដោយផ្ទាល់ ពីសេវកម្មពេស្យាចាររបស់ជនដ៏ទៃ មិនមែនជាសេវាកម្មពេស្យាចារណាមួយដែលប្រព្រឹត្តដោយខ្លួនឯងនោះទេ។ ឧទាហរណ៍៖ ម្ចាស់ផ្ទះបនទាញយកផលពីអំពើពេស្យាចារ របស់បុគ្គលពេស្យាចារនៅផ្ទះបននោះ។

- ជួយ ឬការពារអំពើពេស្យាចាររបស់ជនដ៏ទៃ មានន័យថាអ្នកប្រព្រឹត្តបានជួយសម្រួល ឬបិទបាំងអំពើពេស្យាចាររបស់ជនដ៏ទៃ។ ការជួយសម្រួល ឬបិទបាំង មានន័យថាជាទម្រង់នៃ ការជួយ ការការពារ ការជម្រុញ ឬសម្រួល។ ចំណោកឯពាក្យថា អំពើពេស្យាចាររបស់ជនដ៏ទៃ មានន័យថាជាសកម្មភាពអាជីវកម្មអំពើពេស្យាចារ (មិនមែនជាការជួយបុគ្គលពេស្យាចារទេ)។

ឧទាហរណ៍ថា ម្ចាស់កន្លែងខារាអូខេដែលបង្កប់នូវពេស្យាចារ បានជូលសន្តិសុខដើម្បីយាមនៅខាងមុខ ហើយនៅពេលដែលមានមន្ត្រីមានសមត្ថកិច្ចចុះទៅបង្ក្រាប នឹងអាចងាយស្រួលជូនដំណឹងទៅខ្លួន។ ដូចនេះសន្តិសុខអាចត្រូវបានចោទប្រកាន់ពីការធ្វើសញ្ចារកម្មនេះផងដែរប្រសិនបើខ្លួនបានដឹងច្បាស់ថាគោលបំណងដែលត្រូវបានគេជួលមកនេះដើម្បីជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ។

- ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ មានន័យថាប្រសិនបើម្ចាស់ផ្ទះបន ឬអ្នកធ្វើការនៅផ្ទះបនអូសទាញជនណាម្នាក់ឲ្យធ្វើការនៅផ្ទះបនជាបុគ្គលពេស្យាដោយផ្តល់ ឬសន្យាឲ្យប្រាក់អំពើអូសទាញនោះគឺជាសញ្ចារកម្ម។

- ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។ ពាក្យថាការគាបសង្កត់ ក្នុងមាត្រានេះរួមមានជាអាទិ៍ : ការបង្ខំ ការគាបសង្កត់ ឬការដាក់កំហិតលើរាងកាយ ព្រមទាំងប្រភេទនៃការគាបសង្កត់ផ្សេងទៀត ដែលរួមមានការគាបសង្កត់ ហិរញ្ញវត្ថុ និងផ្លូវចិត្ត។ ឧទាហរណ៍៖ អ្នកប្រព្រឹត្តបានគម្រាមកំហែង ឲ្យកូនស្រីរបស់ខ្លួនប្រព្រឹត្តអំពើពេស្យាចារ បើមិនប្រព្រឹត្តខ្លួននឹងដកការគាំទ្រពីកូនស្រី។ មានន័យថាក្នុងនាមជាឪពុកបានធ្វើការគាបសង្កត់ទៅលើកូនស្រីរបស់ខ្លួនឲ្យធ្វើជាស្រីពេស្យា។

ដូចនេះជនណាហើយដែលប្រព្រឹត្តនូវចំនុចណាមួយដូចបានរៀបរាប់ខាងលើ នឹងត្រូវចោទប្រកាន់ពីការធ្វើសញ្ចារកម្ម ហើយត្រូវផ្តន្ទាទោសយោងតាមមាត្រា ២៦(សញ្ចារកម្ម) នៃ LSHTSE

ដោយមានការផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ មិនមានការពិន័យជាប្រាក់ឡើយ។ ការបញ្ញត្តិបែបនេះវាមានការផ្ទុយពីក្រមព្រហ្មទណ្ឌមាត្រា ២៨៤ (សញ្ចារកម្ម) ដែលមានការពិន័យជាប្រាក់ផងដែរ។ លើសពីនេះទៅទៀតសញ្ចារកម្ម ប្រសិនបើប្រព្រឹត្តឡើងដោយមានការធ្វើទារុណកម្ម នឹងត្រូវផ្តន្ទាទោសយោងតាមមាត្រា ២៩(សញ្ចារកម្មដោយមានការធ្វើទារុណកម្ម) នៃ LSHTSE៖

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើសញ្ចារិក សញ្ចារិកា ឬ មេពេស្យាបានប្រើទារុណកម្ម ឬ អំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ។

### គ. គោលការណ៍នៃការបកស្រាយច្បាប់

ដោយសារតែក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានបញ្ញត្តិឡើងមានលក្ខណៈផ្ទុយគ្នា ឬក៏មានការចែងដូចគ្នានៅត្រង់មាត្រាមួយចំនួន ដូចនេះវាបង្កប់នូវចំងល់ថា តើត្រូវយកច្បាប់ណាមកអនុវត្ត? ក្រឡេកទៅមើល ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចូលជាធរមាននៅឆ្នាំ២០០៨ មុនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩។ ទោះបីជាក្រមព្រហ្មទណ្ឌគឺជាច្បាប់ទូទៅក៏ដោយ ប្រសិនបើចែងឡើងមានទំនាស់ជាមួយនឹង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នោះនឹងត្រូវបានបកស្រាយពីរូបភាពដូចខាងក្រោម៖[47]

- ប្រសិនបើមានបញ្ញត្តិណានៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងធ្វើឲ្យមានទំនាស់ជាមួយនឹងក្រមព្រហ្មទណ្ឌ នោះបញ្ញត្តិដែលមានចែងនៅក្នុង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវបានជំនួសតែពាក្យណាដែលផ្ទុយគ្នាតែប៉ុណ្ណោះ។
- នៅក្នុងករណីដែលបទល្មើសទាក់ទងទៅនឹងអំពើជួញដូរមនុស្ស ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវយកមកអនុវត្តទោះបីជាមានចែងផ្ទុយពីច្បាប់ទូទៅក៏ដោយ។ មូលហេតុគឺដោយសារតែក្រមព្រហ្មទណ្ឌមិនបានចែងជាក់លាក់ អំពីការជួញដូរមនុស្សនោះទេ ម្យ៉ាងទៀតស្របទៅនឹងគោលការណ៍នៃការបកស្រាយច្បាប់

[47] កំណត់ពន្យល់មាត្រានីមួយៗនៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២,២០១៣, ៨-៩។

ដែលជាទូទៅច្បាប់ពិសេសមានអាទិភាពជាងច្បាប់ទូទៅ។ នៅក្នុងក្រមព្រហ្មទណ្ឌបានទទួលស្គាល់ការបកស្រាយបែបនេះនៅក្នុងមាត្រា ៦៦៨ កថាខណ្ឌទី១ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) ថា៖

> ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀតដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ។

ដូចនេះ ដំណោះស្រាយនូវទំនាស់រវៀងច្បាប់ទាំងពីរខាងលើអាចប្រើប្រាស់នូវគោលការណ៍នៃការបកស្រាយច្បាប់ ដើម្បីកាត់បន្ថយនូវវិវាទផ្សេងៗ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងបរិបទនៃការជួញដូរមនុស្សនៅកម្ពុជា គឺមិនមានលក្ខណៈជំហរ ឬវាមានលក្ខណៈដែលមិនអាចសន្និដ្ឋានដោយភ្នែកថាមានបុគ្គលកំពុងតែប្រព្រឹត្តអំពើជួញដូរមនុស្សនោះទេ។ ពីព្រោះបទល្មើសនេះមានការលាក់បាំង ឬស្តែងឡើងតាមរយៈ វិធីសមហេតុសមផល ដែលជនរងគ្រោះ ឬសហគមន៍ពិបាកកត់សម្គាល់ថាវាគឺជាសកម្មភាពដែលកំពុងប្រព្រឹត្តក្នុងគោលដៅជួញដូរ។ បើសិនជាជនរងគ្រោះ ឬក្រុមគ្រួសារអាចសម្គាល់បានថាវាគឺជាអំពើបោកប្រាស់នោះ ពួកគេមិនសុទ្ធចិត្តបណ្តោយឲ្យជនរងគ្រោះជាកូន ឬសាច់ញាតិ អ្នកជិតខាង ឬមិត្តភក្តិ ធ្លាក់ចូលក្នុងកណ្តាប់ដៃជនល្មើសនោះទេ។ ហើយម្យ៉ាងវិញទៀតដោយសារតែស្ថានភាពរស់នៅមានការលំបាក វេទនា ជំពាក់បំណុល ជម្ងឺឈឺថ្កាត់ គ្រោះទុរភិក្ស គ្មានចំណេះដឹង ការធ្វើកសិកម្មមិនអំណោយផល គឺជាកត្តាដែលជម្រុញពួកគេឲ្យទៅស្វែងរកស្ថានភាពរស់នៅដែលប្រសើរជាងនោះ ម្លោះហើយបង្ខំខ្លួន ឬសមាជិកគ្រួសាររបស់ខ្លួនចាកចេញទៅតាមជនល្មើស។

ទន្ទឹមនឹងនេះ ការចំណាកស្រុករបស់គេគឺមានការប្រថុយប្រថាន ជួបការលំបាក រងទុក្ខវេទនាយ៉ាងក្រៃលែង។ នៅពេលដែលស្ថិតនៅក្នុងស្ថានភាពនៃការជួញដូរមនុស្ស ជនរងគ្រោះត្រូវបានគេចាត់ទុកដូចជាទាសករ ព្រោះត្រូវបង្ខំឲ្យធ្វើការងារ ឬបម្រើសេវាឥតឈប់ឈរ។ មិនតែប៉ុណ្ណោះថែមទាំងពួកគេទទួលរងនូវការធ្វើទារុណកម្មគ្រប់បែបយ៉ាង ឃុំឃាំងមិនឲ្យមានសេរីភាព ផ្តាច់ការទំនាក់ទំនងជាមួយមនុស្សជាទីស្រលាញ់របស់ខ្លួន។ ទង្វើដែលជនល្មើសបានធ្វើគឺជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសង្គមយ៉ាងខ្លាំង។ ការជះឥទ្ធិពលទាំងនោះបណ្តាលឲ្យ ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ បាត់បង់កម្លាំងពលកម្ម ប៉ះពាល់កិត្តិយស សុខភាព សេចក្តីថ្លៃថ្នូរ ។ល។

ក្នុងគោលបំណងនៃការស្តារនីតិសម្បទា និងក៏ជាក្តីរំពឹងទុករបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានស្វះស្វែងរកគ្រប់វិធីដើម្បីជួយសង្គ្រោះជនរងគ្រោះពីភាពងងឹត តាមរយៈក្រសួងស្ថាប័នអង្គភាពនានារបស់រដ្ឋ មានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងទាំងនៅក្នុងតំបន់ និងក្រៅតំបន់ ព្រមទាំងជាមួយអង្គការអន្តរជាតិផ្សេងទៀត ដើម្បីធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋរបស់ខ្លួនទាំងឡាយដែលត្រូវបានជួញដូរ។ លើសពីនេះទៅទៀតរដ្ឋាភិបាលបានបង្កើតនូវមជ្ឈមណ្ឌលស្តានីតិសម្បទាក្នុងគោលបំណងជួយពង្រឹងសមត្ថភាព និងព្យាបាលជនរងគ្រោះទាំងផ្លូវកាយ និងផ្លូវចិត្តដែលបានបាត់បង់ និងខូចខាតក្នុងកំឡុងពេលដែលត្រូវបានជួញដូរ។ ក្រៅពីរដ្ឋាភិបាលក៏មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលត្រូវបានបង្កើតឡើង និងទទួលស្គាល់ដោយច្បាប់កម្ពុជាអនុញ្ញាតឲ្យធ្វើការជួយសង្គ្រោះជនរងគ្រោះ។ តាមរយៈសកម្មភាពរបស់អង្គាការទាំងឡាយនោះ យើងឃើញ

មាននូវសមិទ្ធផលផ្លែផ្កាលេចឡើង ដោយជនរងគ្រោះជាពិសេសស្ត្រី និងកុមារទទួលបាននូវលក្ខខណ្ឌអនុគ្រោះជាច្រើន។

ដោយសារតែមានការរីករាលដាល នៃអំពើដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិមនុស្សនេះទើបរដ្ឋអន្តរជាតិទាំងឡាយចូលរួមអនុម័តច្បាប់អន្តរជាតិដើម្បីបង្ក្រាប ការពារ បង្ការ និងជួយសង្គ្រោះជុំវិញបទល្មើសជួញដូរមនុស្សនេះ។ ក្នុងនោះកម្ពុជាបានចុះហត្ថលេខា ឬ/និងផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិនានាទាក់ទងទៅនឹងសិទ្ធិមនុស្ស។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានអនុម័តនូវបទដ្ឋានគតិយុត្តជាច្រើនទាក់ទងទៅនឹងអំពើជួញដូរមនុស្ស ជាពិសេសគឺច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨។

ដូចនេះយើងអាចជ្រាបបានថា កើតមកជាមនុស្សមានតម្រូវការដូចៗគ្នាមិនចំពោះទៅលើនរណាម្នាក់ ឬក្រុមណានោះទេ។ មានន័យថាការចង់ទទួលបាននូវជីវភាពរស់នៅសំបូរសប្បាយគឺមិនមែនតាមរយៈរបរអាជីវកម្មទុច្ចរិតនោះទេ ជាពិសេសអាជីវកម្មទៅមនុស្សដែលទទួលផលចំណេញសំរាប់ខ្លួន ឬក្រុមគ្រួសារបក្សពួករបស់ខ្លួន ប៉ុន្តែវាពិតជាជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់បុគ្គលដំទៃខណៈពេលដែលពួកគេទាំងនោះក៏ត្រូវការសិទ្ធិជាមូលដ្ឋានដែរ។

ជាចុងក្រោយ បន្ទាប់ពីបានធ្វើការស្រាវជ្រាវលើប្រធានបទមួយនេះមកវាធ្វើឲ្យបំផុសនូវចម្ងល់មួយថា ខណៈពេលដែលប្រទេសកម្ពុជាមានច្បាប់គ្រប់គ្រាន់ មានកម្លាំងសមត្ថកិច្ច និងមានការងារសម្រាប់ឲ្យប្រជាពលរដ្ឋ ហេតុអ្វីទើបមិនអាចបញ្ឈប់នូវអំពើជួញដូរមនុស្សនេះបាន?

## អនុសាសន៍

ជាចុងក្រោយនេះ ខ្ញុំបាទមាននូវអនុសាសន៍មួយចំនួនដើម្បីជួយរួមចំណែកកាត់បន្ថយអំពើជួញដូរមនុស្ស ក៏ដូចជាលើកទឹកចិត្តដល់មន្ត្រីមានសមត្ថកិច្ចក្នុងការបំពេញតួនាទីរបស់ពួកគាត់៖

- **ចំពោះប្រជាពលរដ្ឋ**
  - នៅពេលដែលមានគេមកណែនាំអំពីការងារដែលមានកម្រៃខ្ពស់ ហើយតម្រូវឲ្យចំណាកស្រុកទោះក្នុង ស្រុក (ទីក្រុង) ឬក្រៅប្រទេសក្តី នោះត្រូវតែមានការពិចារណាល្អិតល្អន់ ជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន ជាពិសេសជាមួយនឹងតំណាងសិទ្ធិមនុស្ស (ប្រធានភូមិ ឃុំ/សង្កាត់ និងអង្គការ) នៅក្នុងមូលដ្ឋានរបស់ខ្លួន។
  - ត្រូវស៊ើបឲ្យដឹងពីសវតានៃកន្លែងដែលនឹងត្រូវធ្វើការ និងមនុស្សមកណែនាំការងារនោះ។

- ឪពុក-ម្ដាយ មិនត្រូវបង្ខំកូនរបស់ខ្លួនឲ្យធ្វើការងារណាដែលរំលោភសិទ្ធិមនុស្ស (ជាស្រីពេស្យា កេងប្រវ័ញ្ចន៍ពលកម្ម...) ទោះបីជាស្ថិតនៅក្នុងស្ថានភាពទីទាល់ក្រយ៉ាងណាក៏ដោយ ឬទោះបីជាការងារនោះមានចំណូលប្រាក់កម្រៃលើសលប់ក៏ដោយ។
- ត្រូវរាយការជាបន្ទាន់ដល់មន្ត្រីមានសមត្ថកិច្ច ប្រសិនបើជួបប្រទះនូវការជួញដូរមនុស្ស។
- ឪពុក-ម្ដាយត្រូវបញ្ជូនកូនទៅសាលារៀន ដើម្បីទទួលបានការណែនាំល្អៗពីលោកគ្រូ-អ្នកគ្រូ នឹងទទួលបានចំណេះដឹង ដែលជាអាវុត្ថអាចការពារខ្លួនបាន។

▪ **ចំពោះអង្គការក្រៅរដ្ឋាភិបាល**

- គួរតែបង្កើតឲ្យមានវគ្គបណ្ដុះបណ្ដាល រយៈពេលខ្លី/វែងជូនទៅដល់ប្រជាពលរដ្ឋដែលនៅតំបន់ដាច់ស្រយាលងាយរងគ្រោះ និងមានចំណេះដឹងតិចតួចក្នុងការពិចារណា។
- គួរមានទំនាក់ទំនងល្អជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តការជួយសង្គ្រោះជនរងគ្រោះនៃ អំពើជួញដូរមនុស្ស និងចំណាត់ការទៅលើជនល្មើស។
- បង្កើតឲ្យមានកន្លែងស្នាក់នៅដ៏តិសម្បទាដល់ជនរងគ្រោះរយៈពេលយូរអង្វែង ដែលរួមមានកន្លែងបណ្ដុះសមត្ថភាព មន្ទីរពេទ្យទាំងផ្លូវកាយ និងផ្លូវចិត្ត កន្លែងហាត់ប្រាណមានផាសុខភាព របបអាហារគ្រប់គ្រាន់ដោយផ្អែកទៅដោយសារធាតុចិញ្ចឹម និងអនាម័យ ។ល។
- ត្រូវធ្វើការលាក់បាំងនូវជីវប្រវត្តិរបស់ជនរងគ្រោះក្នុងអំឡុងពេលស្ថិតក្នុងស្ថានភាពជួញដូរ ជៀសវៀងភាពអាម៉ាស ប៉ះពាល់ដល់តម្លៃ សេចក្ដីថ្លៃថ្នូរ។
- មានឧបករណ៍ សម្ភារៈ និងប្រដាប់ប្រដាផ្គួបផ្សំផ្សេងៗដែលអាចផ្ដល់ឲ្យជនរងគ្រោះនៅពេលជួយសង្គ្រោះដំបូង។
- មិនត្រូវបង្កើតជាអង្គការ ដែលមានគោលដៅជួញដូរមនុស្សបង្កប់នៅក្នុងប្រតិបត្តិការរបស់អង្គការឡើយ។

▪ **ចំពោះសមត្ថកិច្ចក្នុងស្រុក**

- ត្រូវបង្កើតច្បាប់ និងបទដ្ឋាននានាអំពីការជួញដូរមនុស្ស
- ពង្រឹងស្មារតីដល់សមត្ថកិច្ចក្នុងការធ្វើការងារបង្ក្រាបបទល្មើស ដោយឆន្ទៈអង្គអាចនិងមិនទទួលការសូកប៉ាន់ពីជនល្មើស ជាពិសេសមន្ត្រីអន្តោប្រវេសន៍នៅតាមព្រហ្មដែនជាមួយប្រទេសជិតខាង និងមន្ត្រីអាកាសចរណ៍។
- តុលាការត្រូវផ្ដន្ទាទោសជនល្មើស និងជនពាក់ព័ន្ធ (មន្ត្រី សាច់ញាតិ) ទាំងឡាយអនុលោមទៅតាមច្បាប់ជាធរមាន។

- ត្រូវធ្វើការផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងអំពីល្បិចកលគ្រប់ស្នៀតរបស់ជនល្មើសទៅដល់ប្រជាពលរដ្ឋទូទាំងប្រទេស។
- បង្កើតជាមជ្ឈមណ្ឌល និងកន្លែងស្ពានីតិសម្បទាឲ្យបានច្រើន។

# ឯកសារយោង

## បទដ្ឋានគតិយុត្តជាតិ៖

❖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី២៤ ខែកញ្ញា ១៩៩៣
❖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
❖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣១
❖ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
❖ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

## បទដ្ឋានគតិយុត្តអន្តរជាតិ

❖ អនុសញ្ញាស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវញ្ច័ពេស្យាកម្មលើជនដំទៃ, ចូលជាធរមាននៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥១
❖ អនុសញ្ញាស្តីពី ការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្ម និងពិធីសាររបស់វា
❖ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ចូលជាធរមានថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦
❖ កតិកាសញ្ញាស្តីពីទាសភាព, ចូលជាធរមាននៅថ្ងៃទី៩ ខែមិនា ឆ្នាំ១៩២៧

## សៀវភៅ

❖ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២, ២០១៣
❖ សៀវភៅ What is Behind Human Trafficking in Cambodai?, Amanda Monson, December 2009. http://traccc.gmu.edu/pdfs/student_research/Copy%20of%20Monson_Cambodia.pdf
http://www.asiafoundation.org/resources/pdfs/CCHRReportonHumanTraffickingTrialsinCambodiaJuly2010.pdf
❖ សៀវភៅ Migration And Human Trafficking: The case of Cambodia, Sonja Alexandra Barwitzki, September 2014. https://kh.boell.org/sites/default/files/uploads/2014/10/barwitzki_migration_and_trafficking_2014_final.pdf
❖ សៀវភៅ Human Trafficking is a modern day form of slavery, International Organization for Migration (IOM). https://ec.europa.eu/anti-trafficking/sites/antitrafficking/files/train_the_trainers_manual_1.pdf
❖ សៀវភៅ Human Traffiking in Cambodia: Reintegration of the Cambodian illegal migrants from Vietnam and Thailand, Neth Naro, Singapore June 2009. https://www.rsis.edu.sg/wp-content/uploads/rsis-pubs/WP181.pdf
❖ សៀវភៅ OUT FROM BEHIND CLOSED DOORS: A study on deomestic workers in Cambodia, UN WOMEN, September 2015.

http://www.idwfed.org/en/resources/out-from-behind-closed-doors-a-study-on-domestic-workers-in-cambodia/@@display-file/attachment_1

## របាយការណ៍

❖ របាយការណ៍ Human Trafficking Trails in Cambodia, Cambodia Center for Human Rights, 2010.
http://www.asiafoundation.org/resources/pdfs/CCHRReportonHumanTraffickingTrialsinCambodiaJuly2010.pdf

❖ របាយការណ៍៖ ការអភិវឌ្ឍន៍លើទាសភាព″ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា″, លីកាដូ , ភ្នំពេញ ២០១៦

❖ របាយការណ៍ The Global Slavery Index, How many people are in modern slavery in Cambodia,
http://www.globalslaveryindex.org/country/combodia/

# ឧបសម្ព័ន្ធ

# មន្ត្រីក្រសួងមហាផ្ទៃ បានចាត់ទុក អំពើជួញដូរមនុស្ស ថាជាទាសភាពសម័យទំនើប

Published on Thursday, 12 February 2015 01:43 Hits: 498 ដោយ ៖

ភ្នំពេញ៖ មន្ត្រីក្រសួងមហាផ្ទៃកម្ពុជា នៅថ្ងៃ១០ ខែកុម្ភៈ ឆ្នាំ២០១៥ បានអះអាងថា អំពើជួញដូរ មនុស្សត្រូវបានគេចាត់ទុកថាជាទាសភាពសម័យទំនើបដែលមានចរិកស្មុគស្មាញ ប្រកបដោយល្បិចកល ដែលត្រូវការចាំបាច់នូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការបង្ក្រាប ក៏ដូចជាទប់ស្កាត់បទល្មើស ដែលមានការចាត់តាំង និងឧក្រិដ្ឋជន ដើម្បីកាត់បន្ថយឈានទៅលុបបំបាត់ឲ្យបាន។
លោកស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ក្នុងពិធីប្រកាសគណៈកម្មាធិការ ជាតិ របាយការណ៍ និងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៤- ២០១៨ ដោយអំពាវនាវឲ្យមានការរួមកម្លាំងសហការ និងឯកភាពគ្នាក្នុងការចូលរួមទប់ស្កាត់ ក៏ជាបង្ក្រាបបទល្មើសដ៏គួរឲ្យស្អប់ខ្ពើមមួយនេះ។លោកបន្តថា ៖មន្ត្រីរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ បានធ្វើកិច្ចសហប្រតិបត្តិការលើ ការងារដើម្បីបង្ក្រាប ទប់ស្កាត់ និងបំបាត់សកម្មភាពជួញដូរមនុស្សនេះ ។ ប៉ុន្តែបទល្មើសនេះនៅតែកើតមាននៅឡើងដែលធ្វើឲ្យមានប្រជាពលរដ្ឋរងគ្រោះជាបន្តបន្ទាប់។
លោកបន្តទៀតថា ៖ឧក្រិដ្ឋជនដែលធ្វើសកម្មភាពបទល្មើសនេះ បានប្រើប្រាស់ល្បិចកល និងវិធីសាស្ត្រគ្រប់រូបភាព ក្នុងគោលបំណងទុច្ចរិត ដើម្បីកេងប្រវ័ញ្ចយកផលប្រយោជន៍ពីជន រងគ្រោះ បើទោះបីជាមានច្បាប់ដាក់ទោសទណ្ឌធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ឧក្រិដ្ឋជនមិនញញើតនិងធ្វើសកម្មភាពឡើយឲ្យតែគេអាចទាញយកផលចំណេញបាន។
លោកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ របាយការណ៍ និងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ដែរថា ការបង្ក្រាបអំពើជួញដូរមនុស្ស គឺត្រូវការចាំបាច់ណាស់ទាមទារឲ្យ មានកិច្ចសហការជាច្រើនជាពិសេសជាមួយជនរងគ្រោះ ដោយធ្វើយ៉ាងណាឲ្យពួកគេប្រមូល ឲ្យបាននូវភស្តុតាងគ្រប់គ្រាន់ដើម្បីអាចឲ្យយើងធ្វើការបង្ក្រាប ក៏ដូចជាការផ្តន្ទាទោសជនល្មើស ឲ្យមានប្រសិទ្ធិភាព។
លោកស្រីបន្តថា សម្រាប់កម្ពុជាយើងបានរកឃើញថា អំពើជួញដូរមនុស្សភាគច្រើន គឺបិតនៅក្នុងរូបភាពនៃការជួញដូរពលកម្ម និងការជួញដូរផ្លូវភេទ ដែលទាមទារឲ្យមានកិច្ចខិតខំ ប្រឹងប្រែងពីស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមទប់ស្កាត់ឲ្យមានប្រសិទ្ធិភាព។ គួរបញ្ជាក់ថា កំណើននៃការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ ជាពិសេសនារី និងកុមារ បានផ្តល់ឱកាស ឲ្យជនល្មើសអាចប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងកេញប្រវ័ញ្ចផ្លូវភេទ ៕
អត្ថបទ៖ ចាន់ សុជីវ៉ូ

Like Share Be the first of your friends to like this.

0 Comments Sort by Oldest

ប្រភពពី៖ http://hangmeasdaily.com/index.php/2014-09-08-02-20-17/524-2015-02-11-18-43-33 ថ្ងៃទី១៦/០៧/២០១៧

# អំពើហិង្សា (បទពាក្យ៧)

Posted on October 2, 2012by vawcambodia

ហិង្សាគ្រាំគ្រាទាំងចិត្តកាយ
ហិង្សានាំឆ្ងាយញាតិសណ្ដាន
ហិង្សានាំទុកគ្មានស្រាកស្រាន្ត
ហិង្សានាក្សាន្តរសាត់ឆ្ងាយ ។

ហិង្សាជាយាន្តនាំវិនាស
ហិង្សាគ្មានមាសគ្មានប្រាក់ចាយ
ហិង្សាខូចខាតទ្រព្យទាំងឡាយ
ហិង្សាសប្បាយទាំងទឹកភ្នែក។

ហិង្សានាំមកភាពល្ងង់ខ្លៅ
ហិង្សាកូនចៅលំបាកពេក
ហិង្សាអវិជ្ជានាំខ្លួនស្រេក
ហិង្សានាំបែកធ្លាក់អវចី។

ហិង្សានាំទោសទ័ណ្ឌដាក់ខ្លួន
ហិង្សាគុំគួនប្រពន្ធប្ដី
ហិង្សានាំកូនចៅប្រុសស្រី
ហិង្សានាំក្ដីគុកឃ្នងខ្នោះ។

ហិង្សាជាស្ពានចុះនរក
ហិង្សាជាភ្នក់នាំជំលោះ
ហិង្សាប្រព្រឹត្តនាំវេងគ្រោះ
ហិង្សាខូចឈ្មោះថាជាខ្លៅ។

បន្ទាប់ពីខ្ញុំជំរាបជូន
ប្រជាបងប្អូនកូននិងចៅ
ទោះបីមិនបានក្បោះក្បាយជ្រៅ
តែអាចយកទៅពិចារណា។

ហឹង្សាប្រព្រឹត្តមិនចំណេញ
គួរតែងាកចេញឬយ៉ាងណា
គួរតែអត់ធ្មត់អតិបរមា
ដោះស្រាយបញ្ហាតាមច្បាប់ចិត្ត។

ខ្ញុំសូមអភ័យខន្តីផង
បើមានខុសឆ្គងយ៉ាងណាប្រិយមិត្ត
ឃ្លោងឃ្លាអត្ថន័យមិនសមចិត្ត
សូមជួយពិនិត្យកែអក្ខរា។

ព្រោះតែស្រលាញ់ចូលចិត្តអាន		កំណាព្យបុរាណកេរ្តិ៍ដូនតា

នាំចិត្ត ហត្ថៈ ទាញប៉ាកា		តែងឃ្លាវាចាជាកំណាព្យ

(បទពាក្យ៧)

និពន្ធដោយ លោកអាន ប៉ូលី

ប្រភព៖ https://vawcambodia.wordpress.com/2012/10/02/%E1%9E%A2%E1%9F%86%E1%9E%96%E1%9E%BE%E1%9E%A0%E1%9E%B9%E1%9E%84%E1%9F%92%E1%9E%9F%E1%9E%B6-%E1%9E%94%E1%9E%91%E1%9E%96%E1%9E%B6%E1%9E%80%E1%9F%92%E1%9E%99%E1%9F%A7/ ថ្ងៃទី១៦/០៧/២០១៧

# ជំនួយផ្នែកច្បាប់

The Legal project is a vital aspect of CWCC's response to Violence against Women in it attempts to set deterrence for perpetrators and empower women to remove themselves from current abusive or exploitative situation. The Legal program is the second in the five Protection Project.

The Legal project provides legal advice and support for clients as they seek to resolve their case, in this way participating in holding perpetrators accountable for their violent and criminal actions. The Legal project is vital for clients, the vast majority of whom are too poor to secure legal representation.



**The objective of the Legal Project is to provide legal advice and representation for clients in civil and criminal cases.**

The Legal Project assists clients who have chosen to file charges in court by gathering evidence and providing legal counsel. During the trial, CWCC lawyers represent the clients and ensure that the verdict is enforced. In keeping with CWCC's policy of non-discrimination , these services are not limited to Cambodians, and include victims of other nationalities. In addition to providing details about the project, for each project it would be great to include a short quote, or one page case study, with related images of a community, or individual who has benefited from an aspect of this project.

ប្រភព៖ http://www.cwcc.org.kh/?p=17 ថ្ងៃទី១៧/០៧/២០១៧

## Rescue & Support for Trafficking Victim

When I was 13 my mother sold me to a Danish man. I was rescued by police and referred to CWCC in October 2009 and taken to the safe shelter. I missed my family so much, and felt so afraid and alone, and didn't want to join in any of the activities or have anything to do with anybody. Meeting with the counselor helped me so much, and I was able to share my story and relax. I am waiting for my case to go to court, and both my mother and the Danish man are in the BMC Provincial Prison.

ប្រភព៖ http://www.cwcc.org.kh/?p=131 ថ្ងៃទី១៧/០៧/២០១៧

# Cambodia:

Cambodia is situated in South-East Asia and is home to 15.14 million people[1]. It is estimated that 26% of the adult population is illiterate and 18.6% of the population live below the international poverty line of US$1.25/day[2]. The lives of children in Cambodia are also challenging with 36.1% of children working as child labour and 31.4% of children receive inadequate care[2]. Cambodia is a source, transit, and destination country for human trafficking[3].



## Human Trafficking

- An estimated 35.8 million people are in forced labour (including sexual exploitation) at any given time as a result of trafficking[9]
- Human trafficking affects every continent, country, and every type of economy
- Cambodia is ranked 14th in the world for modern slavery[10]
- An estimated 1.2 million children are trafficked every year[4]
- 22% of human trafficking victims are trafficked for commercial sexual exploitation, of whom 55% are women or girls[4]

## Sexual Exploitation:

- In Cambodia more than 6% of females and 5% of males aged 13-17 reported at least one experience of sexual abuse[5]
- Rape is increasing in Cambodia, and most victims of rape in Cambodia are children. The median age of rape victims in 2010 was 12 years old, two years younger than it was in 2007 [6]

- While the majority of child sex offenders are locals, the magnitude of Cambodia's cases of child sex tourism makes it a popular destination for offenders[7]
- 64% of children in Cambodia said that they knew children who had been sexually abused[8]

ប្រភព៖ https://www.sherescuehome.org/about/facts-and-statistics ថ្ងៃទី១៧/០៧/២០១៧

# ឃាត់ជនសង្ស័យ២នាក់ពីបទសញ្ជារកម្មនិងរំដោះនារី១០នាក់

សង្គម ប្រភព៖ [http://khmeread.com/posts/12652](http://khmeread.com/posts/12652) ថ្ងៃទី១៨/០៧/២០១៧

September 03, 2016 05:13PM

ភ្នំពេញ ៖ ដោយមានការបញ្ជាផ្ទាល់ពីលោក ស្រី ម៉ាក់នី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះធ្វើការបង្ក្រាបជាក់ស្តែងករណី សញ្ជារកម្មមានស្ថានទម្ងន់ ទោស នៅចំណុចផ្ទះលេខ៧២ ផ្លូវលេខ០៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១៦ និង៥០នាទីដោយបាននាំខ្លួនជនសង្ស័យចំនួន២នាក់។

ប៉ូលិសនិយាយថា ជនសង្ស័យ គឺឈ្មោះ នួន សុខណា ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ អ៊ាម ដារ៉ា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ និងនារីរកស៊ីផ្លូវភេទចំនួន ១០នាក់ (អនីតិជនម្នាក់) មកកាន់ការិយាល័យដើម្បីធ្វើការសាកសួរនិងស្រាវជ្រាវ។ វត្ថុតាងដកហូត៖ ស្រោមអនាម័យប្រើប្រាស់រួច, ស្រោមអនាម័យមិនទាន់ប្រើប្រាស់មួយចំនួន, សៀវភៅកត់ត្រាចំនួន៦ក្បាល។ បច្ចុប្បន្នការិយាល័យកំពុងធ្វើការសាកសួរ និងស្រាវជ្រាវ៕



ជនរងគ្រោះ



សញ្ជារិក

# ក្មេងស្រីលាតត្រដាងរឿងអាស្រូវទិញដូរផ្លូវភេទតាមរយៈមេអណ្ដើក



ក្មេងស្រីរូបនេះនិយាយពីការជួញដូរផ្លូវភេទ

**ខេត្តបាត់ដំបង** ៖ មានមន្ត្រីនគរបាល និង មន្ត្រីរាជការមួយចំនួននៅខេត្តបាត់ដំបង អាច មានឈ្មោះជាប់ពាក់ព័ន្ធក្នុងរឿងអាស្រូវទៅ នឹងការទិញដូរផ្លូវភេទក្មេងស្រីជំទង់ដែលជា

ឆ្នាំទី 43 លេខ 7013
ថ្ងៃ ពុធ ទី 21 ខែ កក្កដា ឆ្នាំ 2010

## ក្មេងស្រីហែកលាត...

អនីតិជនម្នាក់ ។ នេះបើតាមការរៀបរាប់ពី ក្មេងស្រីនោះកាលពីចុងសប្ដាហ៍មុន នៅ ការិយាល័យព្រហ្មទណ្ឌកិរិតស្រាលនៃស្នង ការដ្ឋាននគរបាលខេត្ត ខណៈដែលរូបនាងត្រូវ បានឃាត់ខ្លួនពីបទចោរកម្ម ។

ក្មេងស្រីឈ្មោះក.ស និយាយថា នាងកើត នៅថ្ងៃទី១០ តុលា ឆ្នាំ១៩៩៥ នៅរាជធានី ភ្នំពេញ ។ នាងទើបមានអាយុ១៦ឆ្នាំប៉ុណ្ណោះ មកទល់ពេលនេះ ។ នាងស្នាក់នៅផ្ទះជួលមួយ កន្លែងនៅសង្កាត់កាកាប ខណ្ឌដង្កោ ។ ប៉ុន្តែ នាងត្រូវបានគេបង្គាប់ឱ្យប្រាប់មនុស្សផ្សេងៗ ថានាងមានអាយុ១៨ឆ្នាំហើយ ។

នាងក.ស បានប្រាប់ថា រូបនាង រួមជា មួយមិត្តភក្តិក្មេងៗរបស់នាងប៉ុន្មាននាក់ទៀត ត្រូវស្ត្រីម្នាក់ឈ្មោះថា អាយុជាង៣០ឆ្នាំ រស់ នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជ ធានីភ្នំពេញ ល្បួងមកលក់ដូរផ្លូវភេទឱ្យពួក មន្ត្រីនានាក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយ មានជ័យ ។ មិនតិចជាង៥លើកទេ ដែល ស្ត្រីឈ្មោះថា បាននាំពួកនាងមកលក់ដូរផ្លូវ ភេទឱ្យពួកមន្ត្រីនៅខេត្តទាំង២ខាងលើនេះ ។

នាងបានបញ្ជាក់ថា ចំពោះខេត្តបាត់ដំបង រូបនាងត្រូវបានគេលក់ឱ្យមន្ត្រីស៊ីវិលខ្លះ ប៉ុន្តែ ភាគច្រើនគឺពួកមន្ត្រីនគរបាលមានបុណ្យស័ក្តិ និងមាននគរបាលសេដ្ឋកិច្ចមកពីក្រសួង ក៏ បានយកនាងទៅរួមភេទដល់ផ្ទះដែរ ។ នាង បានប្រាប់ទាំងអស់នូវឈ្មោះមន្ត្រីដែលធ្លាប់ ទិញដូរផ្លូវភេទនាង ។

នាងក.ស បានបន្តថា ស្ត្រីឈ្មោះថា រាល់ លើកតែងបបួលនាងថាទៅរកការងារធ្វើ ប៉ុន្តែទីបំផុតយកនាងទៅឱ្យរួមភេទជាមួយ ពួកមន្ត្រីខាងលើនេះ ។ម្ដងៗពួកមន្ត្រីល្មោភ កាមទាំងនោះតែងនាំនាងទៅច្រៀងខារ៉ា អូខេ ឬទៅផឹកស៊ីសប្បាយមុនពេលចូលផ្ទះ សំណាក់ ឬអូតែល ។

នៅយប់ថ្ងៃទី១៨ កក្កដា នេះ ស្ត្រីឈ្មោះ ថា បំរុងនាំនាងឱ្យជួបមន្ត្រីនគរបាលទាំងនោះ ទៀត ប៉ុន្តែខកខានដោយសារតែនាងជាប់ ពាក់ព័ន្ធក្នុងអំពើចោរកម្ម ។ ស្ត្រីឈ្មោះថា បានប្រាប់ឱ្យពួកនាងហៅគាត់ថា "ម៉ាក់" ប៉ុន្តែ នៅពេលដែលនាងមានរឿងស្រាប់តែទូរស័ព្ទ មកប្រាប់នាងឱ្យឈប់ហៅម៉ាក់ គឺហៅគាត់ថា មីងៗវិញ ។

មន្ត្រីនគរបាលព្រហ្មទណ្ឌនិយាយថា ដំបូង នាងក.ស មិនទម្លាយរឿងនេះទេ ព្រោះខ្លាច ស្ត្រីឈ្មោះថា ធ្វើបាប លុះមិនឃើញមានអ្នក ណាមកធានានាង ទើបនាងទម្លាយរឿង អាស្រូវនេះតែម្ដង ។ នាងក.ស ត្រូវបានចាប់ ខ្លួនកាលពីព្រឹកថ្ងៃទី១៨ កក្កដា នៅលើផ្ទះ សំណាក់មួយកន្លែងនៅភូមិរតនៈ សង្កាត់ រតនៈ ក្រុងបាត់ដំបង ពីបទចោរកម្មបន្ទំលួច ទូរស័ព្ទនៅផ្ទះអ្នកលក់គ្រឿងទេសម្នាក់ក្នុង ពេលដែលនាងទៅរកទិញសាប៊ូកក់ក្បាល ។

តាមប្រភពព័ត៌មានថា កាលចាប់ខ្លួននាង ក.ស នេះដំបូងមានមន្ត្រីនគរបាលបានទូរស័ព្ទ មកអន្តរាគមន៍ញឹកញាប់បំផុត ។ ប្រភពបាន ប្រាប់ថា ស្ត្រីឈ្មោះថា នេះជាអតីតមេការនៅ ហាងខារ៉ាអូខេឃីហោ "ធីស៊ីហ្វិចណៃ" នៅ ក្បែរផ្លូវជាតិលេខ៥ ស្ថិតនៅសង្កាត់រតនៈ ក្រុងបាត់ដំបង ។ បន្ទាប់មកនៅរសៀលថ្ងៃទី ១៨ កក្កដា នោះក៏មានបុរសម្នាក់គ្រប់គ្រង នៅហាងខារ៉ាអូខេនេះមកសុំធានានាងក.ស ដែរ ប៉ុន្តែក្រោយមកបានបាត់ខ្លួនរហូត សូម្បី ទូរស័ព្ទក៏បិទទាំងអស់ រាប់ទាំងស្ត្រីមេខ្យល់ ឈ្មោះថា នោះផងដែរ ។

លោកព្រុំ ធៀន ប្រធានការិយាល័យ ព្រហ្មទណ្ឌកិរិតស្រាលបានប្រាប់ថា កម្លាំង ជំនាញរបស់លោកបានកសាងសំណុំរឿងចោរ កម្ម ប៉ុន្តែសំណុំរឿងពាក់ព័ន្ធការជួញដូរផ្លូវ ភេទ គឺទុកឱ្យការិយាល័យជំនាញចាត់ការបន្ត និងបានបញ្ជូនក្មេងស្រីនោះទៅតុលាការ ។

លោកកុយ ហៀង ប្រធានការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិ ជនបានប្រាប់ថា សមត្ថកិច្ចរបស់លោកបាន សាកសួរនាងអំពីការជួញដូរផ្លូវភេទនេះ និង បានស្គាល់ឈ្មោះស្ត្រីដែលនាំនាងមកលក់ដូរ ផ្លូវភេទនេះហើយ ប៉ុន្តែយើងកំពុងស្រាវជ្រាវ រកសាវតាររបស់ស្ត្រីមេខ្យល់នោះផងដែរ ដើម្បីចាត់ការ ។

ទោះជាយ៉ាងណា បើពិនិត្យលើសកម្ម ភាពរបស់ពួកមន្ត្រីល្មោភកាមខាងលើដែល អះអាងដោយក្មេងស្រីក.ស នេះគឺសបញ្ជាក់ ឱ្យឃើញថា ទង្វើរបស់ពួកគេវាផ្ទុយគ្នាទាំង ស្រុងទៅនឹងគោលនយោបាយរបស់រាជរដ្ឋា ភិបាល ដែលបានប្រកាសពីការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស និងការជួញដូរផ្លូវ ភេទលើកុមារ ហើយចំណាត់ការនោះត្រូវ បានប្រមុខរាជរដ្ឋាភិបាលប្រកាសឱ្យមន្ត្រី សមត្ថកិច្ចគ្រប់ស្ថាប័នទាំងអស់ត្រូវអនុវត្តឱ្យ បានខ្លាំងក្លាដើម្បីទប់ស្កាត់ ប៉ុន្តែផ្ទុយទៅវិញ បែរជាពួកមន្ត្រីខាងលើប្រើងប្រែងប្រព្រឹត្តបទ ល្មើសនេះលើឈាមជ័រក្មេងស្រីបំប៉នតណ្ហា របស់ខ្លួនទៅវិញ និងមានន័យថា ជាការជំរុញ ឱ្យមានការជួញដូរមនុស្សតទៅវិញ ៕

ចុភារ៉ៈ

# បទដ្ឋានគតិយុត្តជាតិ

# ករណីសិក្សាពាក់ព័ន្ធ

# របាយការណ៍ និចឆិន្ឆន័យ

**SIREN case analysis**

STRATEGIC INFORMATION RESPONSE NETWORK
United Nations Inter-Agency Project on Human Trafficking (UNIAP): Phase III

PHNOM PENH, CAMBODIA

22 April 2009 CB-03

# EXPLOITATION OF CAMBODIAN MEN AT SEA

## FACTS ABOUT THE TRAFFICKING OF CAMBODIAN MEN ONTO THAI FISHING BOATS

| | |
|---|---|
| **KEYWORD** | ▪ **Location:** Cambodia, Thailand, Malaysia<br>▪ **Topic:** Recruitment; labor exploitation; fishing industry<br>▪ **Information type:** Case analysis from 18 months of casework; n=49 |
| **Synopsis** | *Fact sheet on the recruitment, trafficking, and exploitation of Cambodian men onto Thai fishing boats, based on 49 cases of victims who escaped in Thailand or Malaysia and were assisted in their return home.* |
| **Author** | UNIAP UNITED NATIONS INTER-AGENCY PROJECT ON HUMAN TRAFFICKING[1] |

*An estimated thousands of Cambodian men, women, and children are trafficked annually to Thailand for the purpose of labor exploitation. Some of the worst exploited are the men and boys who are deceived onto long-haul fishing boats that fish the waters of the South China Sea, including into Malaysian waters[2]. These boats, out to sea for up to two years or more, become virtual prisons on which the trafficking victims endure inhumane working conditions, and physical abuse. Death at sea is frequently reported, sometimes at the hands of the Thai boat captains. The only way to escape is to jump ship when the boat goes ashore for registration/documentation purposes in places like Sarawak, Malaysia.*

*This SIREN report summarizes the facts about the trafficking of 49 Cambodian men and boys trafficked onto Thai long-haul fishing boats and assisted over the past 18 months by a network of responders spanning Cambodia, Thailand, and Malaysia. There are some variations in the scenarios faced by these men and boys, but the common theme is deception and debt bondage by two or more Khmer and Thai brokers; their sale to a Thai boat owner for 10,000-15,000 Baht[3]; slave-like working conditions at sea, including beatings, deprivation of food, inhumane work hours (for example, working 3 days and nights straight when nets need to be mended), lack of medical treatment for illnesses and injuries, and threats of death; and sometimes, reportedly, murder.*

*Some of these victims escape their enslavement by jumping ship, but often their suffering does not end here. In Sarawak, Malaysia, brokers feed exploitative palm oil and rubber plantations with the labor of these men and boys, who are easily recruited as they flee from the Thai boat captains and their agents who operate in the vicinity of the port. Some victims are picked up by police or immigration officials instead of brokers (sometimes leading to arrest, fines, caning, and deportation; sometimes leading to plantation work). Some victims surrender to the authorities immediately, in hopes of a swift deportation home. None were screened as trafficked persons.*

---

[1] This report reflects the collaboration and learning of many agencies involved in these cases, including non-government partners IOM, LICADHO, and LSCW in Cambodia, and Tenaganita in Malaysia; and government partners MoFA, MoSAVY, and MoWA in Cambodia; Immigration authorities in Malaysia; and MOJ's DSI in Thailand.

[2] Olivie, Andre (2008). *Identifying victims of human trafficking among deportees from Thailand.* UNIAP.

[3] Around $287-430 US Dollars, at the current exchange rate of 34.8 Baht/dollar.

## CASE SUMMARY
## 49 Cambodian men and boys trafficked onto Thai long-haul fishing boats and assisted in Thailand or Malaysia, June 2007 – December 2008 (18 month period)

The sample of cases included in this analysis are Cambodian men and boys who met four criteria: (1) they were trafficked onto Thai fishing boats; (2) they escaped the boats; (3) they were identified and assisted in the past 18 months by a network of responders in Cambodia, Thailand, and Malaysia; and (4) they have been safely returned to Cambodia. These men and boys were interviewed by UNIAP staff in Khmer language, in or near their home villages.

There are dozens of similar cases that government and NGO responders have assisted prior to this reporting period, and there are also many cases 'in progress' of victims who have been traced and located, but not yet safely returned home. These cases will not be included, for the sake of clarity.

## *Origin provinces in Cambodia and destinations in Thailand for the 49 victims*

10 of the 49 men and boys were from Banteay Meanchey province and 11 of the 49 men were from Kandal province. The high representation in these two provinces is due to the fact that two of the major cases covered in the past 18 months were reported by family members in these provinces, where large groups of men were trafficked *en masse* onto the same boats. In total, the 49 men originated from 13 provinces – a fairly wide distribution across Cambodia. In Thailand, 57% of the victims were trafficked onto boats in Pak Nam, Samut Prakan province, and 31% onto Songkhla boats.







***Cambodia map, above left: Source provinces of victims (highest to lowest).*** *Kandal (11); Banteay Meanchey (10); Siem Reap and Takeo (5 each); Battambang and Kampong Thom (4 each); Oddar Meanchey, Kampong Cham, and Prey Veng (2 each); and Stung Treng, Kampong Speu, Kampot, and Phnom Penh (1 each).*

***Thailand map, above right: Destination provinces where Cambodian victims were forced onto long-haul fishing boats (highest to lowest).*** *Pak Nam, Samut Prakan province (28); Songkhla port (15); Klong Yai, Trat and Pattani ports (2 each); Samut Sakhon and Prachuap Khiri Khan (1 each).*

With regard to age, 18% of the 49 victims were children at the time that they were recruited and forced onto the boats; the remainder were adults.

**Age of victims at time of recruitment**

**[Age range: 15-53]**




**Photo (right): Three of the younger rescued victims from the sample of 49, interviewed in their home village (December 2008).**




***From village to fishing boat: Networks of Cambodian and Thai brokers, organized in a few different ways, deceive the victims onto the fishing boats for the purpose of exploitation for two years or more.***

Most of the victims are able to clearly describe the abuses they suffered and by whom, with descriptions of the brokers, exploiters, and locations involved in their abuse, as well as the promises made and broken. The following quote illustrates a typical scenario of credit bondage (withholding of payment to compel the worker to not escape, in the hopes that he will eventually receive the full payment owed to him), followed by cheating.

> *"I could get 6,000 Baht per month, but I had never received my salary. My boss did not give me my salary and he asked me to wait for next month, again and again. When I worked for 1 year I tried to ask him for my salary. He gave me 20,000 Baht for 1 year that I worked for him. I sent all of my money to my mother in Cambodia through [the broker]. But [the broker] did not send my money to my mother, he kept it for himself."* - 21-year-old victim from Prey Veng

As illustrated in the quote below, victims were also able to easily ascertain the nationalities of all brokers, transporters, and exploiters involved – that is, whether they were Cambodian or Thai.

***Question: Did anyone help you on the Thai side of the border…help you to arrange transportation or work?***
Answer: A Thai broker helped me to go to Thailand, and found a job for me.

***Question: Did you pay this person? How much? What do you know about this person?***
Answer: I did not pay them. When the Thai broker drove me to my work, he took 2,500 Baht from my boss so I needed to work for my boss in order to return his money back. I did not know the Khmer or Thai brokers before. The first Khmer broker's name is [name deleted] and his age is around 28-29 years old. He is Cambodian and his occupation was to bring people from Cambodia to work in Thailand. And he transferred money from Cambodian people who were working in Thailand to their family in Cambodia. The second Khmer broker was a man, Cambodian, aged around 25 years old. I thought maybe he was a soldier because when I met him, he wore a soldier uniform. The Thai broker's age was around 27…he was Thai, [name deleted]. - 23-year-old victim from Prey Veng

An analysis of the recruitment/brokering of the 49 victims reveals the following broker/trafficker patterns and practices.

| **PROMISES MADE AND BROKEN<br>Reported tricks and promises of brokers** | |
|---|---|
| **Monthly earnings in Thailand promised by brokers to victims** | 3,000-7,000 Baht<br>(USD $86-$200) |
| **Amount earned by brokers from selling victims to boat owners or captains** | 10,000-15,000 Baht<br>(USD $287-$431) |
| **Amount earned by intermediary brokers and transporters** | 1,500-2,500 Baht<br>(USD $43-$72) |
| **Job promised by broker to victim** | Usually no specific job is promised. Sometimes factory or construction jobs are promised. |

**Pathways to slavery. Broker/trafficker networks feeding exploitative long-haul fishing boats.**

***Red arrows indicate clear linkages to exploitation. The yellow and orange pathways were about evenly represented in the sample. Enforcement responses should focus on the links to exploitation.***



**_On the long-haul boats: Victims typically experience numerous forms of severe exploitation at sea, including beatings to the head and body, starvation, lack of pay, and psychological trauma from witnessing violence and murder._**

Virtually all of the men and boys reported enduring the following exploitative conditions and treatment: beatings to the head and body; threats to life; trauma from witnessing violence, death, and murder; inhumane working hours (sometimes up to three days and nights straight); sleep and nutritional deprivation; and extremely hazardous, sometimes life-threatening, working conditions. All of the long-haul boats seemed to be out to sea for two years or more, served by supply boats providing supplies, fuel, ice, and new workers (and picking up fish) while closer to Thailand, and making cyclical stops to the Sarawak shore while in Malaysian waters. According to the victims, men are traded from boat to boat in the open sea as manpower needs change.

*"We were beat frequently by the Thai crew, on the back of the head and across the back. The captain had a gun. On shore [on Sarawak] we saw a Thai captain decapitate a Vietnamese fisherman, and another Thai captain decapitate a Thai fisherman."*
- 19-year-old victim from Banteay Meanchey

*"My boss used bad words toward me, beat me, forced me to do hard work, and threatened me that if I braved to run, he would shoot me. There were a lot of big waves in the sea. It was not safe. A worker died because he fell into the sea and my boss knew it as well, but he did not return the boat to save him."*
- 21-year-old victim from Prey Veng

**Proportion of victims who report witnessing a murder by the boat captain**









**Photos (above): Examples of fishing trawlers, Pak Nam, Samut Prakan, Thailand (August 2008).**
**Photo credits: UNIAP.**




**Photo (above): Fishing trawler, Songkhla, Thailand (August 2007).**

## *Post-escape experiences in Thailand and Malaysia: Re-trafficking and extortion await many escaped trafficking victims.*

After jumping ship, what happened to the escaped victims in Malaysia? This sample presents a bias in victims who were found and deported (as opposed to those re-trafficked onto plantations and not found); however, it is still instructive to examine some of the outcomes of the 49 victims.

It is noteworthy that none were screened or identified as victims of trafficking according to Malaysian law[4].

| EXAMPLES OF POST-ESCAPE OUTCOMES IN MALAYSIA |
|---|
| ► Arrested, charged under Immigration Act, sentenced, punished (fined and/or caned), and deported as illegal immigrants |
| ► Chased down by Thai agents affiliated with the boat captains and owners (but protected by Malaysian immigration officers) |
| ► Hid out in forests, sewers, or rural areas, then found and sold onto plantations or farms by Chinese, Malaysian, or Thai brokers |
| ► Held by agents who contacted victims' family members in Cambodia and requested money for the victims' release and return |
| ► Assisted by local Malaysians who offered food, money, and cell phone usage to call home and to call the police |
| ► Assisted to find work on "good" plantations by other Cambodian men living in Sarawak who previously escaped slavery at sea, as opposed to being re-trafficked onto more exploitative plantations |

[4] Malaysian Anti-Trafficking in Persons Act (2007).

## RECOMMENDATIONS

The three recommendations offered below have been informed by many of the government and non-government anti-trafficking responders involved in the identification and support of these victims.

**RECOMMENDATION 1: Law enforcement and coordination.** The laws and policies of Cambodia[5], Thailand[6], and Malaysia are essentially in line with international standards and definitions. If enforced, they could identify and protect these men and boys as victims of human trafficking, and punish their enslavers[7], such that:

- More victims could be immediately screened and identified by Malaysian authorities once they land on Malaysian soil, then repatriated swiftly and safely through Cambodian Embassy cooperation. Both Cambodia and Thailand have trafficking victim screening guidelines and procedures in place that are in line with their anti-trafficking laws and international standards. Similar trafficking victim screening guidelines and procedures for Malaysia would greatly strengthen the three countries' ability to suppress this form of human trafficking, as well as to provide the protection, treatment, and services to victims that are their rights under the laws of all three countries.

- Critical information could be shared between the three countries to support enforcement operations against the worst exploiters – the boat owners and captains, as well as the agents clearly linked to them – so that an increase could be seen in the numbers of exploiters investigated/prosecuted, and numbers of victims identified/assisted. Cambodia, Malaysia, and Thailand all have established specialist enforcement and investigative units to suppress human trafficking[8]. Increased coordination between these units of the three countries and clearly designated focal points and mechanisms for communication, information sharing, and coordination, would again greatly strengthen the three countries' ability to suppress this form of trafficking.

**RECOMMENDATION 2: Livelihood alternatives.** With few livelihood and reintegration options for these men and boys, particularly in the midst of the global financial crisis, safe, legal options for employment of these men – whether in Cambodia or elsewhere – should be a priority for service providers and donors. Feedback from victims indicates that most would prefer to stay and work in Cambodia, if they could find work and make a steady income.

**RECOMMENDATION 3: Trafficking prevention.** Empirically-based preventive measures should be implemented at both origin and destination locations. This report provides critical information on the origin provinces in Cambodia that should be targeted, as well as the destination provinces in Thailand. The tricks and false promises of the recruiters reported by the 49 victims could be used to inform and update awareness-raising messaging to the vulnerable populations targeted.

---

[5] Cambodian Law on Suppression of Human Trafficking and Sexual Exploitation (2008).
[6] Thai Anti-Trafficking in Persons Act (B.E. 2551 / 2008).
[7] However, no traffickers or exploiters in these types of cases have been prosecuted to date.
[8] The Royal Cambodian Police has an Anti-Human Trafficking Unit at the central level as well as the provincial and municipal levels, nation-wide. The Royal Malaysian Police Force has a Special Anti-Trafficking Unit in the Federal Headquarters, and are in the process of having a similar unit in each of the 13 states. The Royal Thai Government has anti-trafficking units within the Children and Women's Division of the Royal Thai Police, and within the Department of Special Investigations (DSI) of the Ministry of Justice.

# SIREN

**STRATEGIC INFORMATION RESPONSE NETWORK**
**United Nations Inter-Agency Project on Human Trafficking (UNIAP): Phase III**

**SIREN releases (June 2007 – April 2009)**

***Please contact SIREN for hard copies or soft copies, in English or Mekong languages!***

GMS-01 – Introduction to SIREN: The Strategic Information Response Network
GMS-02 – Targeting Endemic Vulnerability Factors to Human Trafficking
GMS-03 – Statistical Methods for Estimating Numbers of Trafficking Victims
GMS-04 – The State of Counter-Trafficking: A Tool for Donors
GMS-05 – Why Victims of Trafficking Decline Assistance: Feedback from European Trafficking Victims
GMS-06 – Raids, Rescues, Resolution: Removing Victims from Sex and Labor Exploitation

CB-01 – Counter-Trafficking Databases in Cambodia
CB-02 – Exploitation of Cambodian Men at Sea (Kandal 11 Case)
CB-03 – Exploitation of Cambodian Men at Sea: Facts about the Trafficking of Cambodian Men onto Thai Fishing Boats

TH-01 – From Facilitation to Trafficking: Brokers and Agents in Samut Sakhon, Thailand
TH-02 – What Do Lawyers Require to Prosecute Trafficking and Slavery in Thailand? Guidelines from Lawyers to Front-line Agencies

UK-01 – Raids, Rescues, Resolution: Pentameter 2: Attacking Exploitation in the UK

Country Data Sheets (v. 1.0): Cambodia, China, Lao PDR, Myanmar, Thailand, and Vietnam

For information about UNIAP's SIREN project, please contact SIREN@undp.org.

## SIREN is an initiative supported by:

**United Nations Inter-Agency Project on Human Trafficking**
**Regional Project Management Office (UNIAP/PMO)**
**United Nations Building**
**7th Floor, Block B**
**Rajadamnern Nok Avenue, Bangkok 10200**
**THAILAND**

**www.no-trafficking.org**